ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)
- ស្ងួន ការសេត្រ អគ្គនាយកទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម ក្នុងរបប លន់ នល់
- សឹង ណាំ៖ រំឭកអំពីការរស់រានមានជីវិតរបស់ខ្លួនក្នុងពេលសង្គ្រាម និងការតាមសម្លាប់ដោយកងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតី

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា
លេខ៣០០ ខែធ្នូ ឆ្នាំ២០២៤

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

### សំបុត្រ


- អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ........................១


### ផ្នែកឯកសារ


- ប៉ែនវ៉ាន់សែ ហៅ សែ ហៅ តែល ៖ អតីតនិស្សិត . ទូរគមនាគមន៍ ប្រទេសបារាំង..................... ៤
- សួន កាសេត្រ អគ្គនាយកទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម ក្នុងរបប លន់ នល់.......................៩


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- នួន រឿន៖ អតីតប្រធានកងចល័ត............... ១៣
- របបខ្មែរក្រហមមិនបានយកចិត្តទុកដាក់........ ១៥
- ស្មាន តីយ៉ុម៖ ខ្មែរក្រហម ធ្វើឱ្យយាយ ..........១៧
- សឹង ណាំ៖ រំឭកអំពីការរស់រានមានជីវិតរបស់ខ្លួនក្នុងពេលសង្គ្រាម ...................... ២០
- សំ ឡុង៖ ឪពុកខ្ញុំ និងអ្នកភូមិបុសតាអ៊ឹមប្រមាណ ៣០នាក់ត្រូវបានខ្មែរក្រហមសម្លាប់............ ២៤
- អ៊ុត សុខា៖ ខ្ញុំមានសំណាងមិនស្លាប់រហូតដល់ទៅបីដង...................................២៧
- ស្ម័គ្រចិត្តបម្រើបដិវត្តន៍ .......................... ២៩
- ជុំ សារីម ៖ ប្រធានរោងបាយ .................. ៣៣
- មជ្ឈមណ្ឌលឯកសារកម្ពុជាចូលរួមក្នុងវេទិកាទេសចរណ៍មូស្លីមកម្ពុជាឆ្នាំ២០២៤ ...............៣៧


### ផ្នែកវេទិកាពិភាក្សាសាធារណៈ


- អនាគតដែលត្រូវឆក់យកទៅ៖ .................. ៤០
- តើ «ការធ្វើតាមបញ្ជា»៖ ចម្លើយដែលបានមកអាចទទួលយកបានដែរឬទេ?.................. ៤៥




ស្តូបដែលបានសាងសង់ឡើងដោយ សម្តេចព្រះនរោត្តម សីហនុ «ព្រះបរមរតនកោដ្ឋ» នៅឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ-សែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


- តើហេតុអ្វីបានជាគេនិយាយថាជនជាតិដើមភាគតិចមានទំនាក់ទំនង.................. ៤៨
- ប្តីប្រពន្ធដែលជាប់សែស្រឡាយ.............. ៥១
- និស្សិតមហាវិទ្យាល័យច្បាប់ ...................៥៣
- និស្សិតមហាវិទ្យាល័យនីតិសាស្ត្រ............ ៥៧


### ផ្នែកស្រាវជ្រាវរកគ្រួសារ


- ថ្នាំមួយគ្រាប់ប្តូរនឹងជីវិតម្តាយជួយកូនស្រីមានជំងឺរាក............................... ៦១



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ៣៧៥ព.មប្រក

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ ៖** ឆាំង យុ, លី ដេវីត, សុខ វណ្ណៈ, ស៊ាង ចិន្តា, ឡុង ដានី, ថុន ស្រីពេជ្រ, នេន ស្រីមុំ, សម្បត្តិ សុណិសា, អេង សុខម៉េង, ស្រ៊ាង លីហ៊ួរ, រចឹម បុប្ផា, ដេង ពង្សរ៉ាស៊ី និង រី លក្ខិណា

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លឹម អ៊ុកឹង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន

**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# អគារមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)

ឆាំង យុ



លោក លី មីណា អភិបាលស្រុកបុរីអូរស្វាយ-សែនជ័យ (រូបជួរមុខទី១ រាប់ពីឆ្វេង) ឯកឧត្តមបណ្ឌិត នួន ពេជ្រនិមិត្ត រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ (រូបជួរមុខទី៤ រាប់ពីឆ្វេង) និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា (រូបជួរមុខទី៥ រាប់ពីឆ្វេង) ក្នុងពិធីបើកឱ្យប្រើប្រាស់អគារមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ដែលជាសាខាមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីទទួលសាធារណជនមកទស្សនា និងអ្នកស្រាវជ្រាវ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឆ្នាំ១៩៦៤ ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ «ព្រះបរមរតនកោដ្ឋ» បានយាងជាផ្លូវការមកកាន់ភូមិអូរស្វាយ ហើយបានប្រមូលផ្ដុំប្រជាជននៅក្នុងភូមិដ៏តូចមួយនេះ ដែលប្រកបទៅដោយភាពស្រស់ស្អាតស្ថិតនៅជាប់ដងទន្លេមេគង្គ។ ប៉ុន្មានឆ្នាំក្រោយមក ភូមិតូចមួយនេះ ស្ទើរតែបាត់បង់ទាំងស្រុងពីការចងចាំរបស់យើងក្នុងអំឡុងសង្គ្រាមវៀតណាម ហើយចាប់តាំងពីពេលនោះមក ស្ទើរតែត្រូវបានបំភ្លេចចោល។

នៅក្នុងឆ្នាំ ២០១៩ ដោយសារព្រះទ័យសប្បុរស និងគាំទ្ររបស់ ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ភូមិអូរស្វាយបានលេចត្រដែតឡើងវិញ ដោយមានការសាងសង់សាលារៀន មន្ទីរពេទ្យ និងបន្ទប់ទឹកសាធារណៈ។ ឆ្នាំនេះគឺឆ្នាំ២០២៤ ភូមិដ៏តូចនេះនឹងរំឭកឡើងវិញកាលពី៦០ឆ្នាំមុននៃការយាងមកដល់របស់ ព្រះបាទ

សម្តេច ព្រះនរោត្តម សីហនុ «ព្រះបរមរតនកោដ្ឋ» មកកាន់ភូមិអូរស្វាយ (បច្ចុប្បន្នមានឈ្មោះថា ស្រុកបុរីអូរស្វាយ-សែនជ័យ) ហើយដែលមជ្ឈមណ្ឌលឯកសារកម្ពុជា មានមោទកភាពបានចូលរួមចំណែកក្នុងការស្តារមកវិញនូវមរតករបស់ ព្រះបាទសម្តេចព្រះនរោត្តម សីហនុ «ព្រះបរមរតនកោដ្ឋ» ដោយបានសាងសង់ព្រះរាជដំណាក់តូច ជាបណ្ណាល័យ, សាងសង់កំពង់ផែជាច្រើន, ការរៀបចំឡើងវិញនូវដងទន្លេមេគង្គ និងការសាងសង់ទូកថ្មីជាច្រើនគ្រឿង ដែលទាំងអស់នេះគឺសម្រាប់ប្រើប្រាស់ជាសាធារណៈ។ គ្រឿងបរិក្ខារ និងមធ្យោបាយធ្វើដំណើរតាមទូកថ្មីមានសារសំខាន់ណាស់ក្នុងការពង្រឹងសហគមន៍ឡើងវិញដែលលាតសន្ធឹងក្នុងចំណោមកោះទាំង៦។ ប្រវត្តិសាស្ត្រ បរិស្ថាន និងបេតិកភណ្ឌវប្បធម៌ក្នុងតំបន់បុរីអូរស្វាយ-សែនជ័យ គឺជាធនធានដែលមិនអាចកាត់ថ្លៃបានដែលត្រូវតែថែរក្សា និងការពារសម្រាប់មនុស្សជំនាន់ក្រោយ។

អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ដែលជាសាខាមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងចាប់ផ្តើមទទួលសាធារណជន អ្នកស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤។ មជ្ឈមណ្ឌលឯកសារ



ស្តូបដែលបានសាងសង់ឡើងដោយ សម្តេចព្រះ នរោត្តម សីហនុ «ព្រះបរមរតនកោដ្ឋ» និងអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ- សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ដែលសាងសង់ឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ-សែនជ័យ ខេត្តស្ទឹងត្រែង នៅពេលរាត្រី។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កម្ពុជា នឹងចាប់ដំណើរការដំណាក់កាលបន្ទាប់នៃកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួននៅឆ្នាំ២០២៥ ដែលនឹងរួមបញ្ចូលក្នុងចំណោមសកម្មភាពជាច្រើនផ្សេងទៀត រួមមាន ការស្រាវជ្រាវប្រវត្តិសាស្ត្ររបស់សហគមន៍ សិល្បៈចម្លាក់ និងការកែលម្អបន្ថែមទៀតដល់ការិយាល័យ និងសហគមន៍ជុំវិញ។

ក្នុងអំឡុងរដូវវស្សាហើយនេះ ទឹកទន្លេមេគង្គប្រែជាពណ៌លឿង ដោយសាររដូវប្រាំងកំពុងមកដល់ហើយ យើងនៅតែមានភាពភ្ញាក់ផ្អើលជាមួយនឹងពន្លឺដ៏ភ្លឺចែងចាំងដែលរេរាំលើផ្ទៃទឹកនៅពេលថ្ងៃរះ និងថ្ងៃលិចនៅក្នុងតំបន់បុរីអូរស្វាយ-សែនជ័យ (តំបន់នេះត្រូវបានការពារដោយអនុសញ្ញារ៉ាមសារ ដែលត្រូវបានកំណត់ថាមានសារសំខាន់ជាអន្តរជាតិ ជាពិសេសជាជម្រកសត្វទឹក)។ ខ្សាច់ពណ៌សនៅលើកោះដែលមានឈ្មោះថា «កោះទន្សាយ» រួមទាំងសហគមន៍ជុំវិញនោះគឺអស្ចារ្យខ្លាំងណាស់ ហើយខ្យល់សម្រាប់រដូវកាលនេះហាក់ដូចជា ខ្យល់នៅលើកំពូលអគារ នានិទាឃរដូវក្រុងប៉ារីស។ តំបន់នេះពិតជាពោរពេញដោយសម្រស់ធម្មជាតិ ភាពអស្ចារ្យ តម្លៃប្រវត្តិសាស្ត្រ និងវប្បធម៌ដ៏ធំសម្បើម។



ទូកដឹកភ្ញៀវទេសចរណ៍នៅ ទន្លេមេគង្គក្នុងឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ-សែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



L'avenue à double voie qui traverse le centre. Des arbres d'ornement ont été plantés de part et d'autre des deux chaussées. Un kiosque a été édifié. Au fond le bâtiment administratif où se trouve la direction du centre.





# LE CENTRE AGRICOLE DE O SVAY, DANS STUNG TRENG

*(17 mai)*

LE 6 mai 1964, à la tombée de la nuit, une cinquantaine de militaires, ayant quitté Phnom Penh deux jours plus tôt, arrivaient sur la berge est du Mékong, à quelque cinq kilomètres de la frontière du Laos, après s'être frayé un passage au coupe-coupe, sur une douzaine de kilomètres à travers la forêt, à partir de la route nationale Phnom Penh, Kratié, Stung Trêng et Savannakhet au Laos. Une rivière, le O Svay, se jetait dans le fleuve près de là. Une dizaine de paysans — pêcheurs, hommes, femmes et enfants — vivant du fleuve et de quelques arpents de terre, représentaient toute la population du lieu.













# ប៉ែន វ៉ាន់សៃ ហៅ សៃ ហៅ តែល ៖ អតីតនិស្សិត ទូរគមនាគមន៍ ប្រទេសបារាំង

**ដារ៉ាវឌ្ឍ មេត្តា**



*កម្មករធ្វើការនៅរោងចក្រ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*ខ្ញុំឈ្មោះ ប៉ែនវ៉ាន់សៃ ហៅ សៃ ហៅ តែល មានអាយុ៣៣ឆ្នាំ ក្នុងឆ្នាំ១៩៧៨។ ខ្ញុំមានគ្រួសារហើយ។ ខ្ញុំមានស្រុកកំណើតនៅសង្កាត់លេខ២ ក្រុងភ្នំពេញ។ ខ្ញុំគឺជាអតីតនិស្សិតសាលាទូរគមនាគមន៍ ប្រទេសបារាំង។ មុនអង្គការចាប់ខ្លួនខ្ញុំមានតួនាទីជាជំនួយការបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច។*

*នៅឆ្នាំ១៩៥០ ខ្ញុំចូលរៀនសាលាបឋមសិក្សា រហូតដល់ឆ្នាំ១៩៥៦ បានចូលរៀននៅវិទ្យាល័យស៊ីសុវត្ថិ រហូតដល់ថ្នាក់បញ្ចប់។ នៅឆ្នាំ១៩៦៣ ខ្ញុំចូលរៀនមហាវិទ្យាល័យវិទ្យាសាស្ត្រផ្នែកទី១។ ពេលនោះខ្ញុំបានស្គាល់និស្សិតម្នាក់ឈ្មោះ អ៊ិន សុភាព ហៅ មី គឺជានិស្សិតនិងក្រោយមកជាបុគ្គលិកផ្នែកបេសកកម្មក្រៅប្រទេស នៅក្រសួងការបរទេស។ អ៊ិន សុភាព ហៅ មី បានអប់រំខ្ញុំថា «នៅក្នុងរបបមូលធននិយមត្រូវការប្រុចង់បានអ្វីពេលណារកបានទាំងអស់ឱ្យតែមានលុយ ហើយលុយក៏មិនពិបាករកដែរឱ្យតែមានចំណេះដឹងច្បាស់លាស់» ហើយ អ៊ិន*

សូភាព ហៅ មី បន្ទអប់រំខ្ញុំជាហូរហែ។

នៅខែកុម្ភៈ ឆ្នាំ១៩៦៤ អ៊ុន សូភាព ហៅ មី បាននាំខ្ញុំទៅផ្ទះ ភោគ ឆាយ នៅខាងកើតផ្លូវចុះទៅអូរប៉ុស្ស៊ី ដើម្បីបញ្ចូលខ្ញុំជាសេ-អ៊ី-អា។ នៅក្នុងកម្មវិធីបញ្ចូលមានៈ គោរពទង់ជាតិអាមេរិក, អ៊ុន សូភាព ប្រកាសបញ្ចូលខ្ញុំ និងឱការ៉េត ក្នុងក្រុមសេ-អ៊ី-អា។ ចំណែកអ្នកចូលរួមមានៈ ១) អ៊ុន សូភាព គឺជាអ្នកបញ្ចូល,២) ភោគ ឆាយ អតីតលេខាធិការទូទៅក្រសួងការបរទេស អង្គការចាប់ខ្លួន, ៣)ប៉ុក កាណែល អតីតនិស្សិត បច្ចុប្បន្ន(ឆ្នាំ១៩៧៨)ក្តាប់មិនបាន។ ចំណែកខ្សែទាក់ទងមាន ប៉ុក កាណែល នៅខាងសាលាភ្នំពេញជិតចំណតរថភ្លើង,ភោគគី ហៅ សាយ អតីតនិស្សិត បច្ចុប្បន្ន(ឆ្នាំ១៩៧៨) អង្គការចាប់,វ៉ាន់ពីនី អតីតនិស្សិតសាលាច្បាប់ភ្នំពេញ ជិតក្បាលថ្នល់។ អ៊ុន សូភាព ហៅ មី សាលាមហាវិទ្យាល័យវិទ្យាសាស្ត្រភ្នំពេញជិតវិមានឯករាជ្យ។ ក្រោយពីបានស្គាល់ខ្សែនេះហើយខ្ញុំក៏បានទាក់ទងខាងសាលាពេទ្យតាមរយៈ ប៉ុក កាណែល ខ្ញុំបានស្គាល់ តាន់លី គឺជាអតីតនិស្សិត,ចៅ ទ្រី, ទួន សុខផល្លា ហៅ គៀន ផ្នែកសំណង់ដឹកជញ្ជូនជើងទឹក, ឈុន សុខងួន ហៅ សោម បច្ចុប្បន្ន(១៩៧៨)អង្គការចាប់។

នៅខែធ្នូ ឆ្នាំ១៩៦៥ ខ្ញុំបន្តទៅរៀននៅប្រទេសបារាំង។ តាមការណែនាំរបស់ ភោគ ឆាយ ទៅជួប អ៊ុន សូភាព សរសេរសំបុត្រឱ្យខ្ញុំភ្ជាប់ខ្សែជាមួយ តូច ខាំឿន (បច្ចុប្បន្នឆ្នាំ១៩៧៨) អង្គការចាប់ខ្លួន។ ខ្ញុំទៅដល់ស្រុកបារាំងក្រោយពីភ្ជាប់ខ្សែ តូច ខាំឿន និងបានប្រាប់ខ្សែនៅប៉ារីស និងផែនការៈ ឃោសនាមួលបង្កាច់ខ្មែរក្រហមជាអ្នកបង្កសង្គ្រាមនៅកម្ពុជា, រារាំងអ្នករៀនចប់ កុំឱ្យចូលស្រុក និង កសាងកម្លាំងក្បត់។

នៅឆ្នាំ១៩៦៦ ខ្ញុំចូលរៀនសាលាទូរគមនាគមន៍ ហើយខ្ញុំបានសហការជាមួយ នុត គឹមឡេងប៊ុនថា ហៅ គង់ កសាងកម្លាំងបានពីរនាក់គឺឈ្មោះ ទេព សំអាង និង ជា សារ៉ន។ ទេព សំអាង អតីតក្រសួងខុសរ្រាហកម្មចូលស្រុកឆ្នាំ១៩៦៦ ចំណែក ជា សារ៉ន អតីតបុគ្គលិកក្រសួងកសិកម្មចូលស្រុកឆ្នាំ១៩៦៧។ ពួកគេទាំងពីរនាក់នេះចូលរួមសកម្មភាពឃោសនាមួលបង្កាច់ខ្មែរក្រហមថា ជាអ្នកបង្កហេតុក្នុងរឿងនៅតំបន់សំឡូតក្នុងឆ្នាំ១៩៦៧ ទាំងក្នុងចំណោមខ្មែរ និងចំណោមបរទេស។ តាមរយៈនេះបានអូសទាញកសាងកម្លាំងក្នុងចំណោមអ្នករដ្ឋការមកដល់ថ្មីនិងនិស្សិតមកដល់ថ្មីដែលជាកូនទាយ ទុននិងអនុធនថ្នាក់លើ។ ចំពោះអ្នករដ្ឋការសហការជាមួយ នុត គឹមឡេងប៊ុនថា ហៅ គង់ កសាងបានៈ ១)រិត សាអ៊ុត អតីតបុគ្គលិកក្រសួងខុសរ្រាហកម្ម ចូលស្រុកក្នុងឆ្នាំ១៩៦៧។ ឃិន ពុំមិការ ហៅ វ៉ៃន អតីតនិស្សិតចូលក្នុងប្រទេស ខែកក្កដា ឆ្នាំ១៩៧៣។ ក្រោយមកសហការជាមួយ ឃិនពុំមិការ ហៅ វ៉ៃនកសាងកម្លាំងបងប្អូនបានចំនួន៣នាក់ទៀតៈ តាន់វិច្ឆិកា អតីតនិស្សិតនៅសហករណ៍តាឡី,កែ គឹមសែ ហៅ ជាសែ អតីតនិស្សិតនៅសហករណ៍តាឡី និង ឆាយ ប៊ុនថៃ ហៅ ឆាយ អតីតនិស្សិតក្តាប់មិនបាន។ ក្រោយមកពួកខ្ញុំ៤នាក់កសាងបានកម្លាំងម្នាក់ ឈ្មោះ តាន់ ប៉េង ឃុន អតីតនិស្សិតនៅសហករណ៍តាឡី។

នៅខែសីហា ឆ្នាំ១៩៦៨ អ៊ុន សូភាព ហៅ មី ត្រឡប់មកពីរៀននៅស្រុកបារាំង។ នៅផ្ទះដែល អ៊ុន សូភាព រស់នៅបានឱ្យខ្ញុំស្គាល់នារីម្នាក់ឈ្មោះ សូហ៊ីយ៉ា គឺជាអ្នករកស៊ីនៅស្រុកបារាំង, ហូរ៉ សេត សោម អតីតនិស្សិតវិស្វករចម្រាញ់ប្រេងកាតចូលក្នុងស្រុកឆ្នាំ១៩៦៩ និងអ៊ុនសូផនអតីតនិស្សិតនៅសហករណ៍តាឡី។ នៅខែមិថុនា ឆ្នាំ១៩៦៩ ខ្ញុំឈប់រៀនខាងទូរគមនាគមន៍។ ឆ្នាំ១៩៧០ក្រោយរដ្ឋប្រហារភ្លាម សម្តេចព្រះ នរោត្តម សីហនុ បានប្រកាសបង្កើតរណសិរ្សនៅប៉េកាំង។ តូច ខាំឿន និង អ៊ុន សូភាព ហៅ មី ចាត់តាំងខ្ញុំឱ្យទៅបង្កប់នៅក្នុងរណសិរ្សប៉េកាំង ដោយភ្ជាប់ទៅនឹងខ្សែ សារិន ឆាក។ អ៊ុន សូភាព បាននាំខ្ញុំទៅជួប វ៉ាន់ ពីនី គឺជាខ្សែរបស់សារិន ឆាក។

ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧០ ខ្ញុំទៅដល់



សិស្សសាលាបច្ចេកទេស ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប៉េកាំង។ ក្រោយពីបានទាក់ទងតាម ហ៊ាន់ ពីនី ហើយខ្ញុំក៏ទៅជួប សារិន ឆាក ហើយ សារិន ឆាក បានដឹងថាខ្ញុំភ្ជាប់ខ្សែពីប៉ារីសមក។ សារិន ឆាត បានលើកឡើងពីភារកិច្ចនិងផែនការ សេ-អ៊ុ-អា នៅប៉េកាំង។ ភារកិច្ចរបស់យើងគឺរារាំងកុំឱ្យខ្មែរក្រហម ឈ្នះទាំង១០០ភាគរយបានន័យថាត្រូវឱ្យសង្គ្រាមបញ្ចប់ដោយការចរចា។ ខ្សែទាក់ទងនៅប៉ារីសមាន ហ៊ិណាំហុង បុគ្គលិកទូតនៅប៉ារីស ក្រោយមកទៅសហករណ៍ភូមិភាគពាយ័ព្យ។ នៅប៉េកាំងមាន ចាន់យូរ៉ាន់ អតីតទូត នៅសេនេកាល់ បច្ចុប្បន្ន(១៩៧៨) ជំនួយការនៅក្រសួងការបរទេស។ ហាន់ ម៉ាត់ និស្សិតមកពីគែរ ក្រោយមកសុំត្រឡប់ទៅវិញ ព្រោះបញ្ហាមិនហូបសាច់ជ្រូក។ ចំណែកខ្សែខាងគែរ មានឈ្មោះ ចែម ស្នួន ទីប្រឹក្សាទូតនៅគែរ ក្រោយមកជាទូតនៅអាល់សេរី។

ឆ្នាំ១៩៧២ អង្គការប្រកាសហៅ យុវជន នៅបរទេសទាំងអស់ឱ្យចូលក្នុងប្រទេស។ សារិន ឆាក បានហៅ ចាន់យូរ៉ាន់,ហ៊ាន់ ពីនី និងខ្ញុំមកប្រជុំដាក់ផែនការដើម្បីទប់ទល់នឹងវិធានការនេះ។ សារិន ឆាក បានហៅ ចាន់យូរ៉ាន់,ហ៊ាន់ ពិនី និងខ្ញុំមកប្រជុំដាក់ផែនការដើម្បីទប់ទល់នឹងហេតុការណ៍នេះ។ ផែនការដាក់ចុះមាន៖ ឃោសនាថាការងារនៅក្រៅប្រទេសមានច្រើនណាស់ខ្វះតែមនុស្ស,បើកទូតថ្មីនឹងពង្រឹងទូតដែលមានដើម្បីស្រូបយកយុវជន,បំផុសឱ្យយុវជនសូមបន្តរៀនសូត្រនៅប្រទេសកូរ៉េ និង ប្រទេសរ៉ូម៉ានីប៊ុចិន។ ក្នុងការទប់ទល់ជាមួយឃោសនាការមិនឱ្យចូលមកក្នុងប្រទេសនេះខ្ញុំសហការជាមួយឈ្មោះ បានយ៉ា អ៊ូស ទាញបាន គង់សារីម អតីតនិស្សិតនៅប្រទេសកូរ៉េ។ ដើម្បីបើកទូតថ្មីនិងពង្រឹងទូតចាស់ដែលមានស្រាប់ ហើយ សារិន ឆាក បានហៅខ្សែរបស់ខ្លួនដែលនៅក្រៅឱ្យចូលមកប៉េកាំងដើម្បីត្រៀមចេញ។ពេលនោះបានឱ្យខ្ញុំស្គាល់ថៅងគិមស្រ៊ុន

អតីតស័ក្តិ៤ ពេទ្យទាហាន បច្ចុប្បន្ន(១៩៧៨) ជំនួយការនៅក្រសួងការបរទេស ត្រៀមធ្វើទូតនៅតង់សានី, នូប៊ិច អតីតស័ក្តិ៤កន្លះ ពេទ្យទាហាន បច្ចុប្បន្ន(១៩៧៨)អង្គការចាប់ ត្រៀមខ្លួនធ្វើទូតនៅគែរ, សួវគិមហុង អតីតនិស្សិត ត្រៀមធ្វើទូតនៅប្រទេសកុងហ្គោ។

ខែសីហា ឆ្នាំ១៩៧៣ សង្គ្រាមអាកាសអាមេរិកក៏ត្រូវបញ្ឈប់ទៀត។ ចលនាចូលក្នុងប្រទេសចេះតែប្រព្រឹត្តទៅជាបន្តបន្ទាប់។ ខែវិច្ឆិកា ឆ្នាំ១៩៧៣ ក្រុមសេ-អ៊ី-អា សម្រេចបញ្ចូលខ្ញុំនិង អ៊ិន សុភាព ហៅ មី ចូលទៅបង្កប់ខ្លួនក្នុងប្រទេស។ ថ្ងៃទី៩ ខែវិច្ឆិកា ក្នុងដំណើរចូលប្រទេស បងអៀង សារី បានយកខ្ញុំនិង អ៊ិនសុភាព ហៅ មី និងម្នាក់ទៀតឈ្មោះ សៀង ហួរ ឡុង អតីតនិស្សិតនៅអាល្លឺម៉ង់ ចូលក្នុងស្រុក នៅខែមិថុនា បច្ចុប្បន្ន(១៩៧៧)បាត់ខ្លួនពីក្រសួងការបរទេស។ លុះទៅដល់ហាណូយ ក្រោយពីនៅទីក្រុងបានរយៈពេល៣ថ្ងៃ បងអៀងសារី បានប្រាប់ឱ្យស្គាល់បក្សកុម្មុយនីស្តកម្ពុជា រួចនាំឱ្យទៅនៅក្នុងមន្ទីរសម្ងាត់របស់បក្សនៅជាយក្រុងហាណូយ ហើយក្រោយមកតម្រូវឱ្យពួកខ្ញុំទាំង៣នាក់នៅក្នុងមន្ទីរសម្ងាត់នេះមួយរយៈសិនមុននឹងចូលក្នុងប្រទេស។ ចាប់ពីខែធ្នូ ឆ្នាំ១៩៧៣ មកខ្ញុំនៅក្នុងមន្ទីរសម្ងាត់ថ្មីនេះដែលមានឈ្មោះហៅថាក្រសួង សេតេ៧០ គឺជាវិទ្យុផ្សាយសំឡេងរណសិរ្សទៅក្នុងប្រទេស។ មានបងភា បងអៀង ធិរិទ្ធ គឺជាប្រធានគណៈក្រសួងសង្គមកិច្ច។ ការងារបែកចេញជាពីរផ្នែកគឺខាងបច្ចេកទេសជាងម៉ាស៊ីន និង យួនចាំទទួលធ្វើឱ្យដំណើរការ។ ខែមិថុនា ឆ្នាំ១៩៧៤ គណៈប្រតិភូមានបងខៀវ សំផន និង បងអៀង សារី ដឹកនាំទៅទស្សនកិច្ចនៅក្រៅប្រទេសត្រូវត្រឡប់ចូលស្រុកវិញ។

ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៥ ចាប់ផ្ដើមវគ្គវាយសម្រុកទូទាំងប្រទេស បងប្រធានក្រសួងបានហៅទៅជួបប្រាប់ព័ត៌មាន។ នៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥ អ្នកលឿងត្រូវបានរំដោះ ហើយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភ្នំពេញ ត្រូវបានរំដោះទាំងស្រុង។ ថ្ងៃទី២៣ ខែមេសា វិទ្យុភ្នំពេញតាមផ្សាយជាខ្សែសង្វាក់ ចំណែកវិទ្យុនៅហាណូយត្រូវឈប់ដំណើរការ ហើយសមាជិកក្រសួងទាំងអស់រង់ចាំតែពេលវេលាដើម្បីចូលមកក្នុងប្រទេសវិញ។ ថ្ងៃទី១២ ខែឧសភា ខ្ញុំចេញពីហាណូយមកក្នុងប្រទេស ហើយថ្ងៃទី១៨ ខែឧសភា បានទៅដល់មន្ទីរប២០ ស្ទឹងត្រង់។ ខ្ញុំនៅបានរយៈពេល៤ថ្ងៃក៏អង្គការបញ្ជូនខ្ញុំ,កោប៊ិនហេង ហៅ ខុន, យ៉ែមយ៉ន ហៅ ខន, ហ៊ិនស៊ា ហៅ ខឹម និង ស៊ិន ជណ្ណា ហៅ ខាន់ឱ្យទៅនៅតំបន់ព្រះវិហារ។ ថ្ងៃទី២៣ ខែឧសភា ខ្ញុំបានទៅដល់ឃុំស្រែកណ្ដាល ស្រុករវៀង ខេត្តព្រះវិហារ។ ស្អែកឡើងអនុប្រធានឃុំបានមកចែកគ្នាពង្រាយតាមភូមិក្នុងឃុំស្រែកណ្ដាល ខ្ញុំនិង ស៊ិន ជណ្ណា ហៅ ខាត់ នៅភូមិរវៀងជើង, យ៉ែម យ៉ក់សាន ហៅ ខន និង ហ៊ិនស៊ា ហៅ ខឹម នៅភូមិរវៀងត្បូងហើយ កោប៊ិនហេង ហៅ ខុន នៅភូមិថ្នល់កែង។ ខ្ញុំធ្វើការតាមពួក និងដេកនៅស្រែរយៈពេលមួយអាទិត្យទើបចូលភូមិម្ដង។ ប្រធានពួកខ្ញុំឈ្មោះ ព្រី អតីតជាងមាស,ឈ្មោះស៊ឹង,តាង៉ាន,រុន និង ឡឿក។ រយៈពេលដែលខ្ញុំទៅខេត្តព្រះវិហារខ្ញុំកសាងកម្លាំងបានថ្មី និង បំផ្លាញស្រូវទុំ។ នៅចុងខែធ្នូ អង្គការហៅខ្ញុំមកភ្នំពេញវិញ។

នៅខែមករា ឆ្នាំ១៩៧៦ ខ្ញុំចូលមកនៅក្នុងមន្ទីរក២ ក្រសួងសង្គមកិច្ចជាមួយឈ្មោះ យ៉ែម យ៉ក់សាន ហៅ ខន។ រយៈពេល២ថ្ងៃក្រោយមក ខ្ញុំទៅរៀនវគ្គនយោបាយជាមួយ បងខៀវ សំផន អស់រយៈពេល១ខែ។ បន្ទាប់ពីរៀនចប់អង្គការឱ្យខ្ញុំដើរកត់ស្ថិតិរោងចក្រធ្វើថ្នាំពេទ្យដែលមាននៅភ្នំពេញ។ នៅខែមីនា អង្គការឱ្យខ្ញុំមករៀនខាងម៉ាស៊ីនធ្វើថ្នាំនៅ ជ១។ ពេលនោះខ្ញុំបានស្គាល់ឈ្មោះ កុល អតីតសិស្សថ្នាក់ទី៧ គឺជាប្រធានរោងចក្រ។ រយៈពេល២ថ្ងៃក្រោយមក ហុង មកជ១ហើយបានណែនាំខ្ញុំឱ្យស្គាល់ កុលគឺជាខ្មែរ សេ-អ៊ី-អា។ ខែមេសា ខ្ញុំត្រឡប់មករៀបចំរោងចក្រជ៤វិញ។ អង្គការបានរៀបចំគណៈបណ្ដោះអាសន្នមួយមាន

ណាត គឺជានារី អតីតគ្រូបង្រៀនជាប្រធាន និងខ្ញុំគឺជាអនុប្រធាន ទទួលខាងបច្ចេកទេស, ផេង សមាជិក និង អ៊ាន អតីតលោកសង្ឃ ជាសមាជិក។ ខ្ញុំនិងផេងបានជួបគ្នាដាក់ផែនការៈ ពេលរៀបចំរោងចក្របំផ្លាញរោងចក្រ, ធ្វើឱ្យក្រៀវថ្នាំងថ្នាក់ និងកសាងកម្លាំង។

ខែមករា ឆ្នាំ១៩៧៧ បងប្រធានក្រសួងបានឱ្យមន្ទីរ ទាំងអស់ត្រៀមរាយការណ៍និងធ្វើផែនការប្រចាំឆ្នាំសម្រាប់សន្និបាត។ ក្រុម សេ-អ៊ី-អា នៅដ៤ដាក់ផែនការឱ្យម៉ាស៊ីនដើរឱ្យខ្លាំងឱ្យដំណើរការលែងបាននៅដាច់ឆ្នាំ១៩៧៧។ ខ្ញុំទទួលដាក់ទូរលេខឱ្យឃើញសម្បើមតែលើសកម្លាំងរបស់ម៉ាស៊ីន តួរលេខនេះក៏បានឆ្លងឱ្យសន្និបាតអនុវត្ត។ នៅខែកុម្ភៈ ណាត ផ្លាស់ចេញទៅ ៣១៧ នារីប៉ក់ចូលថ្មីជំនួស។ យប់មុនចេញទៅ ណាត ហៅខ្ញុំនិងហៀក ជួបគ្នាប្រាប់សភាពការណ៍គឺ ប៉ក់ គឺជាខ្សែ សេ-អ៊ី-អា របស់ឡេង ស៊ីមហាក់ ហៅ សី, ខ្ញុំ និងហៀក។ ស្អែកឡើង នារី ប៉ក់ ហៅខ្ញុំនិងហៀក មកប្រជុំគ្នាដើម្បីក្តាប់សភាពការណ៍ ដាក់ផែនការ ឱ្យម៉ាស៊ីនខូចបន្តិចម្តងៗ រហូតដល់ចុងឆ្នាំ១៩៧៧ ដំណើរការលែងបាន,បំភ្លៃមាគ៌ាលើកស្ទួយជីវភាពប្រជាជន, កសាងកម្លាំង សេ-អ៊ី-អា។ នៅខែមីនា អង្គការនាំទន្សាយ និង កណ្តុរពីក្រៅមួយមុខៗ ចំនួន២០០ក្បាលមកប្រគល់ឱ្យដ៤ ទទួលចិញ្ចឹមទាំងអស់។ ដោយសារទន្សាយ និងកណ្តុរ ទាំងនោះធ្លាប់នៅអាកាសធាតុត្រជាក់ ការទុកដាក់ទាមទារបន្ទប់ត្រជាក់ ឱ្យមាននំក្រៀម ម្សៅ ទឹកដោះគោឱ្យវាស៊ីទៀត។ ដោយសារសត្វទាំងនេះយកមកពីចិន ដូច្នេះការថែរក្សា ទាក់ទងដល់នយោបាយជាមួយភ្ញៀវ ដែលមកធ្វើការជាមួយ។ នារី ប៉ក់ ខ្ញុំ និង ហៀក ក៏ប្រជុំគ្នាដាក់ផែនការថែទាំងទន្សាយតែល្មមៗបានហើយ ទុកឱ្យប៉ះពាល់ខ្លះដល់នយោបាយជាមួយភ្ញៀវ។ នៅខែមីនា នេះបានបណ្តោយឱ្យទន្សាយងាប់អស់ជាង២០ក្បាល។ នៅក្នុងខែមីនា នេះក៏មានការធ្វើសន្និបាតប្រចាំត្រីមាសនៅមន្ទីរក២។ ពេលនោះខ្ញុំនិង នារីប៉ក់បានជួបជាមួយ សី នៅ៣១៧។ នៅខែកក្កដា ឆ្នាំ១៩៧៧ អង្គការចាប់ សី និងបក្សពួកនៅ៣១៧។ ក្រោយពីមានសភាពការណ៍ថ្មី ប៉ក់ ហៅខ្ញុំ និង ហៀក មកធ្វើការលើកផែនការថ្មីគឺបំផ្លាញម៉ាស៊ីននៅចុងឆ្នាំ១៩៧៧, រារាំងការធ្វើថ្នាំគីនីនចាក់ ដើម្បីព្យាបាលសន្ធំ និង កសាងកម្លាំង។ ខែសីហា ម៉ុក សំអុល ហៅ ហុង ត្រូវអង្គការដកចេញពីសង្គមកិច្ច សភាពការណ៍នៅរោងចក្រដ៤ ខាងម៉ាស៊ីនវាយគ្រាប់ថ្នាំនៅតែមិនដំណើរការ អង្គការមានការបារម្ភ។ ខាងធ្វើគីនីន អាស៊ីតអាសេទិចជិតអស់មែនទែនហើយ ត្រូវទៅរកខាងឧស្សាហកម្ម តែឧស្សាហកម្មរកឱ្យមិនបាន។ គម្រោងធ្វើមួយលានអំពូលបានតែពីរសែនអំពូល។ បើអស់អាស៊ីតត្រូវប៉ះពាល់ដល់នយោបាយ ខាងមន្ទីរក២ទៀត ដែលជាអ្នកឧបត្ថម្ភរួមគ្រប់វត្ថុធាតុដើមសម្រាប់ក្រសួង។ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ខ្ញុំចេញពី ដ៤ ទៅនៅក២វិញ។ ខ្ញុំទៅធ្វើការជាជំនួយបច្ចេកទេសក្នុងក្រុមមានសមាជិក៣នាក់ហើយប្រធានក្រុមគឺជាអ្នកការពារ បងភា។

នៅខែមករា ឆ្នាំ១៩៧៨ យួនចាប់វាយនៅទល់ដែនខ្លាំង និងទ្រង់ទ្រាយធំ ដូច្នេះខាងសមរភូមិក្រោយត្រូវការផ្គត់ផ្គង់ថ្នាំសង្កូវ ពិសេសសេរ៉ូមឱ្យទាន់ពេលវេលា តែខាងរោងចក្រមានបញ្ហាផ្លូកគម្រប។ នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៧៨ អង្គការចាប់ខ្ញុំមានមិត្ត ឡោ ផុន អ្នកសួរចម្លើយ។

កំណត់ចំណាំៈ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារJ០០១៣៦។ រាល់ចម្លើយសារភាពរបស់អ្នកទោស ទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ ប៉ែនវ៉ាន់សែ ហៅ សែ ហៅ តែល ពិតប្លុយ៉ាងណានោះទេ?

# ស្ងួន ការសេត្រ អគ្គនាយកទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម ក្នុងរបប លន់ នល់

*មីន សាណាស់*



ប្រព័ន្ធប្រឡាយទឹក ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឯកសារប្រវត្តិរូបសង្ខេបI០៨៣៦២ និងចម្លើយសារភាពពីផ្នែកសន្តិសុខមន្ទីរស-២១ ដែលមានលេខសម្គាល់D៤១៧៨០ ក្នុងទំព័រដំបូងបានបង្ហាញពីតួនាទីរបស់ឈ្មោះ ស្ងួន ការសេត្រ រៀនចប់ផ្នែកវិស្វករក្សេត្រកម្ម នៃក្រុងសិបប្ល៊ូ ប្រទេសប៊ែលហ្សិក (១៩៥៥-១៩៦០) និងជាអគ្គនាយកទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម នៃរបបសាធារណៈរដ្ឋខ្មែរ ឬរបប លន់ លន់ ចន្លោះឆ្នាំ១៩៧២-១៩៧៥។ ស្ងួន ការសេត្រ ត្រូវបានអង្គការឃាត់ខ្លួននៅចំណុចភូមិទួលទ្រា ឃុំព្រែកក្មេង ស្រុកល្វាឯម តំបន់២២ ត្រូវនឹងថ្ងៃទី២៥ ខែតុលា ឆ្នាំ២៩៧៥ និងបញ្ជូនមកកាន់មន្ទីរស-២១ ទួលស្លែង។ ចំណែកឯកសារបទសម្ភាសន៍ ស្ងួន ឆេន ដែលមានលេខសម្គាល់ BBI០០៣២ បានរៀបរាប់ថា ស្ងួន ការសេត្រ បានត្រឡប់មកពីប្រទេសបារាំងវិញ តាមការអំពាវនាវពីខ្មែរក្រហមឱ្យមកជួបជាមួយ អៀង សារី ក្នុងគោលបំណងកសាងប្រទេសជាតិ។

ខាងក្រោមនេះជាចម្លើយសារភាពរបស់ សួន កាសេត្រ ជាប់ឃុំឃាំងក្នុងមន្ទីរ ស-២១៖

សួន កាសេត្រ ហៅ សេត អាយុ៤១ឆ្នាំ(១៩៧៥) មានស្រុកកំណើតនៅភូមិវត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង។ សេត មានឪពុកឈ្មោះ សួន ស៊ីង អាយុ៦៨ឆ្នាំ(១៩៧៥) កើតនៅភូមិវត្តសំពៅ ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង និងម្តាយឈ្មោះ ដែង ឆៅ អាយុ៦២ឆ្នាំ(១៩៧៥) កើតនៅភូមិវត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង។ ឪពុកម្តាយរបស់ សេត គឺជាកសិករធ្វើស្រែនិងចម្ការ។ ក្នុងឯកសារបទសម្ភាសន៍របស់ប្អូន សេត បានបញ្ជាក់ថា សេត មានបងប្អូន៤នាក់ ក្នុងនោះមានស្រី២នាក់។ សេត ជាកូនច្បងក្នុងគ្រួសារ និងមានប្អូនស្រីបន្ទាប់ឈ្មោះ សួន ឆេន (រស់នៅខេត្តបាត់ដំបង), សួន សុឆាត (រស់នៅប្រទេសបារាំង) និង ប្អូនប្រុសឈ្មោះ សួន ប្រាក់សុង (ស្លាប់ក្នុងរបបខ្មែរក្រហម)។ សេត មានប្រពន្ធឈ្មោះ ស៊ុយ សុខូម៉ាលី ហៅ ម៉ី អាយុ៣៣ឆ្នាំ (១៩៧៥) ក្រោយរៀបការ ប្តូរមកដាក់ត្រកូល សួន សុខូម៉ាលី កើតនៅសង្កាត់លេខ៣ ក្រុងភ្នំពេញ។ សួន សុខូម៉ាលី រៀនសូត្របានកម្រិតវប្បធម៌ សញ្ញាបត្រសាស្ត្រាចារ្យមធ្យមសិក្សាផ្នែកទី១ ខាងភាសាអង់គ្លេស។ ក្រោយរៀបការ សេត និង ប្រពន្ធមានកូនចំនួន៣នាក់ ក្នុងនោះកូនស្រី២នាក់។ ប្រពន្ធរបស់ សេត មានឪពុកឈ្មោះ ស៊ុយ បេង មានតួនាទីជាមេព្រៃ និង ម្តាយឈ្មោះ មាសកេតុ សុជាតិ។ ខែកុម្ភៈ ឆ្នាំ១៩៧៥ សេត បានបញ្ជូនប្រពន្ធកូន និង ប្អូនស្រី(សួន សុឆាត) ឱ្យទៅរស់នៅប្រទេសបារាំង មុនពេលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ មូលហេតុដែល សេត មិនចាកចេញពីទីក្រុងភ្នំពេញជាមួយប្រពន្ធកូន ព្រោះមិនជឿថាស្រុកខ្មែរប្រកាន់យករបបកុម្មុយនីស្ត។

រំឭកកាលពីកុមារភាពរបស់ សេត ក្នុងឆ្នាំ១៩៤០ បានចូលរៀនកុមារដ្ឋាននៅសាលាបឋមសិក្សាវត្តកំផែងខេត្តបាត់ដំបង។ ចន្លោះពីឆ្នាំ១៩៤០-១៩៤៦ ក៏បន្តការសិក្សានៅមធ្យមសិក្សាស្ថិតក្នុងវត្តសំពៅ និងវត្តពិភិទ្ធ ពីថ្នាក់បឋមឆ្នាំទី១ ដល់ថ្នាក់មធ្យមឆ្នាំទី៣ ដែលមានរដ្ឋាភិបាលសៀមជាអ្នកត្រួតត្រាខេត្តបាត់ដំបងនៅកំឡុងពេលមុន និង ក្នុងចម្បាំងលោកលើកទី២។ ឆ្នាំ១៩៤៦-១៩៤៧ សេត បានបន្តការសិក្សាមធ្យមឆ្នាំទី៤ នៅក្រុងបាងកក ប្រទេសសៀម។ ឆ្នាំ១៩៤៨ ត្រឡប់មកស្រុកកំណើតវិញ ដើម្បីចូលរៀនថ្នាក់ទី៧ នៅសាលាបឋមសិក្សាកណ្តាល ព្រមទាំងប្រឡងជាប់សញ្ញាបត្របឋមសិក្សា។ ចន្លោះឆ្នាំ១៩៤៨-១៩៥២ ចូលរៀននៅអនុវិទ្យាល័យបាត់ដំបងពីថ្នាក់ទី៦ដល់ថ្នាក់ទី៣ និងប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាផ្នែកទី១ រួចបន្តឡើងមករៀននៅវិទ្យាល័យ ស៊ីសុវត្ថិ ឯទីក្រុងភ្នំពេញពីថ្នាក់ទី២ ដល់ថ្នាក់ទីបញ្ចប់ផ្នែកគណិតសាស្ត្រក្នុងឆ្នាំ១៩៥៥។ ពីឆ្នាំ១៩៥៥-១៩៦០ ដោយសារការឧស្សាហ៍ និង ពូកែរៀនសូត្រ សេត ក៏ជាប់អាហារូបករណ៍ទៅសិក្សាបន្តនៅវិទ្យាស្ថានជាតិក្សេត្រសាស្ត្រ ជាប់សញ្ញាបត្រវិស្វករក្សេត្រកម្ម គង្គារុក្ខា នៃក្រុងសិបប៊្លូ ប្រទេសបែលហ្សិក។

ក្រោយពីបញ្ចប់ថ្នាក់សញ្ញាបត្រវិស្វករក្សេត្រកម្មរួច សេត ក៏ត្រឡប់មកប្រទេសកំណើតវិញ និង ក្នុងឆ្នាំ១៩៦១-១៩៦២ បានចូលធ្វើការ ជាអ្នកទទួលបន្ទុកអធិការដ្ឋានផ្នែកបច្ចេកទេសនៃទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម។ ឆ្នាំ១៩៦២-១៩៦៤ ផ្លាស់ទីជាអ្នកទទួលបន្ទុកវិទ្យាស្ថានផ្នែករិះរកវិទ្យាសាស្ត្រខាងព្រៃឈើ។ ឆ្នាំ១៩៦៤-១៩៦៧ ជានាយករងផ្នែកបច្ចេកទេសនៃក្រុមគង្គារុក្ខាប្រមាញ់។ ឆ្នាំ១៩៦៧-១៩៦៨ ជាប្រធានអគ្គនាយកក្រុមហ៊ុនជាតិផ្នែកអាជីវកម្មព្រៃឈើ នៅកំពង់សោម។ ឆ្នាំ១៩៦៨-១៩៧១ ដូរមកជានាយកនៅក្រុមគង្គារុក្ខា និងប្រមាញ់។ ចូលមកជំនាន់ លន់ នល់ ឆ្នាំ១៩៧១-១៩៧២ ជានាយកផ្នែកស្ថិតិសេដ្ឋកិច្ច និង ផែនការនៃទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម។ និងឆ្នាំ១៩៧២-ដល់ថ្ងៃរំដោះ ទី១៧ ខែមេសា ឆ្នាំ១៩៧៥ មានតួនាទីជាអគ្គនាយកនៃទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម។ ស្ថិតក្នុងអំឡុងបម្រើការងារក្នុងរដ្ឋការ និង ក្រុមហ៊ុន

ឯកជន សេត ជាមនុស្សមានចរិតស្លូតត្រង់ ជាហេតុនាំឱ្យកូនចៅស្រឡាញ់រាប់អានជាច្រើន។

ក្រោយថ្ងៃរំដោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សេត ត្រូវខ្មែរក្រហមជម្លៀសឱ្យទៅរស់នៅភូមិទួលទ្រា ឃុំព្រែកក្មេង ស្រុកល្វាឯម ខេត្តកណ្ដាល។ ដល់ពាក់កណ្ដាលខែកក្កដា ឆ្នាំ១៩៧៥ ក៏មានការជួបប្រជុំពិភាក្សា មានអ្នកចូលរួមដូចជាឈ្មោះ ហ៊ីង គុណថុន អតីតប្រធានអគ្គនាយកធនាគារខ្មែរពាណិជ្ជកម្ម, អ៊ូ វិនឌី អតីតធ្វើការនៅក្រសួងការបរទេស, លឹម គីម៉ារី អតីតនាយកក្រសួងធនាគារខ្មែរសម្រាប់ពាណិជ្ជកម្ម និងប្រពន្ធឈ្មោះ ជូ ឡុង រាំងស៊ី, កា សុំ អតីតមេឃ្លាំងនៅតាខ្មៅ ខេត្តកណ្ដាល និងប្រពន្ធឈ្មោះ ថន, ប៉ែន ប៊ុន ជាពេទ្យនៅក្រុមទេពកោសល្យជនបទ, ចន្ទ អតីតជាប្ញង់តុងនៅធនាគារខ្មែរពាណិជ្ជកម្ម។ ការប្រជុំនេះលើកពីការធ្វើដំណើររបស់ ខៀវ សំផន និង អៀង សារី ទៅកាន់ប្រទេសចិន ដែលគ្រប់គ្នាក្នុងប្រជុំមិនដឹងពីគោលបំណងនៃការធ្វើដំណើរ។ ចំណែក ហ៊ីង គុណថុន មានយោបល់ថា «ចិនអញ្ជើញ ខៀវ សំផន ទៅប្រាកដជាចង់បង្ហាញឱ្យពិភពលោកបានឃើញ និងចង់ឱ្យសម្ដេចព្រះ នរោត្ដម សីហនុ បានដឹងខ្លួនថា ចិនគាំទ្រ ខៀវ សំផន និងមាននយោបាយចង់ឱ្យ ខៀវ សំផន ជាអ្នកកាន់ចង្កូតរបស់រដ្ឋ មិនមែនជាសម្ដេចព្រះ នរោត្ដម សីហនុ ដែលគ្រប់គ្នាស្មាននោះឡើយ។ ហេតុនេះ ចិន និងទទួល ខៀវ សំផន យ៉ាងអធិកអធម ឱ្យសមនឹងឋានៈជាប្រមុខរដ្ឋ»។ បន្ថែមពីនេះ ហ៊ីង គុណថុន បាននិយាយបង្ហាញអារម្មណ៍អស់សង្ឃឹមថា អំពីកងទ័ពរំដោះហៅអតីតអ្នកធ្លាប់ធ្វើការរដ្ឋការឱ្យចូលទីក្រុងភ្នំពេញវិញក្នុងពេលឆាប់ៗនេះ។ សេត បានតបទៅ ហ៊ីង គុណថុន វិញថា «តាមគំនិតខ្ញុំ ខៀវ សំផន ប្រហែលជាទៅទាក់ទងជាមួយសម្ដេចព្រះ នរោត្ដម សីហនុ ឱ្យត្រឡប់មកស្រុកខ្មែរវិញ ទោះបីជាយ៉ាងណាក៏ដោយចិនមិនអាចបោះបង់ចោលសម្ដេចនរោត្ដមសីហនុ នោះទេ ដើម្បីជៀសវាងការទិតៀនអំពីប្រទេសអព្យាក្រិត។ ម្យ៉ាងទៀតសម្ដេចព្រះ នរោត្ដម សីហនុ ក៏ចង់តែយាងត្រឡប់មកស្រុកខ្មែរវិញ ដើម្បីចូលស្រុកទេសរបស់ខ្លួន និង ធ្វើបុណ្យជូនសម្ដេចមហាក្សត្រីយានី ស៊ីសុវត្ថិ កុសមៈ»។ ចំពោះ យោបល់ លឹម គីម៉ារី លើកថា «សម្ដេច សីហនុ នឹងត្រឡប់មកស្រុកខ្មែរវិញ ព្រោះតាមហោរាដែល ទាយថាស្រុកខ្មែរមានស្ដេចតទៅទៀត»។ ក្រោយពីការពិភាក្សាចប់ម្នាក់ៗក៏ត្រឡប់ទៅទីតាំងរស់នៅរៀងៗខ្លួន។

ដល់អំឡុងចុងខែសីហា ឆ្នាំ១៩៧៥ ក៏មានការប្រជុំជាលើកទី២ ដែលមានសមាសភាពចូលរួមប្រជុំគឺ សេត, ហ៊ីង គុណថុន, លឹម គីម៉ារី, ស៊ីសុវត្ថិ ដួងដារ៉ា, ជូ ឡុង រាំងស៊ី និង ឈាង គឹមសួរ។ ប្រធានបទនៃការប្រជុំ គឺនិយាយពីការយាងនិវត្តន៍មកកាន់ស្រុកខ្មែរវិញរបស់សម្ដេចព្រះ នរោត្ដម សីហនុ។ ដោយហេតុ ហ៊ីង គុណថុន ចង់វិលត្រឡប់ទៅទីក្រុងភ្នំពេញវិញ និង ចង់ទៅជួបជជែកជាមួយសម្ដេចព្រះ នរោត្ដម សីហនុ ដើម្បីសុំធ្វើការងារក្នុងតំណែងចាស់។ ក្នុងអង្គប្រជុំបានលើកថា តាមការសង្កេតប្រជាជនមូលដ្ឋានក្នុងតំបន់ទួលពង្រ គឺមានភាពជិតស្និទ្ធជាមួយអ្នកភៀសសឹក បើសិនជាមានការពិបាកអ្វីមួយអាចឱ្យប្រជាជនមូលដ្ឋានជួយបាន។ រីឯ ស៊ីសុវត្ថិ ដួងដារ៉ា បានលើកពីករណី កូនស្រីរបស់ខ្លួនដែលកំពុងធ្វើការងារពលកម្មជូនអង្គការ គឺអង្គការប្រដៅឱ្យខំធ្វើការ ទើបបានត្រឡប់ទៅឃើញផ្សារថ្មី។ សេត ឃើញថាម្នាក់ៗមានអាកប្បកិរិយាត្រេកអរជាខ្លាំង ក៏និយាយទប់ស្កាត់កុំឱ្យទាន់រើរវាយ ទោះបីជាយ៉ាងណា ក៏របបថ្មីមិនអាចប្រគល់តួនាទីឬតំណែងចាស់ឱ្យមកម្នាក់ៗវិញទេ។

សេត ក៏ដូចជាប្រជាពលរដ្ឋឯទៀត ដែលត្រូវទៅធ្វើការលើកទំនប់ ជីកប្រឡាយ តែស្ថិតក្នុងពេលធ្វើការ សេត បានបញ្ចេញពាក្យសំដីផ្ទុយនឹងគោលការណ៍អង្គការថា « ការធ្វើការ គ្មានការវាស់ស្ទង់ឱ្យស្រួលប្រួល ការងារបែបនេះ បើសិនជាប្រើម៉ាស៊ីនត្រាក់ទ័រប្រហែលជាឆាប់រហ័សរួចរាល់»។ ជាចុងក្រោយនៃជីវិត សេត ត្រូវចាញ់បោក ការឃោសនារបស់អង្គការខ្មែរក្រហម និងត្រូវចាប់បញ្ជូនមកមន្ទីរឃុំឃាំង ស-២១ វាយធ្វើទារុណកម្មសួរចម្លើយពីខ្សែរយៈគិញមុនពេលសម្លាប់។



*កម្មករកំពុងសាងសង់ស្ថានីយបូមទឹក ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# នួន រឿនៈ អតីតប្រធានកងចល័តវ័យកណ្ដាល

លី វេជវីត



កងចល័តកំពុងជីកប្រឡាយ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នួន រឿន ភេទប្រុស អាយុ៧៥ឆ្នាំ អតីតយុទ្ធជនកងទ័ពរំដោះខ្មែរក្រហម និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ រឿន បច្ចុប្បន្នរស់នៅភូមិគគរ២ ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម បាននិយាយរំឭកអំពីមូលហេតុចូលរួមកងទ័ពរំដោះខ្មែរក្រហម និងជីវិតរស់នៅក្នុងកងចល័ត ក្នុងរបបខ្មែរក្រហម ដូចខាងក្រោមៈ

ខ្ញុំឈ្មោះ នួន រឿន កើតនៅឆ្នាំ១៩៤៧ នៅភូមិគគរ២ ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំរៀបការប្រពន្ធឈ្មោះ ម៉េង ហ៊ាង និងមានកូនប្រុសស្រីទាំងអស់ចំនួន៦នាក់។ ខ្ញុំប្រកបរបរជាកសិករ។ ឪពុករបស់ខ្ញុំឈ្មោះ សួង នួន និងម្ដាយ

ឈ្មោះ អ៊ុង ឈឹម។ ខ្ញុំគឺជាកូនទី៣ក្នុងចំណោមបងប្អូនប្រុសស្រីទាំងអស់ចំនួន១០នាក់។ នៅពេលដែលខ្ញុំមានអាយុ១២ឆ្នាំ ខ្ញុំរៀននៅសាលាបឋមសិក្សានាងអង។ ខ្ញុំរៀនសូត្របានត្រឹមថ្នាក់ទី៩ចាស់។ ក្រោយមកទៀត ខ្ញុំបានបួសរៀននៅវត្តព្រះគ្រូ អ៊ុក បាន៨វស្សា។ ខ្ញុំលាចាកសិក្ខាបទនៅអាយុ១៦ឆ្នាំ។ ខ្ញុំទៅរៀនធ្វើជាងមាសនៅភ្នំពេញ ដោយបានស្នាក់នៅម្តុំផ្សារអូឡាំពិក រហូតដល់ឆ្នាំ១៩៦៨។ នៅឆ្នាំ១៩៦៩ ខ្ញុំបានវិលត្រឡប់មកផ្ទះវិញ និងបើកមុខរបរធ្វើជាជាងមាសនៅផ្ទះតែម្តង។ ខ្ញុំធ្វើមាសយកទៅលក់នៅទីរួមខេត្តកំពង់ចាម ដើម្បីសម្រួលដល់ជីវភាពគ្រួសារ។ នៅឆ្នាំ១៩៧០ ខ្ញុំបានឃើញ អ្នកភូមិជាច្រើនបានចូលរួមដង្ហែបាតុកម្មតាមដងផ្លូវមកពីទិសខាងលិច។ នៅពេលនោះ ខ្ញុំក៏បានចូលរួមដង្ហែក្បួនជាមួយបាតុករផ្សេងៗទៀតទៅដល់សាលាដំបូងខេត្តកំពង់ចាម។ នៅពេលដល់ទីកន្លែងប្រមូលផ្តុំបាតុករនៅទីរួមខេត្ត ខ្ញុំមិនបានឡើងឡានបន្តជាមួយអ្នកផ្សេងទៀត ដែលដង្ហែទៅកាន់ក្រុងភ្នំពេញ។ ខ្ញុំក៏សម្រេចចិត្តវិលត្រឡប់មកភូមិវិញ។ ក្រោយមក ក៏មានការចុះមកប្រមូលយុវជនចូលបម្រើជាទាហានលន់ នល់។ នៅពេលនោះ ខ្ញុំមិនចង់ចូលធ្វើជាទាហាន ក៏បានរត់ចេញពីភូមិទៅនៅស្រុកកោះសូទិន។ ខ្ញុំស្នាក់នៅភូមិពកស្អែងជាមួយបងប្អូនរបស់ខ្ញុំ។ ស្នាក់នៅមិនទាន់បានប៉ុន្មានផង ខ្ញុំឃើញកងទ័ពរំដោះខ្មែរក្រហមចូលមកគ្រប់គ្រងភូមិ។ ខ្ញុំទទួលបានការបញ្ចុះបញ្ចូលឱ្យស្ម័គ្រចិត្តចូលធ្វើជាកងទ័ពរំដោះ។ ដោយមិនមានជម្រើស និងមិនអាចរត់មកភូមិវិញ ដែលមានវត្តមានទាហានលន់ នល់ គ្រប់គ្រង ខ្ញុំក៏ចូលធ្វើជាកងទ័ពរំដោះខ្មែរក្រហមតាំងពីពេលនោះមក។ នៅពេលនោះ មានយុវជនប្រហែល១០០នាក់រួមទាំងរូបខ្ញុំផ្ទាល់ ត្រូវអង្គភាពបញ្ជូនទៅខាងជីហែដែលជាតំបន់រំដោះខ្មែរក្រហម។ បន្ទាប់ពីបានមកដល់ជីហែ យុវជនប្រហែល១០០នាក់ត្រូវបានប្រគល់ឱ្យកងកម្លាំងយៀកកុង ដើម្បីបង្ហាត់បង្រៀនពីក្បួនទ័ពនៅខេត្តព្រៃវែង។ នៅឆ្នាំ១៩៧២ ខ្ញុំត្រូវបានបញ្ជូនទៅហ៊ឹកហ៊ឺនក្បួនទ័ពនៅភូមិឆ្កែកូន ក្នុងខេត្តព្រៃវែង។ ខ្ញុំរៀនក្បួនទ័ព រួមមាន៖ ប្រយុទ្ធរបៀបទប់ទល់ ប្រយុទ្ធរបៀបប្រដេញ និងការប្រើប្រាស់កាំភ្លើងគ្រប់ប្រភេទ។

នៅឆ្នាំ១៩៧៣ ខ្ញុំត្រូវបានបញ្ជូនទៅប្រយុទ្ធនៅសមរភូមិម្តុំកំពង់ត្របែក ខេត្តព្រៃវែង។ ខ្ញុំត្រូវបានបញ្ជូនទៅវាយនៅសមរភូមិជាបន្តបន្ទាប់ទៀត។ នៅឆ្នាំ១៩៧៥ ខ្ញុំបានសុំឈប់ធ្វើជាកងទ័ព ដើម្បីមកមើលម្តាយនៅភូមិវិញ។ បន្ទាប់ពីមកដល់ភូមិវិញ ខ្ញុំត្រូវបានចាត់តាំងឱ្យទៅធ្វើការនៅការដ្ឋានភូមិកៀនជ្រៃ។ នៅឆ្នាំ១៩៧៦ ខ្ញុំរៀបការប្រពន្ធ និងធ្វើការនៅកងចល័តសហករណ៍។ ខ្ញុំគឺជាប្រធាន និងមិត្តនារី សៅ គឺជាអនុប្រធាន។ នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានចូលមកគ្រប់គ្រងឃុំគគរ។ ដោយឃើញសភាពការណ៍ល្អ ខ្ញុំសុំឱ្យមិត្តនារី សៅ ធ្វើជាប្រធានជំនួសវិញម្តង។ ខ្ញុំត្រូវទៅធ្វើការជាប្រធានកងចល័តវ័យកណ្តាលវិញដោយមើលលើការងារភ្ជួររាស់ ដាំពោត និងដំណាំផ្សេងៗ ដើម្បីផ្គត់ផ្គង់មូលដ្ឋាន។ ទោះបីជាមានការដាំដុះដំណាំកសិកម្មបានច្រើនយ៉ាងណាក៏ដោយ ប្រជាជនរួមទាំងរូបខ្ញុំផង គឺមិនមានអាហារហូបចុកគ្រប់គ្រាន់ទេ។ រីឯកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានចាប់អ្នកភូមិ ជនជាតិភាគតិចចាម និងកម្មាភិបាលមូលដ្ឋានយកទៅសម្លាប់កាន់តែច្រើនឡើង។ នៅឆ្នាំ១៩៧៨ ប្រពន្ធខ្ញុំបង្កើតបានកូនម្នាក់។ ខ្ញុំព្យាយាមដើរលួចជីកដំឡូងយកមកស្ងោរឱ្យប្រពន្ធកូនហូប។ ប៉ុន្តែថ្ងៃមួយ កងឈ្លបបានឃើញ និងចាប់ខ្ញុំយកមកសួរចម្លើយ។ ខ្ញុំឆ្លើយថា ខ្ញុំជីកដំឡូងព្រៃ មិនមែនដំឡូងដាំទេ។ បន្ទាប់មក ខ្ញុំត្រូវបានដោះលែង។ យ៉ាងណាក៏ដោយ ខ្ញុំត្រូវបានខ្មែរក្រហមឃ្លាំមើលគ្រប់ពេលវេលា។ នៅដើមឆ្នាំ១៩៧៩ ខ្ញុំ និងប្រពន្ធកូន បានរួចផុតពីសេចក្តីអត់ឃ្លាន និងស្លាប់។ ខ្ញុំ និងគ្រួសារប្រកបរបរជាកសិករ រហូតមកដល់សព្វថ្ងៃនេះ។

# របបខ្មែរក្រហមមិនបានយកចិត្តទុកដាក់លើសុខភាពប្រជាជន

**សុខ វណ្ណៈ**



ប្រជាជន១៧ មេសា ដែលខ្មែរក្រហមជម្លៀសឱ្យទៅរស់នៅតំបន់ជនបទដាច់ស្រយាល នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានទទួលជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ ដែលដឹកនាំដោយលោកសេនាប្រមុខលន់នល់។ ពេលនោះខ្មែរក្រហមបានដាក់ឈ្មោះខ្លួនឯងថារបបកម្ពុជាប្រជាធិបតេយ្យ ដែលស្គាល់ថា របបខ្មែរក្រហម។ បន្ទាប់ពីចូលគ្រប់គ្រងទីក្រុងភ្នំពេញ ខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនចេញទីក្រុងភ្នំពេញភ្លាមៗ ទោះបីមានអ្នកជំងឺកំពុងសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យក៏មិនលើកលែងដែរ។ ជាពិសេសទាហានលោក លន់ នល់ មួយចំនួនត្រូវយោធាខ្មែរក្រហមចាប់ធ្វើបាប និងយកទៅសម្លាប់ចោលយ៉ាងសាហាវព្រៃផ្សៃបំផុត។

រ៉ាន់ អាយុ៦៨ឆ្នាំ បានឃើញខ្មែរក្រហមជម្លៀសប្រជាជនថ្មីជាច្រើនគ្រួសារចេញពីភ្នំពេញ (ហៅថាប្រជាជន១៧ មេសា)។ រ៉ាន់ បានឃើញប្រជាជនថ្មីមួយចំនួនបន្តដំណើរទៅមុខទៀតហើយក៏មានប្រជាជនថ្មីមួយចំនួនបានចូលមករស់នៅក្នុងភូមិថ្មី

ឃុំផុង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។ រ៉ាន់ នៅចងចាំថា ខ្មែរក្រហមចាប់ផ្តើមប្រមូលទ្រព្យសម្បត្តិប្រជាជនដាក់រួមទាំងអស់ មិនឱ្យមានទ្រព្យសម្បត្តិឯកជន និង ចាប់ផ្តើមបំផ្លិចបំផ្លាញវត្តអារាម មិនអនុញ្ញាតឱ្យមានមន្ទីរពេទ្យ សាលារៀនជាដើម។ ប្រជាជននៅក្នុងភូមិទាំងអស់អង្គការបង្ខំឱ្យធ្វើការងាររួម ហូបបាយរួមនៅតាមសហករណ៍ និង មានកម្មាភិបាលខ្មែរក្រហមនៅតាមមូលដ្ឋានជាអ្នកចាត់តាំងការងារប្រចាំថ្ងៃ។ ខ្មែរក្រហមបានបែងចែកកម្លាំងជាបីក្រុម កម្លាំងទី១ គឺជាយុវជនយុវនារីដែលមានកម្លាំងខ្លាំង ឱ្យធ្វើការងារធ្ងន់ៗដូចជាលើកទំនប់ជីកប្រឡាយ។ រីឯកម្លាំងទី២ គឺជាមនុស្សវ័យកណ្តាល ដែលមានកូនចៅ ត្រូវឱ្យធ្វើការងារនៅតាមភូមិដូចជាកាប់គាស់ដកស្ទូងភ្ជួររាស់ ជួនកាលដកនៅតាមការដ្ឋានឆ្ងាយ ហើយយូរៗម្តង ទើបបានមកផ្ទះវិញ។ ចំណែកកម្លាំងទី៣ គឺជាកុមារដែលមានអាយុចាប់ពី៧ ដល់អាយុ១៤ឆ្នាំ នៅធ្វើការងារតាមភូមិដូចជាកើបអាចម៍គោតាមភូមិយកទៅធ្វើជីដាក់ស្រែ មានពេលខ្លះដេញសត្វចាបមិនឱ្យស៊ីស្រូវ និងពេលខ្លះទៀតសែងដីកាប់ដីដូចជាមនុស្សធំដែរ។

រ៉ាន់ នៅក្នុងសម័យខ្មែរក្រហមមានប្តី និងមានកូនចំនួនពីរនាក់។ អង្គការចាត់តាំង រ៉ាន់ ឱ្យធ្វើការងារហួសកម្រិត និងគ្មានពេលសម្រាក ដូចជាលើកទំនប់ជីកប្រឡាយ រែកដីដំបូង ដកស្ទូង។ ជួនកាល រ៉ាន់ ធ្វើការងារដកស្ទូងនៅពេលយប់ទៀត និងគ្មានអាហារគ្រប់គ្រាន់ គឺហូបតែបបររាវៗស្ទើរតែគ្មានគ្រាប់អង្ករក្នុងមួយថ្ងៃពីរពេល។ រ៉ាន់ សម្រាលកូនលើកទី១ នៅក្នុងភូមិ គ្មានមន្ទីរពេទ្យមានតែឆ្មប ដែលមានជំនាញតាមរបៀបចាស់ពីដើមតៗគ្នាមក។ រ៉ាន់ គ្មានបានថ្នាំលេបឬថ្នាំចាក់គ្មានសេរ៉ូមទេ គឺដើររកថ្នាំដឹកដោយខ្លួនឯងដូចជាដើរកាប់សម្បកឈើណាដែលអាចដឹកព្យាបាលជំងឺបាន និងគ្មានអ្នកមកសួរសុខទុក្ខ។ ក្រោយសម្រាលកូនហើយ អង្គការមានច្បាប់ឱ្យ រ៉ាន់ ឈប់សម្រាកបានតែ២០ថ្ងៃ។ អង្គការចាត់តាំងធ្វើការងារស្រាលៗសិនដូចជាឱ្យដេរស្លឹកត្នោតដើម្បីយកទៅប្រក់រោងនៅតាមការដ្ឋាន ឬប្រក់ផ្ទះរយៈពេលពីរខែ ទើបអង្គការចាត់តាំងឱ្យធ្វើការងារធ្ងន់វិញ។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមមកពីភូមិភាគនិរតីចូលមកកាន់កាប់នៅតំបន់ឃុំផុង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ និងបានប្រើនយោបាយអប់រំប្រជាជនឱ្យខំខិតធ្វើការងារដើម្បីកសាងប្រទេសជាតិ។ តែមិនយូរប៉ុន្មានកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានធ្វើបាបប្រជាជនជាងកម្មាភិបាលខ្មែរក្រហមមុនទៅទៀត និងបានចាប់ចងកម្មាភិបាលខ្មែរក្រហមចាស់ដែលធ្លាប់ដឹកនាំប្រជាជននៅទីនេះ។ នៅពេលខ្លះកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីប្រើល្បិចហៅយកទៅរៀនសូត្រ តែមិនដែលឃើញត្រឡប់មកវិញស្ទើរតែទាំងអស់។ ការលំបាកថ្មីមួយទៀតមកលើប្រជាជនជាពិសេសប្រជាជន១៧មេសា ស្ទើរតែបាត់ខ្លួនអស់ពីភូមិ។ កម្មាភិបាលមកពីភូមិនិរតី បានធ្វើបាបប្រជាជនលើសមុនទៀតទាំងការងារ ទាំងបង្អត់អាហារ និងយកទៅសម្លាប់ចោល។ ប្រជាជន១៧មេសា ត្រូវខ្មែរក្រហមធ្វើទារុណកម្មយកទៅសម្លាប់ដោយមិនដឹងអំពីកំហុសអ្វីទាំងអស់។ ខ្មែរក្រហមមកពីភូមិភាគនិរតីបានប្រព្រឹត្តទង្វើសាហាវបំផុត គឺសម្លាប់ប្រជាជននឹងត្បូងចប ភ្លៅរទេះ និង គល់ឫស្សីជាដើម។

នៅឆ្នាំ១៩៧៩ រ៉ាន់ បានរួចផុតពីរបបខ្មែរក្រហម ហើយរស់នៅជួបជុំគ្រួសារបងប្អូននិងប្រកបមុខរបរធ្វើស្រែចម្ការរៀងៗខ្លួនវិញ។ រ៉ាន់ បច្ចុប្បន្ននេះ កាន់តែចាស់ កម្លាំងមិនសូវមាន ជំងឺក៏ច្រើនលើសឈាម ឈឺចង្កេះ ឈឺក្រពះថែមទៀត។ ពេលនេះរ៉ាន់ សប្បាយចិត្តដោយសារមានក្មួយៗស្ម័គ្រចិត្តចុះមកសម្ភាសន៍សាច់រឿងដែលបានឆ្លងកាត់សម័យខ្មែរក្រហមសម្រាប់មនុស្សជំនាន់ក្រោយបានសិក្សារៀនសូត្រនិងបានសួរនាំអំពីសុខភាពប្រចាំថ្ងៃ ព្រោះពីមុនមកមិនដែលមានអ្នកណាយកចិត្តទុកដាក់រឿងសុខភាព និងនិយាយអប់រំពីសុខភាពទេ។

# ស្មាន គីយ៉ុមៈ ខ្មែរក្រហម ធ្វើឱ្យយាយកើតជំងឺឆ្អឹងខ្នងកោង

***មីន សាណាស់***

ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤ ខ្ញុំទទួលដំណឹងពីឪពុករបស់ខ្ញុំថាយាយ ស្មាន គីយ៉ុម ដែលត្រូវជាម្ដាយមីងរបស់គាត់ បានដើរដួលប៉ះទ្វារបន្ទប់ទឹក បង្កឱ្យមានរបួសជាំមុខ និងហើមក្បាលផ្នែកខាងស្ដាំឈឺមួយចំហៀងខ្លួន និង ធ្វើឱ្យគាត់កាន់តែពិបាកក្នុងការធ្វើដំណើរ ស្របពេលដែលឆ្អឹងខ្នងរបស់គាត់កោងក្នុងអំឡុងពេលគាត់កើតជំងឺកូវីត១៩។ កូនចៅរបស់យាយរួមទាំងខ្ញុំ មិនបានគិតអ្វីច្រើនទេចំពោះការកើតជំងឺឆ្អឹងខ្នងកោង គ្រាន់តែគិតថាប្រហែលជាគាត់មានអាយុច្រើនមិនរឹងមាំ ការដួលរបស់គាត់មកពីរមិនបានប្រយ័ត្ន ទើបបណ្ដាលឱ្យមានគ្រោះថ្នាក់បែបនេះ។ ក្រោយពីដួល ភ្នែកខាងស្ដាំរបស់យាយត្រូវងងឹតមើលអ្វីមិនឃើញ ប៉ុន្តែគាត់លាក់បាំងមិនចង់ឱ្យកូនចៅព្រួយបារម្ភ នាំតែអស់ថវិកាក្នុងការព្យាបាល។ ក្នុងថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៤ តាមការអង្វរពីកូនចៅ សុំឱ្យគាត់មកពិនិត្យភ្នែកនៅ ទីក្រុងភ្នំពេញ តែគាត់ស្នើមកពិនិត្យត្រឹមខេត្តកំពង់ចាម។ ពិនិត្យភ្នែកខាងមន្ទីរពេទ្យខេត្តកំពង់ចាមរួច ពេទ្យតម្រូវឱ្យឡើងមកពិនិត្យនៅមន្ទីរពេទ្យព្រះអង្គឌួង រាជធានីភ្នំពេញ ព្រោះត្រូវការវះកាត់បកភ្នែកជាបន្ទាន់ បើទុកទៀតអាចនឹងបាត់បង់កែវភ្នែកម្ខាងជារៀងរហូត។ នៅព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៤ យាយបានទទួលវះកាត់បកភ្នែករួចរាល់ នៅតែចាំលទ្ធផលពេលជាសះស្បើយពីរបួស។ ដើមហេតុនៃការដួលរបស់គាត់គឺ មកពីជំងឺឆ្អឹងខ្នងកោង ពិបាកក្នុងការធ្វើចលនា និង សកម្មភាពផ្សេងៗប្រចាំថ្ងៃ។ កាលពីតូចខ្ញុំធ្លាប់ស្ដាប់យាយរអ៊ូពីរឿងធ្វើការឱ្យ អាពត (ប៉ុលពត) ថា គាត់ត្រូវរែកដី, រែកស្រូវ, ទូល, អាឈើ, លើកឈើ និងធ្វើការងារធ្ងន់ៗជាច្រើនទៀត ព្រោះខ្លាច អាពតយកទៅសម្លាប់ដូចឪពុកម្ដាយ និង បងៗរបស់គាត់ចំនួន៣នាក់។



ស្មាន គីយ៉ុម និងអ្នកស្ម័គ្រចិត្តក្នុងគម្រោងសុខភាព មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំយល់ថាជំងឺឆ្អឹងខ្នងកោងវាមិនអាចកើតងាយៗបានទេចំពោះយាយរបស់ខ្ញុំ ប្រសិនបើគាត់មិនត្រូវខ្មែរក្រហមបង្ខំឱ្យធ្វើការងារហួសកម្លាំង។ តាមគេហទំព័រពេទ្យ វិន ថានី បានបង្ហាញពីវិធីសាស្ត្រសង្កេតមើលពីចំណុចដែលបង្កឱ្យមានជំងឺឆ្អឹងខ្នងកោងដូចជា៖ ស្មាទាំងពីរផ្អៀងមិនស្មើគ្នា, ត្រគាកផ្អៀងមិនស្មើគ្នា, ខ្លួនទ្រង់ទ្រាយឆ្អឹងជំនី និងឆ្អឹងខ្នងប៉ោងហើយផ្អៀងទៅខាងណាម្ខាង។ ចំណែកផលប៉ះពាល់គឺ ឆ្អឹងខ្នងកោង

បន្តិចបន្តួច បណ្តាលឱ្យពិបាកក្នុងការធ្វើសកម្មភាពផ្សេងៗ មួយចំនួនអាចទៅជាឆ្អឹងខ្នងកោងខ្លាំង នឹងមានបន្តឱ្យមានការឈឺសាច់ដុំរួមផងដែរ ប្រសិនបើមានមុំកោងបន្ថែមកាន់ច្រើន និងមានអាការប៉ះពាល់ដល់សរីរាង្គនៅក្នុងប្រព័ន្ធផ្សេងៗទៀត អាចមានការគាបសរសៃបាត់ ដូចជាស្ពឹក ខ្សោយ និងបាត់បង់តុល្យភាព ប្រសិនបើមានកោងនៅក្នុងទ្រូង បរិមាណសួតអាចថយចុះ។

ក្នុងសប្តាហ៍នេះ ខ្ញុំក៏ត្រឡប់ទៅស្វែងរកសារសំឡេងបទសម្ភាសន៍របស់យាយ ស្មាន គីយ៉ុម ជាមួយអ្នកស្ម័គ្រចិត្តកម្ពុជានៃមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងកំឡុងឆ្នាំ២០២១ និង សំឡេងសម្ភាសន៍របស់ខ្ញុំផ្ទាល់ដែលសួរនាំពីការត្បាញសារុង និងក្រមា ក្នុងរបបសង្គមរាស្ត្រនិយម និង ក្រោយរបបខ្មែរក្រហម។

**ខាងក្រោមនេះ គឺជារឿងរ៉ាវ និង បទពិសោធន៍របស់យាយ ស្មាន គីយ៉ុម ៖**

ខ្ញុំឈ្មោះ ស្មាន គីយ៉ុម ភេទស្រី អាយុ៧៨ឆ្នាំ (ក្នុងឆ្នាំ២០២៤) កើតនៅភូមិស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម និងបច្ចុប្បន្នរស់នៅក្នុងភូមិទី៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ណែស ស្មាន មានមុខរបរជាអ្នកជួញដូរ និងនេសាទត្រី និង ម្តាយឈ្មោះ ម៉ាត់ ហ្វាតីម៉ះ មានមុខរបរជាអ្នកតម្បាញសារុងសូត្រ។ ខ្ញុំមានបងប្អូនចំនួន៥នាក់ ក្នុងនោះមានប្រុសចំនួន៣នាក់។ បើនិយាយពីជីវិតកាលពីកុមារភាពរបស់ខ្ញុំ និងបទពិសោធន៍ល្អៗ ដែលខ្ញុំនៅចងចាំគឺការអង្គុយរៀនត្បាញសូត្រជាមួយម្តាយរបស់ខ្ញុំ ដែលកាលនោះ ខ្ញុំទើបមានអាយុប្រហែលជា៧ទៅ៨ឆ្នាំ។ ចំណែកអ៊ំៗរបស់ខ្ញុំរស់នៅភូមិទ្រា ក៏ចូលចិត្តមកយកខ្ញុំទៅនៅជាមួយគាត់ដើម្បីបង្រៀនឱ្យចេះត្បាញ។ ខ្ញុំឃើញក្រោមផ្ទះគាត់មានកីត្បាញច្រើន ខ្ញុំដឹងថាគាត់ពិតមានមុខរបរតម្បាញសារុងសូត្រ។ កាលពីក្មេងខ្ញុំចាប់អារម្មណ៍ការត្បាញសារុងសូត្រជាងត្បាញក្រមា ព្រោះសារុងសូត្រមានគោមធំៗ និងមានពណ៌ស្វាយស្រស់ស្អាតជាងក្រមា។ គ្រួសារខ្ញុំត្បាញសារុង និងក្រមា ទៅតាមតម្រូវការប្រើប្រាស់ និងលក់ចេញសម្រាប់ផ្គត់ផ្គង់ជីវភាពបន្ថែម។ ជីតាខ្ញុំមានឈ្មោះ ស្មាអែល គាត់ជាអ្នករកស៊ីខាងទិញយកក្រមា សារុងពីភូមិស្វាយឃ្លាំងយកទៅលក់ឱ្យខាងភូមិកោះរកា ភូមិកោះសូទិន និង ភូមិកំពង់ក្របី ដែលសុទ្ធតែជាភូមិមានជំនាញខាងត្បាញសំពត់សូត្រ មានគោមស្រស់ស្អាត។ ពេលត្រឡប់មកវិញ ជីតាខ្ញុំ ត្រូវយកសំពត់សូត្រទាំងនោះ មកលក់នៅភូមិស្វាយឃ្លាំង និង ភូមិជនជាតិចាមនៅតាមដងទន្លេមេគង្គ។ សំពត់សូត្រមួយៗមានតម្លៃណាស់នាសម័យសង្គមរាស្ត្រនិយម។ សំពត់មួយអាចមានតម្លៃប្រមាណជា៨០០ ទៅ៩០០រៀល ខណៈដែលមាសមួយជីតម្លៃត្រឹមតែ៣០០រៀល។ ម្តាយខ្ញុំខំសន្សំប្រាក់ណាស់ ដើម្បីទិញសំពត់មួយឱ្យខ្ញុំមុនថ្ងៃរៀបការ។

បន្ទាប់មកខ្ញុំបានរៀបការប្តីឈ្មោះ ម៉ៅ យូ (ស្លាប់ក្នុង២០០២) ដែលមានមុខរបរជាធ្វើស្រែ និង នេសាទត្រីដោយប្រើឧបករណ៍ឈ្នក់។ ចំណែកខ្ញុំក្រៅពីរដូវធ្វើស្រែ គឺនៅបន្តត្បាញសារុងដដែលៗ ឆ្នាំ១៩៧៣ ខ្ញុំបង្កើតកូនប្រុសម្នាក់ឈ្មោះ យូ សុក្រី ហើយក៏ជាឆ្នាំដែលខ្មែរក្រហមចូលមកគ្រប់គ្រងក្នុងភូមិ និង បង្កើតក្រុមសាមគ្គី។ ភូមិស្វាយឃ្លាំងចាប់ផ្តើមច្របូកច្របល់ ព្រោះយប់ឡើងដឹងតែមានមនុស្សជិះរទេះសេះមកចាប់យកចាស់ទុំក្នុងភូមិ និងអ្នកមានចំណេះដឹងជ្រៅជ្រះជាបន្តបន្ទាប់ៗ សំឡេងរទេះសេះ ធ្វើឱ្យអ្នកភូមិមានភាពភ័យខ្លាចគ្រប់ៗគ្នា និងផ្ទៀងត្រចៀកស្តាប់ក្រែងលោរទេះសេះមកឈប់នៅមុខផ្ទះ។ រហូតដល់ឆ្នាំ១៩៧៤ ដំបូងខ្មែរក្រហមចាប់ផ្តើមរៀបចំឱ្យមានជាសហករណ៍លក់ដូរ ដល់ក្រោយមកទៅជាសហករណ៍រួម មានរោងបាយរួម ហូបរួមគ្នា និងប្រមូលសម្ភារតាមផ្ទះនីមួយៗមកដាក់រួមទៀត។

ឆ្នាំ១៩៧៥ ខ្មែរក្រហមដែលគ្រប់គ្រងក្នុងភូមិកាន់តែគាបសង្កត់ឡើង បន្តឱ្យប្រជាជនក្នុងភូមិមានការរើបម្រាស។ ខ្ញុំចាំបានថាយប់មួយ មុនមានការបះបោរ ឈ្មោះ សុះ ពុនយ៉ាមីន បានមកហៅបងប្រុសខ្ញុំឈ្មោះ ណែសយ៉ា ដើម្បីទៅចូលរួមវាយខ្មែរក្រហមដែលតែងតែមកហៅអ្នកភូមិពេលយប់។ ម្តាយរបស់ខ្ញុំបានឃាត់ និងមិនអនុញ្ញាតឱ្យកូនគាត់ទៅនោះទេ ព្រមទាំងបិទទ្វារជាប់។ ហៀបភ្លឺព្រាងៗឡើង ប្តីខ្ញុំត្រឡប់ពីនេសាទត្រីវិញ គាត់ហាក់ដូចជា

ដឹងសភាពការណ៍មុន ហៅខ្ញុំឱ្យរៀបចំបង្វេចល្មមនឹងខ្លួន និងយកកូនចុះពីផ្ទះដើរសំដៅទៅខាងកើតភូមិ ដែលមានចម្ងាយឆ្ងាយពីមាត់ទន្លេ រួចនាំគ្នាជីកត្រង់សេ(លេណដ្ឋាន) សម្រាប់លាក់ខ្លួន គេចពីការវាយប្រហាររបស់ទាហានខ្មែរក្រហម។ ខ្ញុំចាំមិនភ្លេចពេលដែលកំពុងធ្វើដំណើរ ប្រុសៗក្នុងភូមិនាំគ្នានិយាយថា «យើងគ្មានអីតតាំងទេ មានតែ ដាវ កាំបិត ពូថៅ មិនអាចតទល់ជាមួយកាំភ្លើងបានទេ មានតែជីករណ្ដៅត្រង់សេឱ្យលឿន»។ ជីកត្រង់សេរួច ខ្ញុំ និងអ្នកភូមិឯទៀតជាស្ត្រី កូនក្មេងក៏នាំគ្នាចូលពួនក្នុងត្រង់សេ។ សន្ទាប់ទាហានខ្មែរក្រហមពីខាងមាត់ទន្លេចូលមក បាញ់រះអ្នកភូមិស្លាប់ដូចមាន់ដូចទា។ ដល់ម៉ោងប្រហែល ៤ ឬ ៥ល្ងាច ខ្ញុំ និងអ្នកភូមិងើបពីក្នុងត្រង់សេ។ បន្ទាប់មកខ្មែរក្រហមក៏ប្រមូលឱ្យឈរជាជួរ រួចបណ្ដើរចេញតាមច្រកផ្លូវវិហារពាល់ថ្ងៃទៅកាន់ផ្លូវខាងមុខ។ ប្រមូលអ្នកភូមិអស់ក៏បណ្ដេញចេញឱ្យទៅនៅខាងស្រុកក្រូចឆ្មារ។ ខ្មែរក្រហមបានបែងចែក ស្រីៗឱ្យនៅក្នុងវត្ត ចំណែកប្រុសៗគឺឱ្យនៅក្នុង ឡថ្នាំ ឬ សាលារៀន។ គ្រួសារខ្ញុំត្រូវខ្មែរក្រហមឃុំឃាំងក្នុងវត្តក្រូចឆ្មារ រយៈពេលជិតមួយខែ ទើបជម្លៀសឱ្យចេញទៅរស់នៅជាមួយបងប្អូនខ្មែរខាងឃុំប៉ើស។ ការងារដែលខ្មែរក្រហមដាក់ឱ្យខ្ញុំធ្វើគឺធ្វើស្រែចម្ការ គ្មានពេលសម្រាក និងអត់ឃ្លាន។ ឈ្លបខ្មែរក្រហមនៅតែបន្តតាមដានសមាជិកគ្រួសារខ្ញុំ និងអប់រំឱ្យចេះកសាងខ្លួន ព្រោះមាននាមជាពួកបះបោរប្រឆាំង។

ពីឆ្នាំ១៩៧៦ ដល់ ១៩៧៧ កម្មាភិបាលខ្មែរក្រហមបានមកនាំឪពុកម្ដាយ និងបងៗខ្ញុំចំនួន៣នាក់យកទៅសម្លាប់។ ខ្ញុំត្រូវរស់នៅទាំងភាពភ័យខ្លាច និងបារម្ភពីសុវត្ថិភាពប្អូនប្រុសខ្ញុំ។ ខ្ញុំត្រូវខំធ្វើការដូនអង្ករឱ្យច្រើន ដើម្បីអាចបន្តនៅរស់រានមានជីវិតបន្តទៀត ខណៈអ្នកភូមិដែលជាជនជាតិចាមបានបាត់ខ្លួនជារៀងរាល់យប់។

នារដូវវស្សាឆ្នាំ១៩៧៨ ទឹកទន្លេចាប់ផ្ដើមលិចភូមិខ្លាំងជាងឆ្នាំមុនៗ ក្រុមគ្រួសារខ្ញុំមិនអាចទៅធ្វើការអ្វីបានដូនអង្ករ របបអាហារក៏មិនបានទទួល ត្រូវអត់ឃ្លាន។ សាច់ញាតិ និង បងប្អូនថ្លៃខ្ញុំប្រុសៗត្រូវខ្មែរក្រហមហៅឱ្យទៅរស់នៅភូមិថ្មី ដោយមានស្រឡាងធំៗ ត្រៀមដឹកយកទៅ។ តែធាតុពិតគឺខ្មែរក្រហមយកទៅវាយទម្លាក់ទឹកទន្លេស្លាប់អស់។ ចុងឆ្នាំ១៩៧៨ សាច់ញាតិខ្ញុំទាំងអស់នៅសល់គ្នាចំនួន១៨នាក់ គឺមានតែក្មេងៗ ស្ត្រី និងមនុស្សចាស់ ដែលត្រូវខ្មែរក្រហមចាប់ផ្ដើមជម្លៀសជាលើកទី៣ ឱ្យចេញពីភូមិភាគបូព៌ា ចំណុចឃុំប៉ើស១ ស្រុកក្រូចឆ្មារ ទៅខាងស្រុកស្ទឹងត្រង់តាមរយៈស្រឡាង។ ចុះពីស្រឡាងត្រូវឡើងរថយន្តដែលនៅចតចាំជាមុន ដើម្បីបន្តដំណើរទៅស្រុកតាំងគោក ខេត្តកំពង់ធំ។ ពេលនោះខ្ញុំកំពុងពរពោះកូនស្រីទី២របស់ខ្ញុំក្នុងពោះបាន៣ខែ។ គ្រួសារខ្ញុំត្រូវរស់នៅក្នុងស្រុកតាំងគោក រយៈពេល២៨ថ្ងៃ និងជាពេលដែលគ្រប់គ្នាមានបាយហូប តែខ្មែរក្រហមតម្រូវឱ្យហូបជាមួយសម្លសាច់ជ្រូកព្រៃ។ ខ្ញុំបានទៅលួចអំបិលពីរោងបាយ ដើម្បីឱ្យឪពុកម្ដាយក្មេកខ្ញុំដែលមានវ័យចំណាស់ និង មិនព្រមបរិភោគសាច់ជ្រូក។ ម្ដាយក្មេកខ្ញុំបានហាមប្រាម កុំឱ្យទៅលួចមកទៀត ខ្លាចអង្គការចាប់បាននិងយកទៅសម្លាប់។ គ្រួសារខ្ញុំរស់នៅក្នុងខេត្តកំពង់ធំបានរយៈពេល២៨ថ្ងៃ ទើបកងទ័ពវៀតណាមចូលមករំដោះ ទើបយើងបានរស់រានមានជីវិត។ ប៉ុន្តែក្មួយៗខ្ញុំ ដែលមានអាយុក្រោម១០ឆ្នាំ ត្រូវបាត់បង់ឪពុកម្ដាយ ក្លាយជាកូនកំព្រាមកដល់សព្វថ្ងៃ។

ក្រោយរបបខ្មែរក្រហមដួលរលំគ្រួសារខ្ញុំក៏ចាប់ផ្ដើមប្រកបរបរនេសាទ និងធ្វើស្រែចម្ការសារជាថ្មី ដើម្បីចិញ្ចឹមជីវិត។ ខ្ញុំក៏បានបង្កើតកូនបីនាក់បន្ថែមទៀត។ កូនប្រុសច្បងរបស់ខ្ញុំ និង កូនស្រីទី២ មិនបានចូលរៀនសូត្រទេ នេះជាអ្វីដែលខ្ញុំតែងតែសោកស្ដាយ។ ចន្លោះពីឆ្នាំ២០០២ ដល់ឆ្នាំ២០១៩ ក្រោយពីប្ដីខ្ញុំស្លាប់ ខ្ញុំឈប់ពីធ្វើស្រែចម្ការមកធ្វើជាតួន (គ្រូបង្រៀនផ្នែកកូអាន) បង្រៀនកូនសិស្សតូចៗ នៅក្នុងភូមិ។ ចុងឆ្នាំ២០២១ ខ្ញុំបានឆ្លងជំងឺកូវីត-១៩។ ជំងឺកូវីត ធ្វើឱ្យខ្ញុំកើតអារម្មណ៍ភ័យខ្លាចម្ដងទៀត ដូចកាលរស់នៅក្នុងរបបខ្មែរក្រហម។ ខ្ញុំត្រូវរថយន្តពេទ្យដឹកយកទៅព្យាបាលនៅខេត្តត្បូងឃ្មុំ។ ក្រោយពីជាពីជំងឺកូវីត-១៩ ឆ្អឹងខ្នងរបស់ខ្ញុំឈឺ និងកោង ដែលមិនអាចធ្វើដំណើរត្រង់បាន។

# សឹង ណាំ៖ រំឭកអំពីការរស់រានមានជីវិត របស់ខ្លួនក្នុងពេលសង្គ្រាម និងការតាមសម្លាប់ដោយកងទ័ពខ្មែរក្រហម មកពីភូមិភាគនិរតី

ស៊ាង ចិន្តា



សឹង ណាំ អាយុ ៦៧ឆ្នាំ រស់នៅភូមិទោ៧ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម រៀបរាប់អំពីព្រឹត្តិការណ៍កងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតី ចាប់សម្លាប់កងទ័ពភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៧-៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សឹង ណាំ អាយុ៦៧ឆ្នាំ រស់នៅភូមិទី៧ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំធ្លាប់ប្រកបរបររត់ទូកតាមដងទន្លេ ប៉ុន្តែឈប់ប្រកបរបរនេះទៀតហើយ។ ខ្ញុំរៀបការប្រពន្ធឈ្មោះ ប៉េង តាំងសៀម និងមានកូនប្រុសស្រីទាំងអស់ចំនួន ៧ នាក់។ ខ្ញុំកើតនៅភូមិទី៣ ឃុំកោះសូទិន ស្រុកកោះសូទិន។ ខ្ញុំគឺជាកូនទី៣ក្នុងចំណោមបងប្អូនប្រុសស្រី៤ ប៉ុន្តែខ្ញុំបានបាត់បង់បងប្រុសទី២ម្នាក់នៅក្នុងរបបខ្មែរក្រហម។ ខ្ញុំរៀននៅសាលាបឋមសិក្សាភូមិទី៣ រហូតដល់ថ្នាក់ទី៧ចាស់។ នៅពេលនោះ ខ្ញុំត្រៀមប្រឡងចូលថ្នាក់វិទ្យាល័យ។ ខ្ញុំបានបោះបង់ការត្រៀមប្រឡងចេញ ពីព្រោះសង្គ្រាមបានផ្ទុះឡើង គឺបន្ទាប់ពីរដ្ឋប្រហារលន់ នល់ នៅថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០។ ភូមិសាស្ត្រកោះសូទិនគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទាហានលន់ នល់នៅឡើយ ខណៈពេលដែលភូមិសាស្ត្រដីហែត្រូវបានរំដោះដោយកងទ័ពរំដោះខ្មែរក្រហម និងតែងតែទទួលរងការទម្លាក់គ្រាប់បែកពីទាហានលន់ នល់។ នៅពេលនោះ ខ្ញុំមានអាយុ១៥ឆ្នាំ និងមានការភ័យតក់ស្លុតជាខ្លាំង នៅពេលដែលខ្ញុំឮការទម្លាក់គ្រាប់បែកនៅដីហែ។ បន្ទាប់មក ខ្ញុំសម្រេចចិត្តឈប់ទៅរៀននៅសាលា និងជួយការងារឪពុកម្តាយ។ ទាហានលន់ នល់ ឈរជើងនៅតាមបន្ទាយដែលជាគោលដៅដើម្បីត្រៀមប្រយុទ្ធជាមួយការរំកិលចូលរបស់កងទ័ពរំដោះខ្មែរក្រហមពីត្រើយម្ខាងទៀតនៃទន្លេមេគង្គ។ ចាប់ពីចុងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧២ ស្រុកកោះសូទិនគឺជាសមរភូមិប្រទាញប្រទង់គ្នាខ្លាំងរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។

នៅពាក់កណ្តាលឆ្នាំ១៩៧២ បងប្រុសរបស់ខ្ញុំដែលស្ម័គ្រចិត្តចូលធ្វើជាកងទ័ពរំដោះខ្មែរក្រហមបាន

មកលេងផ្ទះ និង ប្រាប់ឪពុកម្តាយឱ្យឆាប់ចាកចេញពីភូមិ ពីព្រោះកងទ័ពរំដោះខ្មែរក្រហមជាច្រើនត្រៀមបញ្ជូនមកវាយផ្តាច់យកកោះសូទិន។ នៅពេលនោះ អ្នកភូមិរស់នៅកោះសូទិនជាច្រើនគ្រួសារបានរត់ភៀសខ្លួនចេញពីភូមិមុនការប្រយុទ្ធគ្នាផ្ទុះឡើង ដោយខ្លះទៅទីរួមខេត្តកំពង់ចាម និងខ្លះទៀតទៅតំបន់រំដោះ។ គ្រួសាររបស់ខ្ញុំរត់ភៀសខ្លួនទៅដីហែ ដែលជាតំបន់រំដោះខ្មែរក្រហម។

នៅឆ្នាំ១៩៧៣ កងទ័ពរំដោះខ្មែរក្រហមបានវាយយកកោះសូទិនបានជោគជ័យ។ ខ្ញុំ និងគ្រួសារ សម្រេចចិត្តវិលត្រឡប់មកផ្ទះវិញ។ ប៉ុន្តែទោះបីជាបានមកដល់ផ្ទះវិញក៏ដោយ ភូមិរបស់ខ្ញុំតែងតែទទួលរងការផ្លោងគ្រាប់ពីបន្ទាយ ទាហាន លន់ នល់ ស្ថិតនៅក្បែរទីរួមខេត្តកំពង់ចាម។ នៅចុងឆ្នាំ១៩៧៣ ទាហានលន់ នល់ បានបើកការវាយប្រហារទៅលើកងទ័ពរំដោះខ្មែរក្រហមដើម្បីដណ្តើមយកកោះសូទិនវិញ។ ទាហាន លន់ នល់ ត្រូវបានបញ្ជូនចេញពីកោះមិត្ត ចំណែកឯកងទ័ពរំដោះខ្មែរក្រហម ឈរជើងត្រៀមប្រយុទ្ធនៅម្តុំព្រែកតាឃ្លោក។ ការប្រយុទ្ធទ្រង់ទ្រាយធំរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានផ្ទុះឡើង និងអូសបន្លាយជាច្រើនថ្ងៃ។ ទោះបីយ៉ាងណាក៏ដោយ កងទ័ពរំដោះខ្មែរក្រហមអាចទប់ទល់មិនឱ្យទាហាន លន់ នល់ វាយដណ្តើមយកកោះសូទិនបាននោះឡើយ។ បន្ទាប់មក ខ្ញុំចូលធ្វើជាកងទ័ពរំដោះខ្មែរក្រហម និងចូលប្រយុទ្ធក្នុងសមរភូមិជាច្រើន។

## សមរភូមិជាមួយទាហាន លន់ នល់

នៅឆ្នាំ១៩៧៤ ខ្ញុំនិងយុវជនក្នុងភូមិជាច្រើននាក់បានស្ម័គ្រចិត្តចូលបម្រើកងទ័ពរំដោះខ្មែរក្រហម។ ខ្ញុំត្រូវបានបញ្ជូនទៅរៀននៅសាលាហ្វឹកហ្វឺនកងទ័ព ស្ថិតនៅភូមិកំព្រោ។ ខ្ញុំរៀនអំពីយុទ្ធសាស្ត្រសង្គ្រាម រួមមាន៖ ការត្រៀមទប់ទល់ និងការប្រយុទ្ធសម្រុកទៅមុខជាដើម។ បន្ទាប់ពីបញ្ចប់ការហ្វឹកហ្វឺនអស់រយៈពេល២ខែ ខ្ញុំត្រូវបានបញ្ជូនទៅប្រយុទ្ធនៅសមរភូមិមុខកំពូល ដែលកងទ័ពរំដោះខ្មែរក្រហមកំពុងតែវាយចូលទៅមុខក្នុងទិសដៅទៅកាន់ទីក្រុងភ្នំពេញ។ ខ្ញុំត្រូវបានដាក់បញ្ចូលទៅក្នុងកងវរសេនាធំ ហៅថា អង្គភាព«៨២៨» ដែលមានសមមិត្ត មិត ជាប្រធាន។ កងវរសេនាធំរបស់ខ្ញុំ ត្រូវបានបញ្ជូនទៅវាយបន្ទាយ ទាហាន លន់ នល់ ជាច្រើនកន្លែង រហូតដល់ម្តុំបាក់ខែង និងឈរជើងនៅទីនោះ។ ទាហាន លន់ នល់ ជាច្រើននៅបន្តឈរជើងនៅម្តុំវត្តខ្វរដើម្បីត្រៀមប្រយុទ្ធទប់ទល់ជាមួយកងវរសេនាធំរបស់ខ្ញុំ។

នៅពាក់កណ្តាលឆ្នាំ១៩៧៤ កងវរសេនាធំរបស់ខ្ញុំទទួលបានទិសដៅវាយផ្តាច់ចូលក្នុងទីក្រុងភ្នំពេញ។ កងទ័ពរំដោះខ្មែរក្រហមបើកការវាយប្រហារជាទ្រង់ទ្រាយធំដែលពេលខ្លះអូសបន្លាយជាច្រើនថ្ងៃ។ នៅពេលដែលវាយបែកបន្ទាយ ទាហាន លន់ នល់ កងទ័ពក្នុងកងវរសេនាធំរបស់ខ្ញុំបានចាប់ខ្លួនទាហានលន់ នល់ ដែលជាជនជាតិភាគតិចព្នងចំនួន២-៣នាក់។ ជនជាតិភាគតិចព្នងដែលត្រូវបានចាប់ខ្លួននេះ គឺស្លៀកពាក់ក្នុងឈុតទាហានអាមេរិកាំង។ ខ្ញុំគ្រាន់តែបានឃើញតែប៉ុណ្ណោះ និងដឹងថាអ្នកទាំងនេះគឺជាជនជាតិភាគតិចព្នង ពីព្រោះតែការបោះក្រវិលត្រចៀកធំៗ។ បន្ទាប់មក ជនជាតិភាគតិចព្នង ដែលត្រូវបានចាប់ខ្លួននេះ ត្រូវបានប្រគល់ជូនអង្គភាពផ្សេងដើម្បីសួរចម្លើយ។ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពរំដោះខ្មែរក្រហមបានវាយចូលកាន់កាប់ទីក្រុងភ្នំពេញ។ កងវរសេនាធំរបស់ខ្ញុំ ត្រូវបានបញ្ជូនទៅគោលដៅគល់ស្ពានជ្រោយចង្វារ ខាងកើតដើម្បីជាកម្លាំងត្រៀមក្នុងករណីចាំបាច់។ នៅថ្ងៃបន្ទាប់គឺថ្ងៃទី១៨ ខែមេសា កងវរសេនាធំរបស់ខ្ញុំត្រូវបានផ្លាស់ទៅឈរជើងនៅទិសដៅអរិយក្សត្រ។ ខ្ញុំឃើញប្រជាជនពីទីក្រុងភ្នំពេញជាច្រើនត្រូវបានជម្លៀស និងដើរតាមផ្លូវ។ កងវរសេនាធំរបស់ខ្ញុំត្រូវនៅឈរជើងនៅ

ទិសដៅអរិយក្សត្រដល់ពាក់កណ្ដាលឆ្នាំ១៩៧៦។ នៅពេលនោះ កងទ័ពនៅក្នុងកងវរសេនាធំត្រូវចុះទៅធ្វើការងារនៅតាមការដ្ឋានរួមមាន៖ ធ្វើស្រែ និងជីកដី និងយាមនៅពេលយប់។

នៅចុងឆ្នាំ១៩៧៦ កងទ័ពនៅក្នុងកងវរសេនាធំរបស់ខ្ញុំ ត្រូវបានដកទៅក្នុងកងទ័ពភូមិភាគបូព៌ា។ ខ្ញុំត្រូវបានបញ្ជូនទៅកងពលលេខ៤ នៃកងទ័ពភូមិភាគបូព៌ាដែលឈរជើងនៅទីរួមខេត្តព្រៃវែង។ កងទ័ពនៅក្នុងកងពលលេខ៤ ត្រូវបានបញ្ជូនទៅធ្វើការជីកប្រឡាយ និងលើកដី ដូចប្រជាជនផ្សេងទៀតដែរ។

## សមរភូមិជាមួយកងទ័ពវៀតណាម

នៅឆ្នាំ១៩៧៧ កងពលលេខ៤ របស់ខ្ញុំត្រូវបានបញ្ជូនទៅភូមិសាស្ត្រភ្នំល្អក់ក្នុងស្រុកពញាក្រែកព្រំដែនវៀតណាម ដើម្បីត្រៀមវាយកងទ័ពវៀតណាម។ កងទ័ពខ្មែរក្រហមចាប់ផ្ដើមបើកការវាយប្រហារនៅសមរភូមិជាមួយកងទ័ពវៀតណាមយ៉ាងខ្លាំងក្លា។ កងពលរបស់ខ្ញុំវាយប្រយុទ្ធជាមួយកងទ័ពវៀតណាម ហើយរំកិលរហូតដល់ចូលដល់តាយនិញ ក្នុងទឹកដីប្រទេសវៀតណាម។ ខ្ញុំដឹងថាតាយនិញ គឺជាអតីតបន្ទាយទាហានអាមេរិក ឬហៅថាបន្ទាយដែក។ នៅថ្ងៃមួយក្នុងឆ្នាំ១៩៧៧ ដដែល ខណៈពេលដែលកងពលរបស់ខ្ញុំឈរជើងនៅសមរភូមិមុខ កងទ័ពវៀតណាមបានវាយផ្ដាច់ផ្នែកក្រោយនៅម្ដុំពញាក្រែក។ នៅពេលនោះ កងទ័ពខ្មែរក្រហមឈរជើងនៅវៀតណាមបានបាក់ទ័ព និងរត់រប៉ាត់រប៉ាយ។ ខ្ញុំ និងកងទ័ពក្នុងកងពលបានរត់រហូតដល់ទន្លេមេគង្គ។ កងទ័ពខ្មែរក្រហមដែលសេសសល់បានប្រមែប្រមូលផ្ដុំកម្លាំងសារជាថ្មីម្ដងទៀត និងត្រៀមវាយទប់ទល់ជាមួយកងទ័ពវៀតណាម។ ស្របពេលនោះដែរ កងទ័ពមកពីភូមិភាគនិរតីត្រូវបានបញ្ជូនមកភូមិភាគបូព៌ា។

## សមរភូមិជាមួយកងទ័ពមកពីភូមិភាគនិរតី

កងទ័ពមកពីភូមិភាគនិរតី គឺមិនបានមកជួយនោះឡើយ ប៉ុន្តែមកចាប់ខ្លួនប្រធានៗអង្គភាពក្នុងកងពលទៅវិញ។ នៅពេលនោះ ខ្ញុំគឺជាកងទ័ពដែលទទួលបន្ទុកការពារប្រធានកងពលលេខ៤។ កងការពាររបស់ខ្ញុំគឺស្នាក់នៅក្បែរផ្ទះប្រធានកងពល។ នៅក្នុងឆ្នាំ១៩៧៧ កងទ័ពមកពីភូមិភាគនិរតីបានមកហៅមិត្តគ្រី ដែលជាអនុប្រធានកងពលលេខ៤។ មិត្តគ្រី បានឡើងលើផ្ទះស្លៀកពាក់ និងត្រូវបាននាំយកទៅបាត់។ ខ្ញុំមិនដែលទទួលបានដំណឹងអ្វីពីមិត្តគ្រីទៀតឡើយ។ ៥ថ្ងៃក្រោយមកកងទ័ពនៅកងពលលេខ៤ភូមិភាគបូព៌ាបានមកដល់។ ប្រធានវរសេនាធំ ប្រធានវរសេនាតូច និងប្រធានអនុសេនាតូចដែលកំពុងឈរជើងនៅសមរភូមិមុខ ត្រូវបានកោះហៅមកប្រមូលផ្ដុំនិងចូលមកផ្ទះដែលកងការពាររបស់ខ្ញុំស្នាក់នៅ។ កងការពាររបស់ខ្ញុំគឺមិនត្រឹមតែទទួលបន្ទុកការពារប្រធានកងពលតែប៉ុណ្ណោះ ប៉ុន្តែថែមទាំងទទួលបន្ទុកដាំស្ល សម្រាប់កងទ័ពក្នុងកងពល។ មិត្តកង មកពីកងវរសេនាធំ ដែលបានស្គាល់ខ្ញុំ ប្រាប់ខ្ញុំថា គាត់ចង់ហូបសម្លកកូរ។ បន្ទាប់មក គាត់ប្រាប់ខ្ញុំថាគាត់ត្រូវឡើងទៅប្រជុំមួយភ្លែត។ នៅពេលនោះ ខ្ញុំប្រាប់ឱ្យគ្នីគ្នាក្នុងកងការពារ ស្វែងរកបន្លែពីព្រោះមានត្រីសាច់ស្រាប់ហើយ។ កងទ័ពម្នាក់ក្នុងកងការពារ ដែលដើររកបេះផ្លែខ្នុរ បានបាត់ខ្លួន។ មួយសន្ទុះក្រោយមក ខ្ញុំឃើញកងទ័ពនេះវិលត្រឡប់មកវិញក្នុងសភាពភ័យតក់ស្លុត មិនអាចនិយាយអ្វីបានទាល់តែសោះ។ បន្ទាប់មក ខ្ញុំស្លសម្លកកូរទាំងមិនមានផ្លែខ្នុរ និងបានរៀបចំទុកដាក់ក្នុងឆ្នាំងដើម្បីទទួលប្រធានៗដែលបានឡើងទៅប្រជុំ។ ប៉ុន្តែមិនមាននរណាម្នាក់មកហូបបាយ និងសម្លកកូរនោះឡើយ។ នៅពេលរសៀលបន្តិច ខ្ញុំចងអង្រឹងដេក និងបានសួរនាំ កងទ័ពដែលកំពុងតែភ័យស្លន់ស្លោនោះ ទើបខ្ញុំដឹងថាបងៗ ដែលជាប្រធានអង្គភាពទ័ពទាំងប៉ុន្មាននាក់ ត្រូវបានវាយសម្លាប់ចោលនៅក្នុងព្រៃអស់

ហើយ។ ខ្ញុំបានតាំងស្មារតី និង ប្រាប់ឱ្យនៅស្ងៀមកុំនិយាយផ្តេសផ្តាស។

១០ថ្ងៃក្រោយមក ឈ្មោះរបស់ខ្ញុំត្រូវបានដាក់ចូលក្នុងបញ្ជីរៀនសូត្រ។ ខ្ញុំដឹងថាខ្ញុំមិនរស់ទេនៅពេលនោះ។ ខ្ញុំភ័យតក់ស្លុតស្ទើរតែដើរមិនរួច។ ខ្ញុំបានតាំងស្មារតីឡើងវិញ បន្ទាប់ពីខ្ញុំបានគិតមួយសន្ទុះអំពីការចូលប្រយុទ្ធក្នុងសមរភូមិជាច្រើន។ បន្ទាប់មក ខ្ញុំបានប្រាប់កងទ័ពដែលឃើញការសម្លាប់នៅព្រៃខ្នុរនោះដើម្បីរត់គេចខ្លួន។ ខ្ញុំចង់ប្រាប់អ្នកផ្សេងទៀតនៅក្នុងអង្គភាពដែរ ប៉ុន្តែខ្ញុំមិនហ៊ាន ពីព្រោះខ្ញុំភ័យខ្លាចកងទ័ពមកពីភូមិភាគនិរតីដឹង និងចាប់ខ្ញុំយកទៅសម្លាប់ចោលតែម្តង។ ខ្ញុំ និងកងទ័ពម្នាក់នៅក្នុងកងពលរត់គេចខ្លួនក្នុងទិសដៅមកភូមិកំណើតវិញ។ យើងទាំង២នាក់រត់គេចចេញពីភូមិមួយទៅភូមិមួយទៀត។ នៅពេលនោះ មិនមានមនុស្សស្នាក់នៅលើផ្ទះទេ គឺស្ងាត់ភូមិតែម្តង។ នៅពេលយប់ ខ្ញុំឡើងទៅដេកនៅផ្ទះរបស់អ្នកភូមិ និងកាន់កាំភ្លើងជាប់ដៃជានិច្ច។ នៅព្រឹកបន្ទាប់ ខ្ញុំឮសូរផ្ទុះអាវុធដាក់គ្នារវាងកងទ័ពនៅភូមិភាគបូព៌ា និងកងទ័ពមកពីភូមិភាគនិរតី។ យើងទាំង២នាក់បន្តរត់គេចខ្លួនចូលក្នុងព្រៃកៅស៊ូវិហារលួង ស្ថិតនៅខាងកើតស្ទួង។ បន្ទាប់មក យើងទាំង២នាក់ឃើញកងទ័ពប្រហែល៤០នាក់ដើរកាត់ព្រៃកៅស៊ូដែរ។ នៅពេលនោះ ខ្ញុំសង្កេតមើលសម្លៀកបំពាក់ដូចជាកងពលតែមួយ។ ខ្ញុំរត់ទៅស្កាត់ក្បួនដែលកងទ័ពទាំងនោះដើរ។ ខ្ញុំបានស្រែកថាតើសភាពការណ៍យ៉ាងម៉េចហើយមិត្តបង? ប្រធានកង សួរវិញថាតើមកពីកងណា? ខ្ញុំប្រាប់ថា ច៤ គឺកងពលលេខ៤។ យើងទាំង២នាក់ចូលរួមជាកម្លាំងកងទ័ពសេសសល់នោះតែម្តង។ យើងដើររហូតដល់ចម្ការកៅស៊ូពាមជីលាំង។ នៅពេលនោះ យើងទាំងអស់ គ្នាមិនដឹងត្រូវរត់គេចខ្លួនទៅណាទៀតទេ ពីព្រោះសំឡេងគ្រាប់ផ្លោង និងកាំភ្លើងផ្ទុះឡើងស្ទើរតែគ្រប់ទីកន្លែង។

បន្ទាប់ពីស្នាក់នៅក្នុងព្រៃកៅស៊ូពាមជីលាំងបានមួយយប់ យើងសម្រេចចិត្តចេញមកផ្លូវដើម្បីបែកគ្នាត្រឡប់ទៅផ្ទះរៀងៗខ្លួន។ នៅពេលនោះ កងទ័ពមកពីភូមិភាគនិរតីបើកការវាយប្រហារ។ យើងទាំងអស់បានរត់ចូលពួនក្នុងព្រៃវិញ និងត្រូវបានឡោមព័ទ្ធ។ បន្ទាប់មក ខ្ញុំប្រាប់អ្នកទាំងអស់គ្នាឱ្យតាំងស្មារតី និងត្រៀមអាវុធដើម្បីវាយបើកផ្លូវសម្រុកចេញរហូតដល់បំបែកការឡោមព័ទ្ធបានយ៉ាងជោគជ័យ។ យើងទាំងអស់គ្នារួចផុតពីសេចក្តីស្លាប់ក្នុងសមរភូមិជាមួយកងទ័ពមកពីភូមិភាគនិរតី និងបន្តរត់គេចខ្លួន រហូតទៅដល់ខេត្តក្រចេះនិងខេត្តពោធិ៍សាត់។

ឆ្នាំ១៩៧៩ យើងខ្ញុំនៅតែប្រយុទ្ធជាមួយកងទ័ពមកពីភូមិភាគនិរតី ដើម្បីរត់គេចខ្លួនតែប៉ុណ្ណោះ។ នៅឆ្នាំ១៩៨០ ខ្ញុំរងរបួសនៅពេលដែលប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហមនៅសមរភូមិក្នុងខេត្តពោធិ៍សាត់។ ខ្ញុំមិនហ៊ានមកព្យាបាលរបួសនៅមន្ទីរពេទ្យទេ ពីព្រោះតែព្រួយបារម្ភខ្លាចការចាប់ខ្លួន។ ខ្ញុំដើរលែងរួច និងប្រាប់មិត្តទាំងអស់របស់ខ្ញុំថា ឱ្យទៅចោលខ្ញុំទៅ។ ប៉ុន្តែមិត្តទាំងអស់មិនបោះបង់ខ្ញុំចោលទេ គឺនៅជាមួយខ្ញុំក្នុងចម្ការក្រូច។ បន្ទាប់មក ម្ចាស់ចំការក្រូចបានមកជួបយើង។ ម្ចាស់ចម្ការនិយាយប្រាប់ថាលែងមានការធ្វើបាបទៀត ហើយនិងប្រាប់អាជ្ញាធរឱ្យមកជួយ។ បន្ទាប់មក ម្ចាស់ចម្ការបាននាំថ្នាំសង្កូវ និងអាហារមកឱ្យហូប។ នៅព្រឹកបន្ទាប់ អាជ្ញាធរបានមកដល់ និងលើកខ្ញុំដាក់លើឡានពេទ្យដើម្បីមកព្យាបាលនៅមន្ទីរពេទ្យខេត្តពោធិ៍សាត់។ ខ្ញុំទទួលការព្យាបាល អស់រយៈពេល៦ខែ។ មិត្តទាំងអស់មិនបានទៅណាទេ គឺនៅក្បែរខ្ញុំរហូត។

នៅចុងឆ្នាំ១៩៨០ មិត្តទាំងអស់និយាយលាគ្នា និងចាកចេញទៅកាន់ភូមិកំណើតរៀងៗខ្លួន។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលឃើញមិត្តទាំងអស់នោះទៀតឡើយ។ ខ្ញុំចាំឈ្មោះមិត្តតែ២ទេ គឺមិត្តយ៉ា (ហៅ យុន) និងមិត្តវ៉ាវី។ ខ្ញុំវិលត្រឡប់មកផ្ទះវិញ និងបានឃើញឪពុករបស់ខ្ញុំនៅផ្ទះ។

# សំ ឡុង៖ ឪពុកខ្ញុំ និងអ្នកភូមិបុសតាអ៊ឹម ប្រមាណ៣០នាក់ត្រូវបានខ្មែរក្រហមសម្លាប់ដោយចោទថាបានចូលជាមួយវៀតណាម

ឡុង ដានី



សំ ឡុង (រូបខាងស្តាំ ជួរខាងមុខ) ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម (រូបខាងឆ្វេង ជួរខាងមុខ)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងឆ្នាំ១៩៧៧ ឪពុកខ្ញុំ និងអ្នកភូមិបុសតាអ៊ឹម ប្រមាណ៣០នាក់ត្រូវបានខ្មែរក្រហមចោទថាបានចូលជាមួយយួន នៅពេលដែលខ្មែរក្រហមចាត់តាំងឱ្យបររទេះទៅអារឈើនៅក្នុងស្រុកឆ្លូង ខេត្តក្រចេះ។ ពេលត្រឡប់មកដល់ភូមិបុសតាអ៊ឹមវិញឪពុកខ្ញុំ និងអ្នកភូមិត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់នៅកន្លែងផ្សេងៗគ្នា។ ឪពុកខ្ញុំ និងពូម្នាក់ឈ្មោះ កយ ត្រូវខ្មែរក្រហមចាប់នៅភូមិថ្មទទឹង ឃុំដាំតាម៉ៅ ប្រកបូលបាវយកទៅវាលខាងលិចភូមិ និងបាត់ខ្លួនរហូត។ សំ ឡុង ភេទប្រុស អាយុ៦៣ឆ្នាំ ជនជាតិខ្មែរ រស់នៅភូមិតាម៉ៅកើត ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ បានរៀបរាប់រឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមដូចខាងក្រោម៖

ខ្ញុំមានប្រពន្ធឈ្មោះ ខៀវ សុវណ្ណ អាយុ៦០ឆ្នាំ ជនជាតិដើមភាគតិចស្ទៀង។ ខ្ញុំមានកូនចំនួន៧នាក់ ក្នុងនោះស្រីម្នាក់ និងប្រុស៦នាក់ (ស្លាប់ប្រុសម្នាក់ដោយគ្រោះថ្នាក់ចរាចរណ៍)។ ខ្ញុំមានមុខរបរ ធ្វើស្រែចម្ការ និងលេងភ្លេងអារក្ស។ ខ្ញុំមានស្រុកកំណើត

នៅភូមិបុសតាអ៊ឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ សួន សំ (ខ្មែរក្រហមសម្លាប់ក្នុងឆ្នាំ១៩៧៧) និងម្ដាយឈ្មោះ ប្រាញ់ ញ៉ាញ់ ស្លាប់ឆ្នាំ១៩៨៣ ដោយសារជំងឺ។ ខ្ញុំមានបងប្អូន៨នាក់ ក្នុងនោះមានប្រុស៤នាក់ និងស្រី៤នាក់។ ខ្ញុំជាកូនទី៣ក្នុងគ្រួសារ។

កាលពីក្មេងខ្ញុំមិនបានរៀនសូត្រ ព្រោះប្រទេសជាតិមានសង្គ្រាម និងសាលារៀនត្រូវបិទ។ ខ្ញុំបានឃើញទាហានទម្លាក់គ្រាប់បែក និងបើករថក្រោះឆ្លងកាត់តាមភូមិ ដើម្បីស្វែងរកកងទ័ពវៀតកុង។ ខ្ញុំបានឃើញទាហានអាមេរិកប្រយុទ្ធជាមួយកងទ័ពវៀតកុងនៅតាមវាលស្រែនៅម្ដុំស្រែតាពេជ។ ពេលនោះរថក្រោះអាមេរិក បានបើកតាមផ្លូវលំកាត់តាមព្រៃមកភូមិតាម៉ៅ ភូមិទួលគ្រួស ភូមិជាំផ្ដិន ភូមិទឹកពូក និងភូមិកន្ទួត ដែលជាភូមិរបស់ជនជាតិដើមភាគតិចស្ទៀង។ ទាហានអាមេរិក និងកងទ័ពវៀតកុងបានចូលមកក្នុងភូមិ និងតំបន់ព្រៃក្បែរនោះប្រហែលជាង១ខែ ទៅ២ខែ ក៏ដកទៅវិញអស់។

នៅក្នុងឆ្នាំ១៩៧២ ឬឆ្នាំ១៩៧៣ ខ្មែរក្រហមបានចូលមកដល់ក្នុងភូមិបុសតាអ៊ឹម និងភូមិផ្សេងទៀតក្នុងឃុំជាំតាម៉ៅ និងបានដើរឃោសនាឱ្យប្រជាជនចូលរួមក្នុងចលនារបស់ខ្មែរក្រហម។ នៅតាមភូមិនីមួយៗ ខ្មែរក្រហមចាប់ផ្ដើមឱ្យប្រជាជនបង្កើតជាក្រុមប្រវាស់ដៃ គឺជួយធ្វើការងារស្រែចម្ការឱ្យគ្នាទៅវិញទៅមក និងហូបបាយនៅតាមផ្ទះរៀងៗខ្លួននៅឡើយ។ ខ្ញុំក៏មានការងារឃ្វាលគោក្របីនៅតាមវាល និងជួយធ្វើស្រែចម្ការជាមួយឪពុកម្ដាយខ្ញុំ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមទទួលជ័យជម្នះទូទាំងប្រទេស ខ្មែរក្រហមបានរៀបចំជាសហករណ៍ ដើម្បីឱ្យប្រជាជនក្នុងភូមិធ្វើការងាររួម ហូបចុករួមនៅតាមសហករណ៍។ ខ្មែរក្រហមក៏បានជម្លៀសប្រជាជន១៧មេសា មករស់នៅក្នុងភូមិបុសតាអ៊ឹម ប្រមាណ៥០គ្រួសារ។ ប្រជាជន១៧មេសា មកដល់ដំបូង ខ្មែរក្រហមយកទៅផ្ញើនៅតាមផ្ទះអ្នកភូមិ ក្នុងមួយផ្ទះមួយគ្រួសារ។ បន្ទាប់មកទៀតទើបខ្មែរក្រហមឱ្យប្រជាជន១៧មេសា កាប់កូនឈើ រកស្លឹកមកប្រក់ធ្វើខ្ទមរស់នៅតាមជាយៗភូមិដោយខ្លួនឯង។ ប្រជាជន១៧មេសា បានស្លាប់ច្រើន ដោយសារជំងឺគ្រុនចាញ់ អត់អាហារ ធ្វើការងារពលកម្មហួសកម្លាំង និងត្រូវខ្មែរក្រហមយកទៅសម្លាប់។ បន្ទាប់ពីខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ មានគ្រួសារប្រជាជន១៧មេសា មិនដល់១០គ្រួសារទេ ដែលបានត្រឡប់ទៅភ្នំពេញវិញ។ បច្ចុប្បន្នមានកូនប្រជាជន១៧មេសា ចំនួន២នាក់បានបន្តរស់នៅក្នុងភូមិបុសតាអ៊ឹម ពីព្រោះឪពុក ម្ដាយ បងប្អូនត្រូវបានខ្មែរក្រហមសម្លាប់។ ភូមិបុសតាអ៊ឹម មានប្រធានកងតូច ឬប្រធាន មានឈ្មោះតាស៊ឹង ចំណែកប្រធានសង្កាត់ ឬឃុំជាំតាម៉ៅមានឈ្មោះតាភូមិ។

ក្រុមគ្រួសារខ្ញុំ ត្រូវបានខ្មែរក្រហមចាត់ជាគ្រួសារសក្ដិភូមិ ហើយខ្មែរក្រហមបានបំបែកគ្រួសារខ្ញុំឱ្យរស់នៅបែកគ្នា។ ឪពុកខ្ញុំ ត្រូវខ្មែរក្រហមចាត់តាំងឱ្យទៅលើកទំនប់ឆ្ងាយពីភូមិ។ ម្ដាយ ខ្ញុំ ត្រូវចាត់តាំងឱ្យបិតប្រព័ន្ធភ្លឺស្រែ ដកស្ទូង និងច្រូតកាត់។ បងៗរបស់ខ្ញុំ ត្រូវបានខ្មែរក្រហមចាត់តាំងឱ្យធ្វើការងារក្នុងកងចល័តនៅឆ្ងាយៗពីភូមិ ខ្ញុំ ត្រូវខ្មែរក្រហមចាត់តាំងឱ្យនៅមើលក្របី។ ចំណែកប្អូនៗត្រូវស្ថិតនៅក្នុងកងកុមារ។

ចំពោះរបបអាហារ គឺហូបបបរ ក្នុងមួយថ្ងៃ២ពេល គឺពេលថ្ងៃត្រង់ និងពេលល្ងាច។ នៅដើមឆ្នាំ១៩៧៧ ឪពុកខ្ញុំ និងកងបុរសប្រហែល៣០នាក់ ត្រូវបានខ្មែរក្រហមចោទថាចូលដៃចូលជើងជាមួយយួន។ ឪពុកខ្ញុំ និងអ្នកភូមិប្រហែល៣០នាក់ផ្សេងទៀតត្រូវខ្មែរក្រហមចាត់តាំងឱ្យទៅអារឈើ និងដឹកឈើនៅកំពង់សសរក្នុងស្រុកឆ្លូង។ ក្នុងរទេះក្របីនីមួយៗមានមនុស្សចាស់ម្នាក់ និងក្មេងមើលក្របីម្នាក់។ ពេលត្រឡប់មកពីអារឈើវិញ មានក្មេងមើលក្របីម្នាក់ឈ្មោះ មឿន ឈីនបានមករាយការណ៍ប្រាប់តាស៊ឹង ដែលជាប្រធានភូមិថា អ្នកទៅអារឈើទាំងអស់បានទៅមើលខ្សែភាពយន្ត

ឯកសាររបស់វៀតណាម។ តាស៊ីងក៏បានទៅរាយការណ៍ប្រាប់ប្រធានឃុំឈ្មោះតាភូមិ។ បន្ទាប់មកខ្មែរក្រហមបានចោទប្រកាន់ឪពុកខ្ញុំ និងអ្នកដែលបានទៅអារឈើប្រមាណ៣០នាក់ទៀតថាជាមនុស្សក្បាលយួនខ្លួនខ្មែរ ហើយត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់។ ដោយខ្មែរក្រហមបានចាត់តាំងឱ្យទៅអារឈើនៅភូមិកប្បាសក្នុងឃុំមេមង់ និងបាត់ខ្លួនតែម្តង។ ចំណែកឪពុកខ្ញុំ និងពូម្នាក់ឈ្មោះកយ ត្រូវខ្មែរក្រហមចាប់នៅភូមិថ្នូទទឹង ប្រកបូលបាវយកទៅវាលខាងលិចភូមិ និងបាត់ខ្លួនរហូត។ ក្នុងចំណោមនោះ មានតែតាថ្លៃម្នាក់គត់ដែលបានគេចខ្លួន គឺគាត់បានរត់គេចពីមួយកន្លែងទៅមួយកន្លែង បន្ទាប់មកគាត់រត់ចូលក្នុងព្រៃ និងភៀសខ្លួនទៅប្រទេសវៀតណាម។ បន្ទាប់ពីរំដោះឆ្នាំ១៩៧៩ តាថ្លៃបានត្រឡប់មករស់នៅក្នុងភូមិថ្នូទទឹងវិញ។ តាថ្លៃ ទើបតែស្លាប់ដោយសារចាស់ជរាប៉ុន្មានឆ្នាំមុននេះ។

នៅចុងឆ្នាំ១៩៧៧ ខ្ញុំ និង អ្នកភូមិទាំងអស់ត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិឱ្យទៅរស់នៅស្រុកស្នួល ខេត្តក្រចេះ។ ខ្មែរក្រហមបានឱ្យប្រជាជនធ្វើដំណើរ និងដេកនៅតាមព្រៃរយៈពេល៣ទៅ៤ថ្ងៃក្នុងមួយកន្លែងៗ និងរយៈពេលប្រហែលមួយខែទើបទៅដល់ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ។ ខ្ញុំ និងអ្នកភូមិបុសតាអ៊ឹមបានរស់នៅស្រុកស្នួលបានប្រហែលមួយខែ ទើបខ្មែរក្រហមបន្តជម្លៀសឱ្យទៅរស់នៅជាមួយជនជាតិភាគតិចព្នងនៅភូមិស្រែជិះស្រែខ្ទឹប ក្នុងស្រុកសំបូរ ខេត្តក្រចេះ។ ក្នុងរយៈនៃការជម្លៀសការរស់នៅរបស់ ខ្ញុំ និងអ្នកភូមិបុសតាអ៊ឹមមានភាពលំបាកខ្លាំង អ្នកភូមិដែលមានវ័យចាស់ជរាភាគច្រើនបានស្លាប់ដោយសារអត់អាហារ និងធ្វើការងារពលកម្មធ្ងន់ធ្ងរ។

នៅចុងឆ្នាំ១៩៧៨ ខ្ញុំ និងអ្នកភូមិបុសតាអ៊ឹមទាំងអស់ ត្រូវបានខ្មែរក្រហមជម្លៀសឱ្យមកខាងថ្មគ្រែ ខេត្តក្រចេះ ដើម្បីរង់ចាំជិះកាណូតមកស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ ខ្ញុំ និងអ្នកភូមិបុសតាអ៊ឹមបានស្នាក់នៅស្រុកស្ទឹងត្រង់រយៈពេល៣យប់ ទើបខ្មែរក្រហមដឹកតាមរថយន្តមករស់នៅភូមិស្វាយភ្លើងក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ពេលរស់នៅក្នុងភូមិស្វាយភ្លើង ខ្ញុំ និងអ្នកភូមិបុសតាអ៊ឹម បានហូបចុកគ្រប់គ្រាន់។ បើតាមខ្ញុំចង់ចាំការរស់នៅភូមិស្វាយភ្លើងបានប្រហែលមួយខែ កងទ័ពវៀតណាមក៏ចូលដល់ទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ នៅខណៈពេលនោះ ខ្ញុំ និងអ្នកភូមិបានធ្វើដំណើរកាត់តាមស្រុកចម្ការលើ មកកំពង់ចាម និងឆ្លងស្រឡាងមកទន្លេបិទ បន្តដំណើរមកស្រុកពញាក្រែក និងបានមករស់នៅភូមិកំណើតនៅបុសតាអ៊ឹមវិញ។

ក្រោយពីបាត់បង់ឪពុក ខ្ញុំត្រូវជួយម្តាយធ្វើស្រែចម្ការដើម្បីចិញ្ចឹមបងប្អូន។ នៅឆ្នាំ១៩៨០ ខ្ញុំបានមករស់នៅជាមួយឪពុកមាក្នុងភូមិតាម៉ៅកើតដើម្បីធ្វើស្រែយកស្រូវទៅជួយចិញ្ចឹមម្តាយ និងបងប្អូន។ ខ្ញុំ បានរៀនអក្សរខ្មែរក្រៅម៉ោងប្រហែល៣ ទៅ៤ម៉ោង ក៏ឈប់រៀន។ នៅឆ្នាំ១៩៨៣ ខ្ញុំបានចូលរៀនថ្នាក់អក្ខរកម្មប្រហែល៥-៦ខែទៀត ទើបខ្ញុំ អាចសរសេរ និងអានអក្សរបាន។ នៅឆ្នាំ១៩៨៥ ខ្ញុំបានរៀបការប្រពន្ធឈ្មោះ ខៀវ សុវណ្ណ ដែលជាជនជាតិដើមភាគតិចស្ទៀងរស់នៅភូមិតាម៉ៅកើត។ បន្ទាប់មក ខ្ញុំបានផ្លាស់មករស់នៅជាមួយគ្រួសារខាងប្រពន្ធ និងប្រកបរបរធ្វើស្រែចម្ការ។



សំ ឡុង សព្វថ្ងៃរស់នៅភូមិបុសតាអ៊ឹម ជុំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ៊ុត សុខា៖ ខ្ញុំមានសំណាងមិនស្លាប់រហូតដល់ទៅបីដង

## ថុន ស្រីពេជ្រ

ខ្ញុំឈ្មោះ អ៊ុត សុខា ភេទស្រី អាយុ៦៥ ឆ្នាំ រស់នៅភូមិជើងទឹក សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង។ កាលនៅពីតូចខ្ញុំបានចូលរៀននៅសាលាព្រៃវែងក្រុងត្រឹមថ្នាក់ទី៩ចាស់។ នៅសម័យខ្មែរក្រហម គ្រួសារខ្ញុំត្រូវបានជម្លៀសទៅភូមិខ្សោកដើម្បីធ្វើស្រែ និងជីកប្រឡាយ។ គ្រួសារខ្ញុំ ជាគ្រួសារដែលត្រូវចាត់ចូលក្នុងជំពូកប្រជាជនថ្មី ប៉ុន្តែខ្មែរក្រហមមិនបានគាបសង្កត់សមាជិកគ្រួសារខ្ញុំខ្លាំងពេកទេ។ នៅពេលដែលខ្ញុំធ្វើការងាររហ័ត់ ខ្ញុំអាចសម្រាកមួយភ្លែតបាន។ នៅពេលដែលខ្ញុំឃ្លាន ខ្ញុំអាចគាស់ដំឡូងយកមកស្ងោរហូបបាន ប៉ុន្តែក៏ត្រូវលាក់កំបាំងពីគេឯងដែរ។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៧ គ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសទៅកាន់ខេត្តពោធិ៍សាត់។ ខ្ញុំមិនដឹងគិតយ៉ាងណាទេ ព្រោះប្រជាជននៅក្នុងភូមិ ត្រូវបានជម្លៀសស្ទើរតែទាំងអស់ រួមទាំងគណៈឃុំ។ អ្នកជម្លៀសទាំងអស់ ត្រូវធ្វើដំណើរដោយថ្មើរជើងទៅកាន់កំពង់ចម្លងអ្នកលឿង ដើម្បីបន្តដំណើរមកក្រុងភ្នំពេញ។ នៅពេលកប៉ាល់បានមកដល់មុខវាំង ប្រជាជនជាច្រើនសប្បាយរីករាយយ៉ាងខ្លាំង ព្រោះបានមើលឃើញព្រះបរមរាជវាំងដ៏ស្រស់ស្អាត។ បន្តិចក្រោយមក អ្នកនៅលើកប៉ាល់ទាំងអស់បានជ្រួលច្របល់ឡើង បន្ទាប់ពីបានដឹងថា កប៉ាល់ដែលខ្លួនកំពុងជិះបានលិចទឹកចូលពេញ។ ជាសំណាងល្អ កប៉ាល់នោះមិនបានលិចភ្លាមៗទេ។ យើងបានមកដល់ទីចំណតក្បែរស្ពានជ្រោយចង្វារ មុនពេលដែល



អ៊ុត សុខា អាយុ ៦៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិជើងទឹក សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កប៉ាល់នោះលិច។ អ្នកជម្លៀសទាំងអស់បានចាកចេញពីកប៉ាល់យ៉ាងប្រញាប់ប្រញាល់ ហើយឡើងទៅជិះរថភ្លើងបន្តរហូតទៅដល់ស្រុក មោងឫស្សី ខេត្តបាត់ដំបង។

មនុស្សស្រីម្នាក់ ក្នុងសម្លៀកបំពាក់ពណ៌ខ្មៅ និងពាក់មួកកន្តឹប បានបើកទ្វាររថភ្លើង រួចប្រកាសឱ្យអ្នកជម្លៀសទាំងអស់ប្រញាប់ចាកចេញពីរថភ្លើងចូលទៅក្នុងព្រៃ។ អ្នកគ្រប់គ្នាបានចាកចេញ

យ៉ាងលឿន ហើយគ្រួសារខ្ញុំបានចាកចេញជាមួយគេដែរ និងបានដើរទៅឆ្ងាយតាមការបញ្ជារបស់អ្នកនាំផ្លូវៗ ខ្ញុំដើរកាត់ដីខ្សាច់ដោយជើងទទេៗ ជើងខ្ញុំស្ទើរតែរលាកដើរលែងរួចៗ នៅតាមផ្លូវ យើងត្រូវបានអនុញ្ញាតឱ្យឈប់ដាំបាយហូបៗ ខ្ញុំបានឱកាសសម្រាកបន្តិចៗ ពេលហូបបាយរួច យើងត្រូវអង្គការហៅឱ្យទៅចូលរួមប្រជុំ ដើម្បីរៀបចំឱ្យមានក្រុម និងត្រូវបានចាត់តាំងឱ្យចូលធ្វើការងារភ្លាមៗ។ ខ្ញុំពុំបានដឹងថា តើខ្ញុំនិងគ្រួសារត្រូវសម្រាកនៅទីណាទេ។ នៅពេលយប់ ខ្មែរក្រហមបាននាំយើងមករកកន្លែងសម្រាក គឺនៅក្នុងខ្ទមតូចមួយក្បែរវាលស្រែ។ ការមកដល់ខេត្តពោធិ៍សាត់ ខ្ញុំមានអារម្មណ៍មិនល្អភ្លាម ព្រោះខ្ញុំគិតថា ខ្ញុំកាន់តែលំបាកជាងមុនទៅទៀត។ ពេលព្រឹកព្រលឹមឡើង អង្គការបានគោះជួង ដើម្បីដាស់យើងឱ្យក្រោកទៅធ្វើការ។ ជួនកាល អង្គការប្រើយើងឱ្យងើបតាំងពីម៉ោង ២ ព្រឹក ទៅធ្វើការងារនៅឯស្រែ។ មុននឹងចេញទៅធ្វើស្រែ យើងត្រូវឈរតម្រង់ជួរសិន។ កម្មាភិបាលខ្មែរក្រហម ដើររាប់សមាជិក។ ពេលរាប់គ្រប់ចំនួនហើយ ទើបកម្មាភិបាលរូបនោះ បញ្ជាយើងឱ្យបំបែកជួរដើរទៅកាន់វាលស្រែ។ ខ្ញុំនៅចាំបានថា ការងារដំបូងដែលខ្ញុំធ្វើ គឺកាប់ដី និងលើកប្រព័ន្ធភ្លឺស្រែ។ បន្ទាប់មក ខ្ញុំត្រូវទៅដកស្ទូង ច្រូតស្រូវ រែកកណ្ដាប់ និងជីកប្រឡាយ។

នៅដើមខែមករា ឆ្នាំ១៩៧៩ ខ្ញុំ និងអ្នកឯទៀតត្រូវខ្មែរក្រហមជម្លៀសឱ្យទៅឆ្ងាយពីភូមិដែលខ្ញុំ និងអ្នកទាំងនោះពុំធ្លាប់រស់នៅ។ នៅទីនោះ ខ្ញុំត្រូវខ្មែរក្រហមបង្ខំឱ្យជីករណ្ដៅទំហំ៥០ម៉ែត្របួនជ្រុងក្នុងរយៈពេល២ថ្ងៃ។ យើងទាំងអស់គ្នា ពុំបានដឹងថា រណ្ដៅដែលយើងកំពុងតែជីកនេះ ជារណ្ដៅសម្រាប់កប់ខ្លួនឯងទាល់តែសោះ។ អង្គការបានឱ្យយើងហូបឆ្អែត។ ខ្ញុំសប្បាយចិត្តណាស់ ព្រោះខ្ញុំបានហូបឆ្អែត។ ប៉ុន្តែ ខ្ញុំបានឮអ្នកភូមិនិយាយគ្នាថា ខ្មែរក្រហមនឹងសម្លាប់យើងចោល បន្ទាប់ហូបឆ្អែតហើយ។ ជាសំណាងល្អ យើងមិនទាន់ត្រូវក្រុមខ្មែរក្រហមសម្លាប់ឡើយ ព្រោះក្រុមខ្មែរក្រហមទាំងនោះបានរត់ចោលយើងបាត់ទៅហើយ។ ខ្ញុំ និងអ្នកផ្សេងទៀតបានវិលត្រឡប់មកកាន់ស្រុកកំណើតវិញ ហើយបានរួចរស់មានជីវិតរហូតមកដល់សព្វថ្ងៃ។

ឆ្លងកាត់របបខ្មែរក្រហម ខ្ញុំបានជួបប្រទះរឿងរ៉ាវច្រើនណាស់។ ខ្ញុំបានរួចផុតសេចក្ដីស្លាប់ចំនួន៣ដង។ ខ្ញុំនៅចងចាំថា ខ្ញុំត្រូវខ្មែរក្រហមបញ្ជូនឱ្យទៅធ្វើការនៅក្នុងកងហា និងត្រូវខ្មែរក្រហមចងស្លាបសេកជាមួយនឹងមនុស្ស៥០នាក់ទៀតនៅក្នុងកង។ យើង ត្រូវខ្មែរក្រហមនាំយកទៅសម្លាប់នៅវេលាម៉ោង១២យប់។ នៅពេលទៅដល់រណ្ដៅ កងឈ្លបឱ្យយើងអង្គុយចុះ។ យើងមិនអាចរត់ទៅណាបានទេ ព្រោះកងឈ្លបនៅយាមជុំវិញ។ អ្នកផ្សេងទៀតត្រូវបានចងដៃ និងបិទត្រចៀក លើកលែងតែខ្ញុំម្នាក់ប៉ុណ្ណោះ។ ខ្ញុំបានឃើញ និងឮសំឡេងសន្តិសុខវាយអ្នកទោសនឹងពូថៅ ឮសូរតែប៉ូកៗ ហើយអ្នកទោសបានប្រកាច់ និងត្រូវបានធ្លាក់ចូលទៅក្នុងរណ្ដៅ។ ពេលឃើញហើយ ខ្ញុំត្រជាក់ចុងដៃចុងជើង និងភ័យខ្លាចខ្លាំងណាស់។ ខ្ញុំអង្គុយស្ទើរតែក្រាបដល់ស្មៅទៅហើយ ព្រោះមិនចង់ឱ្យឈ្លបទាំងនោះឃើញ។ ជាសំណាងល្អ អ្នកនៅចុងក្រោយគេ គឺជាខ្ញុំ។ កងឈ្លបមិនបានវាយសម្លាប់ខ្ញុំទេ ព្រោះកងឈ្លបទាំងនោះអស់កម្លាំង និងរោយដៃ។ ខ្ញុំក៏បានរួចខ្លួនប៉ុន្តែកងឈ្លបបានបញ្ជូនខ្ញុំមកកាន់កងរយ ដើម្បីត្រៀមយកទៅសម្លាប់នៅរយៈពេល៥ថ្ងៃបន្ទាប់ទៀត។ រយៈពេល៥ថ្ងៃបន្ទាប់បានមកដល់ ខ្ញុំក៏ត្រូវបញ្ជូនមកសម្លាប់ម្ដងទៀត ហើយខ្ញុំបានរួចខ្លួនម្ដងទៀតដែរ។ បន្ទាប់មក ខ្ញុំក៏ត្រូវបញ្ជូនទៅកាន់កងផ្សេងបន្តទៀត។ លើកនេះខ្ញុំក៏មានសំណាងដែរ ព្រោះកងទ័ពវៀតណាមបានចូលមកដល់។ ខ្មែរក្រហមបានរត់ទៅបាត់អស់បន្សល់ទុកខ្ញុំនៅក្បែររណ្ដៅ។ ខ្ញុំបានធ្វើដំណើរមកកាន់ស្រុកកំណើតវិញ តាមបញ្ជារបស់កងទ័ពវៀតណាម។ នៅតាមផ្លូវ ខ្ញុំបានជួបបងប្អូនឪពុកម្ដាយដោយចៃដន្យ។ យើងបាននាំគ្នាធ្វើដំណើរត្រឡប់មកស្រុកកំណើត។

# ស្ម័គ្រចិត្តបម្រើបដិវត្តន៍

នេន ស្រីមុំ



កុមារបដិវត្តន៍នៅក្នុងរបបខ្មែរក្រហម។ (បណ្ណសារ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រជាជនជាច្រើនបានស្ម័គ្រចិត្តចូលបដិវត្តន៍ដើម្បីគាំទ្រ សម្តេចព្រះ នរោត្តម សីហនុ ឡើងគ្រងអំណាចសារជាថ្មី។ ស្រុកព្រែកប្រសព្វនៃតំបន់ក្រចេះ បន្ទាប់ពីលោកសេនាប្រមុខ លន់ នល់ និងសហការីរបស់ខ្លួន ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីព្រះប្រមុខរដ្ឋ តំបន់ក្រចេះគឺជាតំបន់មួយក្នុងចំណោមតំបន់ជាច្រើននៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានយោធាខ្មែរក្រហមកាន់កាប់នៅក្នុងឆ្នាំ១៩៧០។ បន្ទាប់ពីរបបសាធារណរដ្ឋខ្មែរ ឡើងកាន់អំណាច បានធ្វើឱ្យប្រជាជនកម្ពុជាមានការមិនពេញចិត្តជាមួយនឹងការដឹកនាំរបស់លោកឧត្តមសេនីយ៍ លន់ នល់។

អ៊ី សុផានហៅ ចាតភេទស្រី កើតក្នុងឆ្នាំ១៩៦០។ សុផាន មានប្តីឈ្មោះ ស៊ុំ វ៉ាវុធ អាយុ៤៨ឆ្នាំ (២០០៦) និងមានកូនប្រុសម្នាក់។ សព្វថ្ងៃ សុផាន ប្រកបមុខរបរធ្វើស្រែចម្ការ រស់នៅភូមិស្រែស្តៅ ឃុំអូរឫស្សី ស្រុកក្រចេះ ខេត្តក្រចេះ។ សុផាន មានឪពុកឈ្មោះ អ៊ី យេន ហៅ ហាន ម្តាយឈ្មោះ ទុង ជឹម និងមានបងប្អូនចំនួន៦នាក់ ក្នុងនោះស្រី២នាក់ និងប្រុស៤នាក់។ សុផាន ធ្លាប់រៀនសូត្របានត្រឹមថ្នាក់ទី៧ (ចាស់) នៅសាលាបឋមសិក្សាឆ្នូង។

នៅឆ្នាំ១៩៧០ ក្រោយពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីអំណាច

ប្រទេសជាតិចាប់ផ្ដើមមានសង្គ្រាម និងមានយន្តហោះមកទម្លាក់គ្រាប់បែក។ កងកម្លាំងបដិវត្តន៍ខ្មែរក្រហមក៏លេចចេញជារូបរាង ដោយមានយុវជន យុវនារីកម្ពុជាជាច្រើន បានចូលស្ម័គ្រចិត្តបម្រើបដិវត្តន៍ ដោយមិនបានដឹងច្បាស់ទេថា ចលនានោះជាចលនាបដិវត្តន៍របស់ខ្មែរក្រហម ព្រោះយកឈ្មោះរបស់សម្ដេចព្រះ នរោត្តម សីហនុ បាំងមុខ ដើម្បីទាញឱ្យយុវជន យុវនារីចូលរួមបដិវត្តន៍របស់ខ្លួន។

នៅឆ្នាំ១៩៧៣ មានកម្លាំងយុវជន យុវនារីមួយចំនួនធំបានចូលធ្វើជាយោធាខ្មែរក្រហម ហើយខ្លះទៀតទៅធ្វើជាកងចល័ត។ នៅពេលនោះ យុវជន និងយុវនារី មិនសូវនៅផ្ទះនោះទេ ព្រោះត្រូវចេញទៅធ្វើការនៅកងចល័ត នៅផ្ទះភាគច្រើនគឺជាអ្នកដែលមានគ្រួសាររួចហើយ។ ចំណែកឯ សុផាន ត្រូវបានជម្លៀសទៅកាន់ឃុំចំបក់ ហើយបានស្ម័គ្រចិត្តចូលបម្រើចលនាខ្មែរក្រហម។ មុនដំបូងអង្គការចាត់តាំងឱ្យគាត់ធ្វើការនៅក្នុងកងកុមារនៅឃុំចំបក់ មើលថែទាំ និងបង្រៀនអក្សរកុមារខ្លះៗ ព្រមទាំងដឹកនាំឱ្យកុមារទាំងអស់នោះធ្វើការងារ ដូចជាកើបអាចម៍គោ កាប់ទន្ទ្រានខែត្រ យកទៅធ្វើជីដាក់ស្រែ។ នៅក្នុងកងនោះមានកុមារចន្លោះពី ៥០នាក់ទៅ ៦០នាក់។ អង្គការបានបែងចែកឱ្យយុវជននៅមួយកង និងយុវនារីនៅមួយកងដាច់ដោយឡែកពីគ្នា។ អង្គការមិនបានអនុញ្ញាតឱ្យ បុរស និងស្ត្រីមានទំនាក់ទំនងជាមួយគ្នាឡើយ សូម្បីតែជាបងប្អូននឹងគ្នាក៏មិនអនុញ្ញាតឱ្យស្គាល់គ្នាដែរ គឺត្រូវផ្ដាច់មនោសញ្ចេតនាពីគ្រួសារទាំងអស់។

នៅឆ្នាំ១៩៧៤ សុផាន ត្រូវបានអង្គការបញ្ជូនទៅសមរភូមិវាយជាមួយទាហាន លន់ នល់ តាមផ្លូវព្រែកក្ដាម ព្រែកព្នៅ វាយសម្រុកចូលទីក្រុងភ្នំពេញ។ កាលនោះ សុផាននៅក្នុងកងពលទី១ ប្រធានកងពលឈ្មោះ អឿន។ សុផាន ត្រូវបានអង្គការបញ្ជូនទៅកាន់ទីក្រុងភ្នំពេញហើយឱ្យធ្វើដំណើរដោយថ្មើរជើង មិនមានឡានសម្រាប់ដឹកជញ្ជូនឡើយ។ ទៅដល់វត្តជើងព្រៃ ផ្លូវទៅទីក្រុងភ្នំពេញ អង្គការបានឱ្យ សុផាន ចូលធ្វើការនៅក្នុងកងសែងគ្រាប់កាំភ្លើង គ្រាប់បែក និងសែងអ្នករបួស ព្រមទាំងសាកសព។

ឈានចូលដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥



កងកុមារធ្វើការនៅតាមការដ្ឋានលើកទំនប់និងជីកប្រឡាយ នៅក្នុងរបបខ្មែរក្រហម។ (បណ្ណសារ មជ្ឈមណ្ឌលឯកសារកម្ពុជា)

កម្លាំងយោធាខ្មែរក្រហម បានវាយចូលដល់ទីក្រុងភ្នំពេញ ពេលនោះខ្មែរក្រហមបានប្រាប់ឱ្យប្រជាជនចាកចេញពីផ្ទះសម្បែង។ ចលនាផ្លាស់ទីចេញពីទីក្រុងភ្នំពេញនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រព្រឹត្តទៅក្នុងស្ថានភាពចលាចលគួរឱ្យភ័យខ្លាច និងដោយបន្ទាន់។ ប្រជាជនត្រូវបានប្រាប់ឱ្យធ្វើដំណើរចេញពីផ្ទះសម្បែងរបស់ខ្លួនដោយគ្មានការលើកលែង។ ទោះបីយ៉ាងណាការប្រយុទ្ធតតាំងគ្នារវាងកងកម្លាំង លន់ នល់ និងខ្មែរក្រហម កើតឡើងនៅកន្លែងមួយផ្សេង ដែលជាហេតុបណ្តាលឱ្យមានការកាត់ផ្តាច់ផ្លូវចេញពីទីក្រុង បណ្តាលឱ្យសមាជិកនៃគ្រួសារខ្លះ មិនអាចចាកចេញពីទីក្រុងជាមួយគ្នាបាន ។ ខ្មែរក្រហមបានប្រើហេតុផល ៤យ៉ាងក្នុងការបន្ទំប្រជាជនឱ្យចាកចេញពីទីក្រុងភ្នំពេញគឺ ទី១) អង្គការ និងបក្សត្រូវការបោសសម្អាតខ្មាំង ២) រៀបចំឱ្យសមស្របតាមគោលការអង្គការបក្សកំណត់ទុក ៣) អង្គការបក្សមានតួនាទីការពារអាយុជីវិត និងការពារទីក្រុងឱ្យគង់វង្ស និង៤) អង្គការបក្សដឹងមុនថា មានខ្មាំងអាមេរិកកាំង និងបរិវាររៀបចំកម្ទេចទីក្រុងរបស់យើងដោយប្រើយន្តហោះធុនធំៗជាងមុនទៅទៀត។

នៅពេលប្រជាជនចេញអស់ យោធាមួយខ្មែរក្រហមចំនួនបាននៅយាមទីក្រុងភ្នំពេញ និងចាំបោសសម្អាតទីក្រុង មួយចំនួនទៀតបានទៅការពារព្រំដែន ខ្លះបានទៅធ្វើស្រែនៅជាយក្រុងភ្នំពេញ។ បន្ទាប់ពីប្រជាជនបានចាកចេញពីទីក្រុងភ្នំពេញ កងពលរបស់ សុផាន មិនទាន់បានចូលទៅក្នុងក្រុងឡើយ គឺនៅតាមជាយក្រុង។ សុផាន បានផ្លាស់ពីកងពលតូចទី១ ទៅកងពលធំ៣១០ វិញ ដែលមាន អឿន ជាប្រធានកងពលដដែល។ ក្រោយពីបានផ្លាស់ប្តូរកងពលរួចមក អង្គភាពរបស់ សុផាន ត្រូវបានអង្គការចាត់តាំងឱ្យធ្វើស្រែនៅម្តុំកប់ស្រូវ បឹងបាយាប និងតំបន់មួយចំនួននៅជាយទីក្រុងភ្នំពេញ។

ឆ្នាំ១៩៧៧ ប្រធានកងពលឈ្មោះ អឿនត្រូវបានអង្គការចាប់ខ្លួនបញ្ជូនទៅគុកទួលស្លែង ដោយចោទថា ក្បត់នឹងអង្គការ ចូលជាភ្នាក់ងារសម្ងាត់ សេ-អ៊ី-អា ជាមួយអាមេរិកាំង។ ក្រៅពី អឿន ដែលជាប្រធានកងពល នៅមានកម្មាភិបាល និងយោធាមួយចំនួនក៏បាត់ខ្លួនដែរ។ ក្រោយពីចាប់ប្រធានកងពលយោធា ទាំងអស់នៅក្នុងកងពល៣១០ សុទ្ធតែជាប់និន្នាការនយោបាយ ហើយបានបញ្ជូនខ្លួនទៅលត់ដំនៅភូមិភាគបូព៌ា។ ភូមិភាគបូព៌ា (ភូមិភាគ២០៣) ដឹកនាំដោយ សោ ភឹម ដែលបានធ្វើអត្តឃាតនៅខែឧសភា ឆ្នាំ១៩៧៨។ ភូមិភាគនេះរួមមានខេត្តព្រៃវែង និងខេត្តស្វាយរៀង ទាំងមូល ផ្នែកខ្លះនៃខេត្តកំពង់ចាមដែលស្ថិតនៅត្រើយខាងឆ្វេងទន្លេមេគង្គ ទាំងអស់ ស្រុកឆ្លូងក្នុងខេត្តក្រចេះ និងស្រុកចំនួន៣ ក្នុងខេត្តកណ្តាល រួមមានស្រុកខ្សាច់កណ្តាល ស្រុកល្វាឯម និងស្រុកមុខកំពូល។ ភូមិភាគនេះចែកចេញជា៥តំបន់ រួមមាន៖ តំបន់២០ តំបន់២១ តំបន់២២ តំបន់២៣ និងតំបន់២៤ ។

នៅឆ្នាំ១៩៧៨ ភូមិភាគបូព៌ា ត្រូវស្ថិតនៅក្នុងភូមិភាគដែលត្រូវកម្ទេចរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ នៅខែមករា និងកុម្ភៈក្រោយពេលដែលការប្រយុទ្ធមានភាពធូរស្រាលនៅតាមព្រំដែនមជ្ឈិមបានចាប់ផ្តើមចាប់ខ្លួនកម្មាភិបាលរបស់ភូមិភាគបូព៌ាជាច្រើននាក់។ សោ ភឹម បានដឹងយឺតពេលទៅហើយ ថាគាត់ជាកម្មវត្ថុនៃកិច្ចប្រតិបត្តិតាមកម្ទេច។ អង្គការថ្នាក់លើបានស្តីបន្ទោសឱ្យគាត់ចំពោះបរាជ័យ ដែលកងទ័ពរបស់កម្ពុជា ពុំបានសម្រេចកម្ចាត់កងទ័ពវៀតណាមឱ្យវិនាសសាបសូន្យ។ បក្សបានចោទប្រកាន់គាត់ជាសមាជិកនៃ «បក្សលួចលាក់របស់វៀតណាម» ដែលបញ្ចូលមកក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ក្នុងពេលដែលភូមិភាគបូព៌ាត្រូវបង្ខំមកឱ្យយោធាខ្មែរក្រហមភូមិភាគនិរតីមកគ្រប់គ្រង។

យោធាខ្មែរក្រហមមកពីភូមិភាគនិរតី បានប្រើប្រជាជនឱ្យធ្វើការជាទម្ងន់លើសពីកម្លាំងដែលប្រជាជនអាចធ្វើបាន មិនត្រឹមតែប៉ុណ្ណោះអង្គការ

ក៏បានរឹតបន្តឹងរបបអាហាររបស់ប្រជាជនៗ សុផានបានបន្ថែមថា នៅពេលនោះ អង្គការមិនផ្តល់ចានឱ្យប្រជាជនសម្រាប់ដាក់អាហារឡើយ ហើយដល់ម៉ោងត្រូវហូបអាហារ អង្គការបានផ្លុំកញ្ចែ ដើម្បីផ្តល់ជាដំណឹងៗ ពេលដែលឮសំឡេងកញ្ចែ ប្រជាជនគ្រប់រូបបាននាំគ្នាស្រវារត់ទៅបេះស្លឹកឈូក យកទៅដាក់បាយជំនួសចានៗ ចំពោះរបបអាហារដែលប្រជាជនទទួលបានគឺមានតែបបររាវៗ ដែលមានទឹកច្រើនជាងគ្រាប់អង្ករ លាយជាមួយនឹងសម្លព្រលិត និងត្រកួនៗ សម្លទាំងនោះភាគច្រើនមានតែបន្លែមិនសូវមានសាច់ត្រីៗ

ប្រជាជននៅភូមិភាគបូព៌ា តែងតែត្រូវអង្គការចាប់ខ្លួនទៅជារឿយៗៗ ការនាំខ្លួនទៅបែបនេះបានធ្វើឱ្យប្រជាជនមួយចំនួនទៀត មានចម្ងល់ និងដក់ជាប់នៅក្នុងចិត្តថាអង្គការចាប់យកប្រជាជនទៅ ទីណា បន្ទាប់ពីការបាត់ខ្លួនប្រជាជនអស់ជាច្រើននាក់ ហើយមិនដែលឃើញត្រឡប់មកវិញៗ ប្រជាជនមូលដ្ឋានបានដឹងច្បាស់ថា អង្គការយកទៅសម្លាប់ចោល មិនមែនដូចពាក្យដែលអង្គការប្រាប់ថា ដោយសារតែនៅសហករណ៍ផ្សេងត្រូវការកម្លាំងបន្ថែម, រៀនសូត្រ, ផ្លាស់ប្តូរទីលំនៅថ្មី ឬកសាងៗ ហេតុផលទាំងប៉ុន្មានគឺជាហេតុផលដែលខ្មែរក្រហមតែងតែប្រើនៅពេលចាប់ខ្លួននរណាម្នាក់យកទៅសម្លាប់ៗ យើងឃើញថា ខ្មែរក្រហមបានសម្លាប់ប្រជាជនស្លូតត្រង់អស់ជាច្រើន ពេលយោធានិរតីចូលមកគ្រប់គ្រងភូមិភាគបូព៌ា ៗ មានប្រជាជនជាច្រើនដែលត្រូវចោទប្រកាន់ថាជាជនក្បត់ដោយសារតែខ្សែស្រឡាយ និងមានសាច់ញាតិជាជនជាតិវៀតណាម និងប្រជាជនមួយចំនួនទៀតដែលគ្រាន់តែធ្វើឱ្យបាក់ចបបង្គីឬរបស់របរមួយចំនួនទៀតដែលអង្គការបានផ្តល់ឱ្យក៏ត្រូវចាប់យកទៅសម្លាប់ដោយមិនលើកលែងៗ

នៅឆ្នាំ ១៩៧៩ កងទ័ពវៀតណាមវាយសម្រុកចូលមក ធ្វើឱ្យយោធាខ្មែរក្រហមស្លាប់និងរបួសអស់ពាន់នាក់ៗ សុផានបានរត់ចូលព្រៃចម្ការកៅស៊ូ និងរត់បន្តរហូតទៅដល់ព្រំដែនថៃ ដើម្បីគេចចេញពីសង្គ្រាមរវាងយោធាខ្មែរក្រហម និងកងទ័ពវៀតណាមៗ ដល់ឆ្នាំ១៩៨០ សុផានបានត្រឡប់មកស្រុកកំណើតវិញ និងរស់នៅជួបជុំជាមួយគ្រួសាររបស់គាត់ជាថ្មីម្តងទៀតៗ



កងកុមារចេញទៅធ្វើការនៅតាមការដ្ឋានលើកទំនប់ជីកប្រឡាយនៅក្នុងរបបខ្មែរក្រហមៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជុំ សារឹម ៖ ប្រធានពេទបាយ

សោម ប៊ុនថន

ខ្ញុំឈ្មោះ ជុំ សារឹម កើតឆ្នាំ១៩៤៦ កើតនៅភូមិកំពង់អំពិល ឃុំកំពង់អំពិល ស្រុករំដួល ខេត្តស្វាយរៀង។ សព្វថ្ងៃខ្ញុំរស់នៅភូមិស្វាយរំពារ ឃុំសង្កែ ស្រុករំដួល ខេត្តស្វាយរៀង។ ខ្ញុំមានប្រពន្ធឈ្មោះ សួស សួន និងមានកូនចំនួន៨នាក់ គឺប្រុស ៧នាក់ និងស្រីម្នាក់។



ជុំ សារឹម សព្វថ្ងៃរស់នៅភូមិកំពង់អំពិល ឃុំកំពង់អំពិល ស្រុករំដួល ខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីតូច ខ្ញុំចូលរៀននៅសាលានៅវត្តសង្កែ រយៈពេល៣ឆ្នាំក៏ផ្លាស់ទៅរៀននៅសាលាបឋមសិក្សាម្រាក ស្ថិតនៅភូមិស្វាយចេក ឃុំស្វាយចេក ស្រុករំដួលវិញ។ ខ្ញុំរៀនដល់ថ្នាក់ទី៩ ពីសង្គមចាស់ក៏ឈប់រៀន។ បន្ទាប់មក ខ្ញុំធ្វើជាកម្មករផលិតសាច់ក្រកលក់នៅផ្សារត្រើយតាហោ ស្ថិតនៅក្នុងសង្កាត់ពោធិ៍តាហោ ក្រុងស្វាយរៀង ខេត្តស្វាយរៀង ដើម្បីយកប្រាក់ឱ្យប្អូនរបស់ខ្ញុំរៀន។ នៅសម័យនោះ រដ្ឋាភិបាលប្រកាសជ្រើសរើសទាហាន (១៨ខែ) ហើយខ្ញុំបានស្ម័គ្រចូល។ បន្ទាប់មកទើបអង្គភាពទាហានបានបញ្ជូនខ្ញុំឱ្យទៅហ្វឹកហាត់រយៈពេល៣ខែ ដែលមានមេបញ្ជាការខេត្តស្វាយរៀងឈ្មោះ សោហោ។ នៅអំឡុងពេលហ្វឹកហាត់នោះ អង្គភាពបានចាត់តាំងខ្ញុំឱ្យកាន់បដា ដែលសរសេរថា ដេញវៀតកុងចេញពីទឹកដីកម្ពុជាឱ្យអស់ ដើរដង្ហែ។ ខ្ញុំកាន់បដានោះដើរទៅកាន់បន្ទាយកងទ័ពវៀតកុង (វៀតណាមខាងជើង) ដែលបោះនៅតាមព្រំដែនស្ថិតនៅភូមិកំពោតទូក ឃុំគគីសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង។ ពេលទៅដល់បន្ទាយវៀតកុង កងទ័ពវៀតកុងបានដេញចាប់ខ្ញុំ ឃើញដូច្នេះខ្ញុំភិតភ័យយ៉ាងខ្លាំងក៏ទម្លាក់បដាចោល ហើយរត់ទៅលាក់ខ្លួននៅក្នុងកុដិព្រះសង្ឃ នៅក្នុងវត្តគគីសោម។ ពេលទទួលបានដំណឹងថាវៀតកុងដេញចាប់ខ្ញុំ ម្ដាយរបស់ខ្ញុំបារម្ភយ៉ាងខ្លាំង ហើយទៅយកខ្ញុំត្រឡប់មកផ្ទះវិញ។

មិនយូរប៉ុន្មាន លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ធ្វើឱ្យស្រុកភូមិខ្ញុំមានភាពច្រួលច្របល់យ៉ាងខ្លាំង។ អំឡុងពេលចលាចលនោះ ឪពុកម្ដាយរបស់ ខ្ញុំក៏រៀបការប្រពន្ធឱ្យខ្ញុំ ទាំងយើងមិនដែលស្គាល់គ្នាពីមុនមកទេ។ ប្រពន្ធខ្ញុំរស់នៅភូមិស្វាយរំពារ ឃុំសង្កែ ស្រុករំដួល ខេត្តស្វាយរៀង។

សម័យនោះ ឪពុកម្ដាយខាងស្រីមិនបន្ដាប់បណ្ណាការទេ ពេលឪពុកម្ដាយខាងប្រុសចូលស្ដីដណ្ដឹង គឺស្រេចលើខាងប្រុសជូនៗ ឪពុកម្ដាយខាងស្រីចង់ឱ្យកូនស្រីរៀបការ ព្រោះប្រទេសកំពុងវឹកវរ ហើយភ័យខ្លាចយួនចូលមកធ្វើបាប និងប្រព្រឹត្តអំពើពាលាមកលើកូនស្រីរបស់ខ្លួនៗ ទន្ទឹមនោះ ឪពុកម្ដាយរបស់ខ្ញុំក៏ផ្សំផ្គុំបងស្រីខ្ញុំឱ្យបងប្រុសបង្កើតប្រពន្ធរបស់ខ្ញុំដែរ។ បន្ទាប់ពីខ្ញុំរៀបការរួច ខ្ញុំរកស៊ីដឹកជ្រូកមានទាយកទៅលក់នៅប្រទេសវៀតណាម (ខាងត្បូង) ដើម្បីចិញ្ចឹមក្រុមគ្រួសារ។ នៅអំឡុងពេលនោះ កងទ័ពវៀតកុង (វៀតណាមខាងជើង) បានចូលមកចងអង្រឹងដេកនៅក្រោមផ្ទះរបស់ខ្ញុំ ហើយកងទ័ពរំដោះខ្មែរក្រហមក៏ចូលមករស់នៅលាយឡំជាមួយប្រជាជននៅក្នុងភូមិដែរ។ នៅពេលកងទ័ព ធីវគី ចូលមក កងទ័ពវៀតកុងបានលាក់ខ្លួន ហើយកងទ័ពរំដោះខ្មែរក្រហមក៏លាក់កាំភ្លើងកុំឱ្យធីវគីដឹងដែរ ចំណែកខ្ញុំបានរត់គេចចេញពីភូមិ។ នៅថ្ងៃមួយក្នុងឆ្នាំ១៩៧០ ពេលខ្ញុំភ្ញាក់ឡើងស្រាប់តែឃើញកងទ័ព លន់ នល់ និងរថក្រោះធីវគី ប្រមាណ៤០គ្រឿង មកឈប់តម្រៀបជាជួរនៅក្នុងភូមិ និងមានយន្តហោះត្រៀមប្រយុទ្ធជាមួយកងទ័ពវៀតកុង ឃើញដូច្នេះខ្ញុំក៏ទៅលែងគោ ព្រោះខ្លាចត្រូវគ្រាប់ផាប់ ហើយខ្ញុំក៏គេចខ្លួនទៅខាងជើងភូមិ។ អំឡុងពេលនោះគឺមានការវាយប្រយុទ្ធគ្នារយៈពេល៣យប់៣ថ្ងៃ ហើយយន្តហោះម៉ាកអែសហុងតូមរបស់ធីវគីក៏មកទម្លាក់គ្រាប់បែកបណ្ដាលឱ្យកងទ័ពវៀតកុង ខ្មែរក្រហម រួមទាំងប្រជាជនស្លាប់យ៉ាងច្រើន។ ចំណែកខាងធីវគី និង លន់ នល់ ក៏ស្លាប់ដែរ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនមកពីខេត្តស្វាយរៀង ក្រុងភ្នំពេញ និងប្រជាជនមួយចំនួនទៀតមកពីខេត្តក្រចេះ ខេត្តកំពង់ចាម ឱ្យមករស់នៅស្រុករំដួល។ មកដល់ដំបូង មេភូមិបានសួរនាំអ្នកដែលជម្លៀសមកថ្មីទាំងនោះអំពីស្រុកកំណើត និងប្រវត្តិរូប។ មេភូមិបានកត់ត្រាឈ្មោះប្រជាជនថ្មីទាំងនោះក្នុងបញ្ជីដាច់ដោយឡែកពីប្រជាជនមូលដ្ឋាន។ ប្រជាជនថ្មីទាំងនេះគ្មានសិទ្ធិសេរីភាពដូចប្រជាជនមូលដ្ឋានឡើយ និងមិនត្រូវបានជ្រើសរើសឱ្យឈរឈ្មោះជាប្រធានក្រុម ឬសមាជិកក្រុមទេ។ រីឯអ្នកដែលធ្លាប់ធ្វើជាទាហាន លន់ នល់ និងមានឋានន្តរស័ក្ដិត្រូវបានខ្មែរក្រហមប្រកាសឱ្យមកចុះឈ្មោះ នៅក្នុងភូមិ ហើយឱ្យរស់នៅជាមួយប្រពន្ធកូនដាច់ដោយឡែកពីប្រជាជនមូលដ្ឋាន។ នៅពេលយប់ ឈ្លបខ្មែរក្រហមបានចាប់អ្នកធ្លាប់ធ្វើទាហាន លន់ នល់ ទាំងនោះយកទៅវាយសម្លាប់ចោលនៅព្ររបោះ ជិតវត្តកំពង់អំពិល។ ឈ្លបខ្មែរក្រហមមកចាប់អ្នកដែលមានឋានន្តរស័ក្ដិធំៗយកទៅសម្លាប់មុន ហើយអ្នកដែលមានឋានន្តរស័ក្ដិតូចទៅសម្លាប់តាមក្រោយៗ។ ចំណែកប្រពន្ធកូននិងសមាជិកគ្រួសាររបស់ទាហាន លន់ នល់ ទាំងនេះ ឈ្លបខ្មែរក្រហមមិនទាន់សម្លាប់ទេ គឺចាត់តាំងឱ្យទៅធ្វើការងារតាមកងជាមួយប្រជាជនមូលដ្ឋាននៅក្នុងភូមិ ដោយមានឈ្មោះ ចាន់ ស៊ឹម គឺជាប្រធានភូមិស្វាយរំពារ។ ចំណែកគណៈឃុំសង្កែឈ្មោះ សៅ ធី, តមកមានឈ្មោះ ញាល់, ប្រាជ្ញ សុន, ភឹម, ហ៊ុនយន និង យឿង ដែលក្រោយមកគណៈឃុំទាំងនេះត្រូវបានចាប់ខ្លួនទាំងអស់។

ចំណែកខ្ញុំ ខ្មែរក្រហមចាត់តាំងឱ្យធ្វើជាប្រធានក្រុមនៅកងរោងបាយ ទី២។ នៅក្នុងភូមិស្វាយរំពារមានកងរោងបាយចំនួន២ គឺកងរោងបាយ ទី១ មានឈ្មោះ នាង វុន ប្រធានកង និងកងរោងបាយ ទី២ មានខ្ញុំគឺជាប្រធាន។ នៅកងរោងបាយ ទី២របស់ខ្ញុំ មានប្រជាជនប្រមាណជាង៥០គ្រួសារ ហើយខ្ញុំគឺជាអ្នកមើលការខុសត្រូវលើការហូបចុករបស់ប្រជាជន។ ចំណែករបបអាហារគឺប្រធានសហករណ៍គឺជាអ្នកកំណត់ ហើយក្នុងមួយភូមិមានសហករណ៍មួយ។ ប្រធានសហករណ៍ចែករបបអង្ករកន្លះកំប៉ុងសម្រាប់មនុស្សពេញវ័យម្នាក់ក្នុងមួយពេល ចំណែកក្មេងៗចំនួន១០នាក់ទទួលបានរបបអង្ករ២កំប៉ុងក្នុងមួយពេល។ នៅសម័យនោះ មានការខ្វះខាតអំបិលយ៉ាងខ្លាំង ដូច្នេះសហករណ៍ចែកអំបិលឱ្យ

រោងបាយតិចតួចប៉ុណ្ណោះ។ នៅពេលបានអំបិលមកម្តងៗអ្នកដាំបាយបានលួចលាក់អំបិលទុកខ្លះ ដូច្នេះមិនមានអំបិលគ្រប់គ្រាន់ហូបឡើយ។ ក្រៅពីអង្ករនិងអំបិល ប្រធានសហករណ៍បានចាត់តាំងក្រុមខាងសេដ្ឋកិច្ចឱ្យដើររកត្រីដើម្បីយកមកបែងចែកឱ្យកងរោងបាយរបស់ខ្ញុំ។ ខ្មែរក្រហមបានអនុញ្ញាតឱ្យសហករណ៍កាប់គោក្របីធ្វើម្ហូបក្នុងមួយឆ្នាំពីដង គឺពេលបុណ្យភ្ជុំ និងពេលចូលឆ្នាំខ្មែរ។ ក្រៅពីការងារនៅរោងបាយ ខ្ញុំបានដឹកនាំប្រជាជនក្នុងកងចុះស្ទូងស្រូវពីម៉ោង៥ល្ងាច ដល់ម៉ោង១០យប់ ដើម្បីប្រឡងប្រណាំងគ្នាតាមដែនការរបស់ឃុំនិងស្រុក ហើយរបបអាហារសម្រាប់កងចូលរួមប្រឡងនោះគឺខ្ញុំបើកបានកន្ទក់យកមកស្ងោរឱ្យហូប។ នៅពេលព្រឹកកងរបស់ខ្ញុំចាប់ផ្តើមស្ទូងពីម៉ោង៦ព្រឹក រហូតដល់ម៉ោង១២ ទើបឈប់សម្រាកហូបអាហារ បន្ទាប់មកត្រូវទៅរែកកណ្តាប់ដើម្បីស្ទូងនៅម៉ោង៥ល្ងាចបន្តទៀត។ ជារឿយៗបន្ទាប់ពីធ្វើការងាររចប់ ខ្ញុំបានដឹកនាំសមាជិកនៅក្នុងកងទៅប្រជុំនៅសហករណ៍ ដើម្បីអប់រំនិងកសាង ហើយត្រួតពិនិត្យសមាជិកកង មិនឱ្យនរណាម្នាក់ទំនេរឡើយ។ ប្រសិនបើសមាជិកកងណា ត្រូវបានរកឃើញថាបានប្រព្រឹត្តកំហុស គឺខាងសន្តិសុខប្រាប់ទៅមេភូមិឱ្យហៅអ្នកដែលបានប្រព្រឹត្តកំហុសនោះទៅប្រជុំណែនាំនៅសហករណ៍ ហើយចាប់ខ្លួនតែម្តង។ ជាក់ស្តែងនៅឆ្នាំ១៩៧៦ ឈ្មោះ ហន គឺជាសន្តិសុខភូមិបានរិះគន់មេភូមិស្វាយរំពារឈ្មោះ ចាន់ ស៊ុម ដែលជាមិត្តភក្តិរបស់ប្រធានសន្តិសុខស្រុករំដួលឈ្មោះ សៅ សារ៉េត ថាមិនបានគ្រប់គ្រងលើការដកសំណាបយកទៅឱ្យប្រជាជនតាមកងស្ទូងឱ្យបានគ្រប់គ្រាន់ ខណៈនោះស្រាប់តែសន្តិសុខស្រុកមកចាប់ចង ហន ដោយចោទថាប្រឆាំង នៅមុខអង្គប្រជុំនៅសហករណ៍សង្កែតែម្តង។ បន្ទាប់មក សន្តិសុខស្រុកក៏បញ្ជូន ហន ទៅមន្ទីរសន្តិសុខពពកវិល។ ក្រៅពីដឹកនាំប្រជាជនធ្វើការងារ នៅរោងបាយរបស់ខ្ញុំមានអ្នកចិញ្ចឹមជ្រូកចំនួន១០០ក្បាល ហើយពេលខ្លះអ្នកធ្វើការក្នុងរោងបាយលួចជ្រូកយកទៅសម្លាប់យកសាច់ហូប ដូច្នេះខ្ញុំក៏រាយការណ៍ទៅសហករណ៍ថា ជ្រូកធំៗបានស៊ីជ្រូកតូចដើម្បីកុំឱ្យសហករណ៍ចាប់កំហុស។

នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតី បានមកចាប់កម្មាភិបាលភូមិឃុំស្រុក និងចាប់ប្រធានសហករណ៍ច្រកបាវ រួចហើយដាក់លើរថយន្តអាហ្វ៊ីបអាដី ដែលមានសរសេរអក្សរលើជញ្ជាំងរថយន្តថា រថយន្តដឹកជនក្បត់០០៣និង០០៤។ ជាក់ស្តែង ខ្ញុំឃើញកងសន្តិសុខមកចាប់ឈ្មោះ យឿង គណៈឃុំសង្កែនៅមុខខ្ញុំតែម្តង គឺនៅមុនពេលសន្តិសុខដឹកចេញទៅ យឿង បានហុចក្រមាមកឱ្យខ្ញុំ និងនិយាយមកកាន់ខ្ញុំថា ឪស្លាប់ហើយ។ បន្ទាប់ពីកម្មាភិបាលមកពីភូមិភាគនិរតីចាប់កម្មាភិបាលចាស់ៗនៅស្រុករំដួលអស់ ខ្មែរក្រហមបានដាក់កម្មាភិបាលមកពីនិរតីមកដឹកនាំជំនួសវិញ ហើយខ្ញុំក៏មិនស្គាល់អ្នកទាំងអស់នោះដែរ។

នៅរដូវវស្សា ឆ្នាំ១៩៧៧ កម្មាភិបាលមកពីភូមិភាគនិរតីបញ្ជូនខ្ញុំនិងគ្រួសារឱ្យទៅរស់នៅ និងធ្វើស្រែនៅកំពង់សឹង ស្រុកព្រះស្តេច ខេត្តព្រៃវែង។ រហូតដល់ស្រូវចេញផ្កា ទើបខ្មែរក្រហមជម្លៀសខ្ញុំនិងគ្រួសារទៅជិះស្រឡាងនៅអ្នកលឿង ទៅឈប់នៅច្បារអំពៅ ក្នុងក្រុងភ្នំពេញ។ ខ្ញុំដេកនៅច្បារអំពៅមួយយប់។ លុះព្រឹកឡើងខ្មែរក្រហមចែកបាយមួយកញ្ចប់ ក្រមាខៀវមួយ អាវខៀវមួយ និងខោខ្មៅមួយឱ្យខ្ញុំ។ នៅពេលល្ងាចថ្ងៃដដែល ខ្មែរក្រហមយករថយន្តមកដឹកខ្ញុំ និងគ្រួសារទៅដាក់នៅចំណតរថភ្លើងក្នុងក្រុងភ្នំពេញ ដើម្បីជិះរថភ្លើងបន្តទៅឈប់នៅស្វាយដូនកែវ ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់។ បន្ទាប់មកទើបខ្មែរក្រហមយករថយន្តមកដឹកខ្ញុំនិងគ្រួសារទៅដាក់នៅសហករណ៍កូនក្អែក ស្ថិតនៅក្នុងឃុំមោងឬស្សី ស្រុកមោងឬស្សី ខេត្តបាត់ដំបង តំបន់២ ភូមិភាគពាយ័ព្យ។ នៅទីនោះ ខ្ញុំឃើញផ្ទះប្រជាជនជាច្រើនខ្នងទុកចោល និងមិនឃើញមានមនុស្សរស់នៅឡើយ។ ខ្ញុំក៏បានសួរប្រធានរោង

បាយដែលជាប្រជាជនមូលដ្ឋាននៅ ទីនោះថាតើម្ចាស់ផ្ទះទៅណាអស់ហើយ? ប្រធានរោងបាយប្រាប់ថា ស្លាប់អស់ហើយ ហើយបានសួរខ្ញុំវិញថាក្មួយមកពីខេត្តណា? ខ្ញុំក៏ប្រាប់ថាមកពីខេត្តស្វាយរៀង។ ព្រដូច្នេះប្រធានរោងបាយប្រាប់ខ្ញុំថា ប្រសិនបើខ្ញុំប្រាប់ថានៅស្វាយរៀងនឹងស្លាប់មិនខាន។ ភ្លាមនោះស្រាប់តែប្រធានសហករណ៍មកដល់ ហើយសួរថាតើមានប្រជាជនថ្មីប៉ុន្មានគ្រួសារ? ស្អែកត្រូវយកទៅអប់រំ។ ពេលព្រដូច្នេះ ខ្ញុំបានលួចឱ្យម្ជុល និងថ្មដែកកេះទៅប្រធានសហករណ៍ដើម្បីឱ្យជួយថែរក្សាខ្ញុំនិងគ្រួសារ។ បន្ទាប់មក ប្រធានសហករណ៍បានចាត់តាំងខ្ញុំឱ្យមើលថែទាំចម្ការក្រូច, ប្រពន្ធខ្ញុំនៅកងស្ទូង ហើយកូនតូចៗរបស់ខ្ញុំដើរកាត់ដើមទន្ទ្រានខែត្រ និងប្រមូលអាចម៍គោធ្វើជីដាក់ស្រែ។ នៅ ទីនោះប្រធានសហកណរ៍ចែករបបអង្ករពីរកំប៉ុងសម្រាប់មនុស្ស១០នាក់។ រាល់ថ្ងៃ ខ្ញុំតែងតែយកចិត្តប្រធានរោងបាយ និងប្រធានសហករណ៍ ដោយធ្វើសរសៃប្របាច់ជើងប្របាច់ដៃ និងច្រៀងឱ្យស្តាប់ ធ្វើឱ្យប្រធានរោងបាយនិងសហករណ៍ស្រឡាញ់ចូលចិត្តខ្ញុំយ៉ាងខ្លាំង។

ថ្ងៃមួយគណៈស្រុកឈ្មោះ ឡឿន និងប្រពន្ធឈ្មោះ សារីម បានមកដល់ចម្ការក្រូច និងបានហៅខ្ញុំទៅសួរថា ក្នុងចំណោមក្រូច២០ដើម តើមានក្រូចប៉ុន្មានដើមឆ្ងាញ់? ខ្ញុំឆ្លើយថា មានផ្លែក្រូចឆ្ងាញ់តែពីរដើមប៉ុណ្ណោះ ហើយខ្ញុំបាននាំគណៈស្រុកឈ្មោះ ឡឿន និងប្រពន្ធទៅមើលដើមក្រូចនោះ។ គណៈស្រុកឈ្មោះឡឿនបេះផ្លែក្រូចនោះហូប រួចហើយពេញចិត្តយ៉ាងខ្លាំង។

នៅពេលកងទ័ពពេលវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាចូលមករំដោះប្រទេសកម្ពុជា នៅដើមខែមករា ឆ្នាំ១៩៧៩ នៅសហករណ៍កូនក្អែករបស់ខ្ញុំគឺខ្មែរក្រហមនៅគ្រប់គ្រងនៅឡើយ។ លុះក្រោយមក ប្អូនថ្លៃរបស់ខ្ញុំឈ្មោះ ហែម ភី បានរត់ភៀសខ្លួនពីខ្មែរក្រហមក៏មកនៅជាមួយវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាវិញ។ ដូច្នេះសន្តិសុខខ្មែរក្រហមមកចាប់ខ្ញុំរួមទាំងប្រជាជន៩៦នាក់ផ្សេងទៀត។ នៅពេលយប់ប្រធានសន្តិសុខឈ្មោះ ជ្រឿន បានធាក់ខ្ញុំមួយជើង និងរុញខ្ញុំទៅកន្លែងឃុំឃាំង ហើយខ្ញុំក៏ស្រែកនិងក្រាញដោយផ្អែកនៅពាងទឹក។ ខណៈនោះប្រធានរោងបាយ និងប្រធានសហករណ៍ដែលនៅទីនោះដែរ ចំណាំសំឡេងខ្ញុំ ទារក៏ស្នើឱ្យប្រធានសន្តិសុខដោះលែងខ្ញុំ។ ខ្ញុំនិងគ្រួសារបានទៅលាក់ខ្លួននៅតាមព្រៃដោយដើររកត្រីយកមកហូប ហើយយប់ចូលដេកនៅក្នុងភូមិ។

នៅខែមិថុនា ឆ្នាំ១៩៧៩ ខ្ញុំនិងគ្រួសារ បានវិលត្រឡប់មកស្រុកកំណើតវិញ។ ពេលមកដល់ផ្ទះ ប្រជាជនក្នុងភូមិបានរាយការណ៍ឱ្យអាជ្ញាធរឃុំ និងកងទ័ពវៀតណាម ហើយអាជ្ញាឃុំនិងវៀតណាមបានហៅខ្ញុំទៅរៀននយោបាយ និងឃុំឃាំងខ្ញុំនៅឃុំកំពង់ចករយៈពេលមួយខែ ព្រោះខ្ញុំធ្លាប់ធ្វើជាប្រធានរោងបាយក្នុងរបបខ្មែរក្រហម។ នៅអំឡុងពេលនោះ មានកម្មាភិបាលវៀតណាមចំនួនពីរនាក់នៅគ្រប់គ្រងឃុំកំពង់ចក ចំណែកស្រុករំដួលក៏មានកម្មាភិបាលវៀតណាមគ្រប់គ្រងដែរ និងមានចំនួនច្រើនជាងឃុំ ដោយឡែកនៅក្នុងភូមិមិនមានវៀតណាមមកគ្រប់គ្រងទេ។ ក្រោយអាជ្ញាធរឃុំ និងកងទ័ពវៀតណាមដោះលែងខ្ញុំ ខ្ញុំក៏ចូលធ្វើឈ្លបឃុំ។ រយៈពេលមួយសប្តាហ៍ក្រោយមក រដ្ឋអំណាចឃុំបានឱ្យខ្ញុំធ្វើប្រវត្តិរូប និងចាត់តាំងខ្ញុំឱ្យធ្វើជាអនុប្រធានឈ្លបឃុំ គ្រប់គ្រងលើសមាជិក៣០នាក់។ ខ្ញុំធ្វើអនុប្រធានឈ្លបឃុំរយៈពេល៦ឆ្នាំ ទើបរដ្ឋអំណាចបញ្ជូនខ្ញុំឱ្យឡើងទៅវាយជាមួយខ្មែរក្រហម។ ក្រោយមក ខ្ញុំសុំលាឈប់ពីការងារឈ្លបឃុំវិញ។ បន្ទាប់ពីបោះឆ្នោតឆ្នាំ១៩៩៣ រដ្ឋាភិបាលបានជ្រើសរើសខ្ញុំឱ្យធ្វើជាមេភូមិ។ សព្វថ្ងៃខ្ញុំចូលនិវត្តន៍ហើយ ប៉ុន្តែខ្ញុំនៅជួយការងារភូមិ និងសមាជិកភូមិ។

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ចូលរួមក្នុងវេទិកាទេសចរណ៍មូស្លីមកម្ពុជាឆ្នាំ២០២៤ ដែលរៀបចំឡើងដោយក្រសួងទេសចរណ៍

*អេង សុខម៉េង*




*ឯកឧត្តម មហាំម៉ាត់ យូណោស អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ ប្រគល់បណ្ណសរសើរដល់អ្នកស្រី សូ ហ្វារីណា នាយករង មជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៤ នេះក្រសួងទេសចរណ៍បានរៀបចំវេទិកាទេសចរណ៍មូស្លីមកម្ពុជា ឆ្នាំ២០២៤ ក្រោមមូលបទ«ភាពស្រស់ស្អាតនៃសុខដុមនីយកម្ម និងគោលដៅទេសចរណ៍មូស្លីម» ជាលើកដំបូងរបស់ខ្លួន នៅសណ្ឋាគារភ្នំពេញ។ វេទិកានេះក៏មានការចូលរួមតាំងពិព័រណ៍ដូចជាសិប្បកម្ម សេវាកម្មនិងអាជីវកម្មផ្សេងៗ។

គម្រោង «សូត្រចាម» ឬ «ពណ៌នៃការចងចាំ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានចូលរួមដាក់តាំងបង្ហាញផលិតផលរបស់ខ្លួនមានដូចជា ក្រណាត់សូត្រ ហូល និងក្រមាដែលត្បាញដោយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជនជាតិចាមរស់នៅស្រុកកោះសូទិន ខេត្តកំពង់ចាម។

វេទិកានេះប្រារព្ធឡើងក្នុងគោលបំណង ដើម្បីបង្ហាញពីភាពចម្រុះនៃវប្បធម៌របស់ប្រទេសកម្ពុជា ចូលរួមផ្សព្វផ្សាយសក្តានុពលទេសចរណ៍សម្រាប់ទីផ្សារទេសចរណ៍មូស្លីម, ស្វែងរកឱកាសសម្រាប់ការវិនិយោគក្នុងវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចដើម្បីភាពងាយស្រួលដល់ទេសចរណ៍មូស្លីម, ពិនិត្យលទ្ធភាពរបស់ភាគីពាក់ព័ន្ធដើម្បីត្រៀមខ្លួនបំពេញ

នូវតម្រូវការដែលកំពុងកើនឡើងសម្រាប់ទីផ្សារទេសចរណ៍មូស្លីម, និងលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធដើម្បីបង្កើត និងអនុវត្តយុទ្ធសាស្ត្រសម្រាប់ជំរុញកំណើនទេសចរណ៍ប្រកបដោយបរិយាប័ន្ន និងនិរន្តរភាពនៅកម្ពុជា។

វេទិកាទេសចរណ៍មូស្លីមកម្ពុជា ឆ្នាំ២០២៤ ក្រោមមូលបទ «ភាពស្រស់ស្អាតនៃសុខដុមនីយកម្ម និងគោលដៅទេសចរណ៍មូស្លីម» ប្រារព្ធឡើងក្រោមអធិបតីភាពរបស់ ឯកឧត្តម ហួត ហាក់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍។ ឯកឧត្តមបានថ្លែងសុន្ទរកថាបើកអង្គវេទិកាដោយគូសបញ្ជាក់ថាភ្ញៀវទេសចរណ៍មូស្លីមជាគោលដៅអត្តិភាពមួយក្នុងចំណោមគោលដៅភ្ញៀវទេសចរដទៃៗទៀតសម្រាប់ក្រសួង។ ឯកឧត្តមបានរំឭកថា ក្នុងឆ្នាំ២០២៣ ភ្ញៀវទេសចរណ៍អន្តរជាតិដែលបានមកទស្សនាកម្ពុជាមានចំនួនប្រមាណជាង៥លាននាក់ ក្នុងនោះភ្ញៀវទេសចរមូស្លីមមានចំនួនប្រមាណជាង៣៦ម៉ឺននាក់។

ឯកឧត្តមថ្លែងបន្តថាភ្ញៀវទេសចរមូស្លីមតម្រូវឱ្យមានការគិតគូរដោយយកចិត្តទុកដាក់លើបញ្ហាផ្សេងៗដូចជា អាហារដ្ឋានហាឡាល កន្លែងថ្វាយបង្គំ និងកន្លែងស្នាក់នៅ ជាដើម។ ឯកឧត្តមក៏បានលើកឡើងពីផែនការអភិវឌ្ឍន៍ទេសចរណ៍មូស្លីម ៥ឆ្នាំ (២០២៣-២០២៧) ដែលសំដៅទៅដល់ការផ្សព្វផ្សាយ និងលើកកម្ពស់វិស័យទេសចរណ៍មូស្លីមឱ្យកាន់តែទូលំទូលាយបន្ថែមទៀត។

ប្រធានបទសំខាន់ៗរួមមាន៖ ការយល់ដឹងអំពីទីផ្សារទេសចរណ៍មូស្លីម និន្នាការ និងតម្រូវការទីផ្សារទេសចរណ៍មូស្លីមពិភពលោក, បេតិកភណ្ឌវប្បធម៌ និងពហុវប្បធម៌, ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងសេវាអាហារហាឡាល, កន្លែងថ្វាយបង្គំ និងកន្លែងស្នាក់នៅ ត្រូវបានលើកយកមកពិភាក្សាពីសំណាក់វាគ្មិនល្បីៗដែលអញ្ជើញមកពីក្រសួងទេសចរណ៍ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ សមាគមន៍មូស្លីមកម្ពុជា និងវិស័យឯកជននានា ដើម្បីស្វែងរកធាតុចូលបន្ថែមទៀតក្នុងការធ្វើឱ្យប្រសើរឡើងចំពោះទេសចរណ៍មូស្លីម។ វេទិកានេះក៏មានការចូលរួមពីប្រធានមន្ទីរទេសចរណ៍ រាជធានី-ខេត្ត ភ្ញៀវជាតិ ភ្ញៀវអន្តរជាតិ និស្សិតជំនាញទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធវិស័យទេសចរណ៍ជាច្រើនរយនាក់។

បន្ទាប់ពីកិច្ចពិភាក្សាត្រូវបានបញ្ចប់អ្នកចូលរួមបានទស្សនាស្តង់ពិព័រណ៍ជាច្រើន ដូចជា ស្តង់ពិព័រណ៍ម្ហូបអាហារ ផលិតផលក្នុងស្រុក សិប្បកម្ម សេវាកម្ម អាជីវកម្ម និងស្តង់ពិព័រណ៍ផលិតផលតម្បាញ «សូត្រចាម» ឬ «ពណ៌នៃការចងចាំ»។

គួររំឭកផងដែរថាគម្រោង «សូត្រចាម» ឬ «ពណ៌នៃការចងចាំ» ត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងឆ្នាំ២០២១ ដែលគាំទ្រផ្នែកហិរញ្ញវត្ថុដោយ ទីភ្នាក់ងារសហប្រតិបត្តិការ និងសម្របសម្រួលរបស់ប្រទេសតួកគី(TIKA) តាមរយៈស្ថានទូតតួកគីប្រចាំកម្ពុជា។ គោលបំណងនៃគម្រោងនេះគឺដើម្បីថែរក្សាស្នាដៃត្បាញសូត្រ ការប្រើប្រាស់ពណ៌ និងគោម តាមរយៈការចងចាំរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងអាចបង្កើតប្រាក់ចំណូលសម្រាប់សហគមន៍។ គោលដៅគម្រោងសូត្រចាមនេះ គឺធ្វើយ៉ាងណាឱ្យមានការរំឭកឡើងវិញ និងទទួលស្គាល់អំពីស្នាដៃតម្បាញនេះ ទាំងក្នុង និងក្រៅប្រទេស។



ឯកឧត្តម ហួត ហាក់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងគណៈប្រតិភូ ទស្សនាពិព័រណ៍សូត្រចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


CAMBODIA MUSLIM FRIENDLY TOURISM FORUM 2024
UNDER THE THEME
"THE BEAUTY OF HARMONIZATION AND MUSLIM FRIENDLY
TOURISM DESTINATIONS"











# អនាគតដែលត្រូវឆក់យកទៅៈ ភូមិអូរស្វាយ និងការបំផ្លិចបំផ្លាញនៃអំពើប្រល័យពូជសាសន៍

**សម្បត្តិ សុណិសា**



ហ៊ឹម ហ៊ុយ អតីតប្រធានឆ្មាំយាមមន្ទីរស-២១ (ខាងឆ្វេង) និង សម្បត្តិ សុណិសា (ស្តាំ) នៅការិយាល័យកណ្តាល មជ្ឈមណ្ឌលឯកសារកម្ពុជា រាជធានីភ្នំពេញ ឆ្នាំ២០២៣។ សម្បត្តិ សុណិសា (ស្តាំ) គឺជា អ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ បច្ចុប្បន្ន ស្តាំ កំពុងបន្តសិក្សាជំនាញប្រព័ន្ធទំនាក់ទំនង និងផ្សព្វផ្សាយ នៅសាកលវិទ្យាល័យ មែលប៊ន។ (ឆាំង យុ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

លាតសន្ធឹងនៅតាមបណ្តោយច្រាំងទន្លេពណ៌ខៀវល្អឹងល្អើយនៃដងទន្លេមេគង្គផ្នែកខាងលើដ៏ស្ងប់ស្ងាត់ ស្រុកអូរស្វាយ គឺជាសហគមន៍ប្រជុំកោះដែលក្តោបនូវតម្លៃប្រវត្តិសាស្ត្រជាសារវ័ន្ត និងទម្ងន់នៃប្រវត្តិសាស្ត្រដ៏ស្មុគស្មាញរបស់កម្ពុជា។ ជាផ្នែកមួយនៃព្រះរាជចក្ខុវិស័យជានិមិត្តរូបក្នុងការអភិវឌ្ឍន៍របស់អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ទីតាំងភូមិសាស្ត្រយ៉ាងអំណោយផលរបស់ស្រុកអូរស្វាយ គឺជាចំណុចប្រសព្វនៃការអភិវឌ្ឍន៍យ៉ាងដុះដាលទៅលើផ្នែកវប្បធម៌និងសេដ្ឋកិច្ច។ ស្រុក

អូរស្វាយ ស្ថិតនៅចំតំបន់ទល់ដែនរវាងប្រទេសកម្ពុជា និងប្រទេស ឡាវ ដែលញ៉ាំងឱ្យទីតាំងនេះក្លាយជាទីតាំងយុទ្ធសាស្ត្រក្នុងការរក្សានូវដែនអធិបតេយ្យភាពរបស់កម្ពុជា នៅក្នុងជម្លោះដែនដី និងជុំវិញនូវសន្ទុះនៃការរីកចម្រើនរបស់សហគមន៍។ ទោះបីជាយ៉ាងណាក្តី អនាគតដ៏ត្រចះត្រចង់របស់ស្រុកអូរស្វាយ ត្រូវបានបន្ទុចបង្អាក់យ៉ាងឃោរឃៅ នៅក្នុងឆ្នាំ១៩៧៥ ក្រោមការគ្រប់គ្រងនៃរបបខ្មែរក្រហម។ របបនេះ បានបន្សល់នូវភាពខ្ទេចខ្ទាំទៅលើសហគមន៍អូរស្វាយ ហើយសក្តានុពលភាពនៃស្រុកអូរស្វាយ ក៏ត្រូវបានលុបកប់ដោយសារតែអំពើហិង្សា ការបំផ្លាស់ និងការបាត់បង់នានា ដែលអូសបន្លាយអស់រយៈកាលជាច្រើនឆ្នាំ។ បច្ចុប្បន្នស្រុកអូរស្វាយ (ដែលត្រូវស្គាល់ជាទូទៅថា ស្រុកបុរីអូរស្វាយសែនជ័យ) រក្សាជំហរនឹងទ្រឹងក្នុងនាមជានិមិត្តរូបនៃភាពមិនងាយទ្រុឌទ្រោម និងសេចក្តីសោកសង្រេង ពោលគឺជាទីប្រជុំស្រុកមួយដែលបំផុសជាសំណួរមួយថា៖ "តើស្រុកនេះ នឹងមានសភាពយ៉ាងដូចម្តេច ប្រសិនបើប្រវត្តិសាស្ត្រមានលំនាំមួយផ្សេង?"

នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ស្រុកអូរស្វាយ គឺមិនមែនត្រឹមតែជាភូមិឋានដាច់ស្រយាលមួយប៉ុណ្ណោះទេ ក៏ប៉ុន្តែគឺជាសំអាងនៃដែនអធិបតេយ្យភាពរបស់កម្ពុជា។ នៅក្នុងឆ្នាំ១៩៦៤ សម្តេចព្រះ នរោត្តម សីហនុ បានយាងព្រះរាជដំណើរទស្សនកិច្ចទៅកាន់ស្រុកអូរស្វាយ និងយាងជួបសំណេះសំណាលជាមួយប្រជានុរាស្ត្រនៅក្នុងភូមិឋាននេះ ក្នុងនាមជានិមិត្តរូបនៃសេចក្តីប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការរក្សាការពារទល់ដែនរបស់ខ្លួន។ ក្រោមព្រះរាជត្រាស់បង្គាប់របស់ព្រះអង្គ មន្ត្រីរាជការចូលនិវត្តន៍ ដែលរួមមាន ទាហាននិងក្រុមគ្រួសារ ត្រូវបានបញ្ជូនឱ្យទៅរស់នៅក្នុងភូមិនេះមិនតែប៉ុណ្ណោះ ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ត្រូវបានរៀបចំកសាង ដោយបំផុសបាននូវស្មារតីនៃមោទកភាពជាតិ។ យោងតាមសមាជិកក្រុមប្រឹក្សាស្រុក លោក វ័ន្ត សុន ដែលមានវ័យ៧៩ឆ្នាំ ព្រះរាជកិច្ចខិតខំប្រឹងប្រែងរបស់ព្រះបរមរតនកោដ្ឋ ក្នុងការបង្កើតជាទីប្រជុំស្រុកតាមបណ្តោយទល់ដែន ដែលរំលេចនូវវប្បធម៌ខ្មែរយ៉ាងលេចធ្លោនេះ គឺជាការបញ្ចៀសការវាតទីពីសំណាក់ ឡាវ។

"ព្រះរាជចក្ខុវិស័យរបស់ព្រះអង្គ គឺបង្រួបបង្រួម និងផ្តល់អំណាចដល់យើងគ្រប់គ្នា"។ វ័ន្ត សុន បានលើកឡើងយ៉ាងដូច្នេះ។ "ប្រសិនបើអំពើប្រល័យពូជសាសន៍ពុំបានកើតឡើងទេនោះ ស្រុកអូរស្វាយ អាចនឹងក្លាយជាគំរូដ៏ត្រចះត្រចង់នៃភាពមិនងាយទ្រុឌទ្រោមរបស់កម្ពុជា ពោលគឺជាទីប្រជុំស្រុក ដែលរីកដុះដាល ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ និងវិស័យកសិកម្មប្រកបដោយភោគផល"។

ផ្ទុយទៅវិញ របបខ្មែរក្រហមដ៏ឃោរឃៅ បានបង្កជារលកនៃការបំផ្លិចបំផ្លាញយ៉ាងគំហុកលើប្រជាជាតិទាំងមូល ដែលបានប្តូរផ្លាស់រូបរាងទាំងស្រុងនៃស្រុកអូរស្វាយ។ គោលនយោបាយនៃការធ្វើពលកម្មដោយបង្ខំ និងការផ្លាស់ទីប្រជាជនដោយបង្ខំ បានបំបែកបំបាក់ក្រុមគ្រួសារ និងរុញច្រានឱ្យមានការសម្លាប់រង្គាលលើប្រជាជនស្លូតត្រង់ជាច្រើន ព្រមទាំងបន្សល់ជាស្នាមរបួសមុតជ្រៅរហូតមកទល់សព្វថ្ងៃ។ ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងស្រុកអូរស្វាយ ដែលជាសមិទ្ធផលនៃព្រះរាជចក្ខុវិស័យរបស់សម្តេចព្រះបរមរតនកោដ្ឋ បានសាបសូន្យដូចផេះផង់។ ខ្មែរក្រហមបានធ្វើឱ្យទីតាំងនេះក្លាយជាទីរហោស្ថានបុបង្កជាការខូចខាតទៅលើសំណង់និមិត្តរូបនៅក្នុងអំឡុងពេលកាន់អំណាចរបស់ខ្លួន។ ទន្ទឹមនឹងនេះដែរ ខ្មែរក្រហមបានបំផ្លាញស្មារតីនៃការអភិវឌ្ឍន៍ដែលសំណង់ទាំងអស់នេះតំណាងឱ្យ សេចក្តីសង្ឃឹមយ៉ាងមុតមាំដែលកំណត់អត្តសញ្ញាណរបស់ស្រុកអូរស្វាយ ក្នុងនាមជាទីតាំងពោរពេញដោយសក្តានុពលសម្រាប់ជីវិត និងភាពសម្បូររុងរឿង ត្រូវបាត់បង់នៅក្នុងអំពើហិង្សាហួសវិស័យ និងភាពភិតភ័យ ដូចទៅនឹងសហគមន៍នៅទូទាំងប្រទេសកម្ពុជា ដោយសារតែការបោះបង់ចោល បុ

បំផ្លិចបំផ្លាញនៅក្នុងរបបខ្មែរក្រហម។

ចំពោះអ្នកផងទាំងពួង ដែលរួចរស់ជីវិតពីអំពើឃោរឃៅនៅក្នុងអំឡុងរបបខ្មែរក្រហម ការចងចាំអំពីការបាត់បង់ទាំងនេះ គឺដូចទៅនឹងការស្រមើស្រមៃនូវស្ថានភាពផ្សេងមួយបែបទៀតសម្រាប់សហគមន៍របស់ខ្លួន។ រឿងរ៉ាវជីវិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានគូសវាសនូវទិដ្ឋភាពនៃសហគមន៍មួយ ដែលត្រូវបំផ្លាញដោយរបបខ្មែរក្រហម។ ជីប ស៊ឹម មានវ័យ៧៨ឆ្នាំ បានរំឭកអំពីព្រះរាជកិច្ចខិតខំប្រឹងប្រែងរបស់សម្តេចព្រះបរមរតនកោដ្ឋ ក្នុងការស្ថាបនាផ្លូវនិងលំនៅឋាន។ “ប្រសិនបើគ្មានវត្តមានរបស់ខ្មែរក្រហម ស្រុកអូរស្វាយនឹងមានភាពរុងរឿងសម្បូរសប្បាយ អមជាមួយនឹងវត្តមាននៃផ្សារផ្សា និងផ្លូវរលោងស្រិល។ ផ្ទុយទៅវិញ អំពើប្រល័យពូជសាសន៍បានឆក់យកជីវិតក្រុមគ្រួសាររបស់ខ្ញុំ និងអនាគតរបស់សហគមន៍នេះ”។

ជា ចាន់ថៃ បច្ចុប្បន្នមានវ័យ៧០ឆ្នាំ បាននឹករំពៃថា ស្រុកអូរស្វាយ អាចជាទិសដៅទេសចរណ៍មួយដែលមានផ្សារនិងសណ្ឋាគារ ដោយឆ្លុះបញ្ចាំងអំពីព្រះរាជចក្ខុវិស័យរបស់សម្តេចព្រះបរមរតនកោដ្ឋ។ ផ្ទុយស្រលះ ឪពុកនិងឪពុកមាររបស់គាត់បែរជាក្លាយទៅជាជនរងគ្រោះនៃរបបខ្មែរក្រហមទៅវិញ ដែលបន្សល់ទុកឱ្យគាត់នូវការព្រាត់ប្រាស និងសេចក្តីលំបាកវេទនា។ “យើងអាចមានសុភមង្គលដោយរស់នៅក្នុងជីវិតប្រសើរជាងនេះ ជាមួយនឹងផ្លូវ និងមន្ទីរពេទ្យល្អៗ ព្រមជាមួយនឹងឱកាសនានាសម្រាប់មនុស្សម្នាគ្រប់រូប”។

សូម្បីតែអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលស្ថិតនៅក្នុងវ័យកុមារកាលពីជំនាន់នោះ ក៏មានការសោកស្តាយជាខ្លាំងចំពោះអ្វីដែលបាត់បង់ទៅដែរ។ ស៊ាង សារ៉ង បច្ចុប្បន្នមានវ័យ៧០ឆ្នាំ បានចងចាំអំពីស្ថានភាពភូមិស្រុកនេះ ដែលពីដំបូងគឺជានិមិត្តរូបនៃដែនអធិបតេយ្យភាពរបស់កម្ពុជា ហើយត្រូវបំផ្លាញក្លាយជាផេះផង់។ “វិស័យដាំដុះអាចនឹងប្រកបដោយភោគផលជាងនេះ ហើយហេដ្ឋារចនាសម្ព័ន្ធរបស់យើង អាចនឹងប្រសើរជាងឥឡូវឆ្ងាយណាស់”។

រឿងរ៉ាវផ្ទាល់ខ្លួនទាំងអស់នេះ គឺមិនត្រឹមតែរំលេចអំពីសេចក្តីឈឺចាប់ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងជាសេចក្តីក្រើនរំឭកអំពីភាពមិនងាយទ្រុឌទ្រោម និងចក្ខុវិស័យដែលដក់ជាប់នៅយ៉ាងជ្រាលជ្រៅជាមួយនឹងប្រជាជនក្នុងស្រុកអូរស្វាយថែមទៀតផង។ រឿងរ៉ាវទាំងនេះ មិនត្រឹមតែបង្ហាញអំពីអតីតកាលដ៏ជូរចត់ប៉ុណ្ណោះទេ ក៏ប៉ុន្តែបំផុសនូវសេចក្តីសង្ឃឹមចំពោះអនាគតដ៏ត្រចះត្រចង់ថែមទៀតផង។

ថ្វីត្បិតតែទទួលរងការបំផ្លិចបំផ្លាញយ៉ាងដំណំក្នុងរបបខ្មែរក្រហមយ៉ាងណាក្តី ស្រុកអូរស្វាយកំពុងស្តារនូវអត្តសញ្ញាណរបស់ខ្លួនបណ្តើរៗ ដោយមានភាពមិនងាយទ្រុឌទ្រោមរបស់ប្រជាជនជាកត្តាជំរុញចិត្ត ព្រមជាមួយនឹងការគាំពារពីកិច្ចផ្តួចផ្តើមបែបទំនើប។ នៅក្នុងឆ្នាំ២០១៩ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល សព្វព្រះរាជហឫទ័យជ្រោសព្រះរាជទានហិរញ្ញប្បទានសាងសង់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដែលរួមបញ្ចូលនូវសាលារៀន, មន្ទីរពេទ្យ និងអគារបម្រើមុខងារផ្សេងៗក្នុងតំបន់នេះ ក្នុងព្រះរាជគោលបំណងបណ្តុះសេចក្តីសង្ឃឹមរបស់សហគមន៍មួយ ដែលហែលឆ្លងអតីតកាលដ៏សោកសង្រេង។ ព្រះរាជកាយវិការចូលរួមចំណែករបស់ព្រះអង្គ គឺមិនត្រឹមតែទ្រទ្រង់ចំពោះការសាងសង់ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងជាព្រះរាជនិមិត្តរូបនៃកិច្ចខិតខំប្រឹងប្រែងបែបទំនើប ក្នុងការស្តារឡើងវិញនូវព្រះរាជចក្ខុវិស័យរបស់សម្តេចព្រះបរមរតនកោដ្ឋ និងជាសេចក្តីក្រើនរំឭកចំពោះប្រជាជនក្នុងស្រុកអូរស្វាយ អំពីកម្លាំងមិនរាថយនិងសក្តានុពលភាពនៃមាគ៌ាដ៏ត្រចះត្រចង់ឆ្ពោះទៅអនាគតថែមទៀតផង។

ស្ថាប័នសង្គមស៊ីវិល ដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជា ជាដើម បានដើរតួនាទីយ៉ាងសំខាន់

នៅក្នុងការស្តារទីប្រជុំស្រុកនេះឡើងវិញដែរ។ គម្រោងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលរួមមានការសាងសង់ផែ និងផ្គត់ផ្គង់ជាទូកសម្រាប់ប្រជាជនក្នុងតំបន់ធ្វើដំណើរ ជំរុញឱ្យមធ្យោបាយធ្វើដំណើរ និងការផ្សារភ្ជាប់គ្នារវាងកោះទាំងប្រាំមួយនៅក្នុងសហគមន៍មានភាពប្រសើរឡើង។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះចាប់ផ្តើមចេញពីគោលបំណងក្នុងការដោះស្រាយចំពោះបញ្ហាប្រឈមប្រចាំថ្ងៃរបស់ប្រជាជនក្នុងសហគមន៍ ដោយផ្តល់ជាការទទួលបាននូវការអប់រំ, ការថែទាំសុខភាព និងជំនួញក្នុងតំបន់ឱ្យប្រព្រឹត្តដោយងាយស្រួលជាងមុន។

ទោះបីជាយ៉ាងណាក្តី កិច្ចការងារនេះ ត្រូវបន្តដំណើរវែងឆ្ងាយទៀត។ អ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ដូចជា សៀវ ជន បានសង្កត់ធ្ងន់អំពីតម្រូវការនៃការវិនិយោគបន្ថែមទៀតជាពិសេសទៅលើវិស័យទេសចរណ៍។ "ទីប្រជុំស្រុករបស់យើងមានសក្តានុពលជាច្រើនជាពិសេសនៅតាមបណ្តោយដងទន្លេមេគង្គ។ ការអភិវឌ្ឍន៍វិស័យទេសចរណ៍ អាចកែប្រែសេដ្ឋកិច្ច និងនាំមកនូវឱកាសនានាសម្រាប់ប្រជាជន"។ ចំណែកឯវិនិយោគទុនផ្សេងទៀត អាចប្រើប្រាស់នៅក្នុងការពង្រីកទីផ្សារ និងពង្រឹងបរិក្ខារអប់រំ ដើម្បីធ្វើឱ្យមូលដ្ឋានគ្រឹះរបស់ស្រុកកាន់តែរឹងមាំ។

កិច្ចខិតខំប្រឹងប្រែងនេះ ថ្វីត្បិតតែសាមញ្ញ ប៉ុន្តែរំលេចអំពីចំណុចរបត់ដ៏សំខាន់មួយ។ កិច្ចខិតខំប្រឹងប្រែងនេះ ឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តរួមគ្នាជាធ្លុងមួយ ដើម្បីផ្តល់កិត្តិយសចំពោះប្រវត្តិសាវតារនៃស្រុកអូរស្វាយ ស្របគ្នាជាមួយនឹងការកសាងអនាគតមួយអនុលោមទៅតាមសេចក្តីសន្យាកាលពីដើមដំបូង។ ខណៈដែលសហគមន៍នៅតែបន្តស្តារខ្លួនឡើងវិញ រឿងរ៉ាវរបស់សហគមន៍នេះ ក្លាយជាភាពមិនងាយទ្រុឌទ្រោមមួយ ដែលជាទឡ្ហីករណ៍បង្ហាញថាថ្វីត្បិតតែស្ថិតនៅជិតជាមជាមួយនឹងស្រមោលអន្ធការនៃរបបខ្មែរក្រហមយ៉ាងណាក្តី សេចក្តីសង្ឃឹមនៅតែអាចរះឡើងជាពន្លឺបំភ្លឺនាំផ្លូវសម្រាប់សង្គមក្រោយជម្លោះរបស់កម្ពុជាដដែល។

សំណួរដែលចោទសួរថាតើស្រុកអូរស្វាយអាចមានសភាពយ៉ាងណា ប្រសិនបើគ្មានវត្តមានសង្គ្រាម និងអំពើប្រល័យពូជសាសន៍ គឺមិនមែនត្រឹមតែជាការឆ្លុះបញ្ចាំងអំពីអតីតកាលប៉ុណ្ណោះទេ ក៏ប៉ុន្តែគឺជាការជម្រុះឆ្ពោះទៅកាន់អនាគតប្រសើរជាងមុន។ ទីប្រជុំស្រុកដែលពោរពេញដោយប្រវត្តិសាស្ត្រជ្រាលជ្រៅ និងភាពមិនងាយទ្រុឌទ្រោម គ្របសោបនូវសក្តានុពលមហាសាល ដែលអាចសម្រេចបានសមិទ្ធផលជាផ្លែផ្កាតាមរយៈកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈរជាសមូហភាព។

ជំហានដំបូងដ៏ចាំបាច់បំផុតគឺ ផ្តល់អាទិភាពជាចម្បងចំពោះការអភិរក្សប្រវត្តិសាស្ត្ររបស់ស្រុកអូរស្វាយ។ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, ព្រះរាជកេរដំណែលរបស់សម្តេចព្រះបរមរតនកោដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធស្រុកពីមុនៗដែលនៅសេសសល់ សុទ្ធសឹងជាបំណែកដ៏ចាំបាច់នៃអត្តសញ្ញាណវប្បធម៌របស់កម្ពុជា។ កិច្ចផ្តួចផ្តើមលើវិស័យអប់រំ ដូចជា ការរួមបញ្ចូលប្រវត្តិសាស្ត្ររបស់ស្រុកអូរស្វាយ នៅក្នុងកម្មវិធីសិក្សានៅតាមសាលារៀន និងការគាំពារដល់សារមន្ទីរក្នុងតំបន់ អាចធានាថាមនុស្សជំនាន់ក្រោយអាចយល់ដឹងអំពីសារសំខាន់និងការខិតខំតស៊ូពុះពាររបស់ទីប្រជុំស្រុកនេះ។ ដូចដែល វ័ន្ត សុន បានលើកឡើងថា៖ "ការអប់រំនាំមកនូវការអភិវឌ្ឍន៍។ យុវជន-យុវនារីរបស់យើង ត្រូវដឹងអំពីដើមកំណើតរបស់ខ្លួន ដើម្បីកសាងអនាគតប្រសើរមួយ"។

ការអភិវឌ្ឍន៍សេដ្ឋកិច្ច គឺជាជំហានដ៏សំខាន់។ ការវិនិយោគទៅលើវិស័យទេសចរណ៍ ដូចជាការធ្វើឱ្យបរិក្ខារនៅតាមបណ្តោយដងទន្លេមេគង្គ មានភាពប្រសើរឡើង អាចប្រែក្លាយស្រុកអូរស្វាយទៅជាទិសដៅនៃអេកូទេសចរណ៍និងទេសចរណ៍បែបវប្បធម៌។ តំបន់នេះគឺជាផ្នែកមួយនៃដែនដីស្ថិតនៅក្នុងតំបន់អភិរក្ស អនុម័តដោយ អនុសញ្ញារ៉ាមសារ



សិស្សមួយរូបនៅភូមិអូរស្វាយ កំពុងរង់ចាំ និងអានសៀវភៅនៅលើផែមួយកន្លែងក្នុងស្រុកអូរស្វាយ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បុអនុសញ្ញាស្តីអំពីតំបន់ដីសើម មានសារសំខាន់ជាអន្តរជាតិ (ពិសេសជាទីជម្រកសត្វស្លាបទឹក)។ ការពង្រីកទីផ្សារ និងពង្រឹងខ្សែរហកម្មក្នុងតំបន់ ដូចជាផ្នែកដាំដុះ និងនេសាទ បន្ថែមពីលើតំបន់អេកូទេសចរណ៍នេះ គឺមិនត្រឹមតែអាចបង្កើនសន្ទុះសេដ្ឋកិច្ចក្នុងតំបន់ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងផ្តល់ជាជីវភាពរស់នៅប្រកបដោយនិរន្តរភាពសម្រាប់ប្រជាជនក្នុងតំបន់ថែមទៀតផង។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ ទាមទារឱ្យមានការសហការរួមគ្នារវាងសហគមន៍ក្នុងតំបន់ រាជរដ្ឋាភិបាល និងស្ថាប័នអន្តរជាតិ ដើម្បីបង្កើតបានជាការរីកចម្រើនរយៈពេលយូរអង្វែង។

សរុបមក មនុស្សជំនាន់ក្រោយ គឺជាតួអង្គយ៉ាងសំខាន់ក្នុងការសម្រេចសេចក្តីសង្ឃឹមនិងការអភិវឌ្ឍន៍ទាំងនេះ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅតែសង្កត់ធ្ងន់អំពីសារសំខាន់នៃការអប់រំ និងកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងអនាគតដ៏ប្រសើរមួយ។ ស៊ាង សាវ៉ង កសិករមួយរូបដែលរស់រានមានជីវិតពីរបបខ្មែរក្រហម បានលើកឡើង៖ "យើងចង់ឱ្យកូនចៅរបស់យើងមានមហិច្ឆិតា និងហ៊ានស្រមើស្រមៃថាតើស្រុកអូរស្វាយគួរតែមានរូបរាងបែបណា"។

ដំណើរឆ្ពោះទៅមុខបន្តទៀត អាចនឹងពើបប្រទះជាមួយបញ្ហាប្រឈមផ្សេងៗ ក៏ប៉ុន្តែស្មារតីរបស់ប្រជាជនក្នុងស្រុកអូរស្វាយ នៅតែមុតមាំជានិច្ច។ តាមរយៈការថែរក្សាប្រវត្តិសាស្ត្រ បង្កើតឱកាសសេដ្ឋកិច្ច និងផ្តល់អំណាចដល់យុវជន-យុវនារីក្នុងតំបន់ ទីប្រជុំស្រុកនេះ អាចស្តារឡើងវិញនូវកេរដំណែលរបស់ខ្លួន និងវិវឌ្ឍន៍ខ្លួនទៅជានិមិត្តរូបនៃភាពមិនងាយទ្រុឌទ្រោម និងការកកើតឡើងវិញ។ បច្ចុប្បន្ន គឺជាពេលវេលាដ៏សក្តិសមបំផុត ក្នុងការចាប់ផ្តើមប្រតិបត្តិការ ដើម្បីធ្វើឱ្យការគិតរំពៃថា "តើអាចមានសភាពដូម្តេច" ទៅជាការពិតថា "នឹងវិវត្តទៅយ៉ាងដូចម្តេច"។

# តើ «ការធ្វើតាមបញ្ជា»៖ ចម្លើយដែលបានមកអាចទទួលយកបានដែរឬទេ?

ស្រ៊ាង លីហួរ



អ្នកទោសនៅមន្ទីរសន្តិសុខស-២១ ត្រូវបានសន្តិសុខនាំមកថតរូបមុននឹងបញ្ជូនទៅឃុំឃាំង និងសួរចម្លើយ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីការអានអំពីប្រវត្តិនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហម (របបកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩) អ្នកអានតែងតែបញ្ចប់ដោយសំណួរអំពីហេតុផលនៅពីក្រោយការសម្លាប់មនុស្ស។ តាមដំណើររឿងរបស់អ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមម្នាក់ ឈ្មោះ សុខ អៀត មានអាយុ៨៥ឆ្នាំ អតីតកងឈ្លបនៅខេត្តព្រះវិហារ។ ក្នុងរបបខ្មែរក្រហម សុខ អៀត បាននិយាយថា «លោកបានអនុវត្ត [ការសម្លាប់] ពីព្រោះតែបញ្ជាពីថ្នាក់លើប៉ុណ្ណោះ»។ គាត់បានពន្យល់ថាគាត់មិនមានជម្រើសនោះទេ។ សម្រាប់គាត់ ការសម្លាប់គឺបណ្ដាលមកពីស្ថានភាពសង្គមជាក់ស្ដែងនៅសម័យនោះ។

អ្នកយាមគុកមកពីអតីតមន្ទីរសន្តិសុខ ស-២១ ឬជាទូទៅស្គាល់ថាជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងក្នុងរាជធានីភ្នំពេញ ដែលត្រូវប៉ាន់ស្មានថាមានអ្នកទោសចំនួនជាង ១២,០០០នាក់ ដែលជាប់ឃុំឃាំង និង ត្រូវបានសម្លាប់ ហើយមានមនុស្សតិចតួចប៉ុណ្ណោះ ដែលបាននៅរស់រានមានជីវិត។ ឆ្មាំគុកក៏បាន ផ្ដល់ហេតុផលដូចគ្នា ក្នុងបទសម្ភាសន៍ជាមួយវិទ្យុអាស៊ីសេរីជាភាសាខ្មែរកាលពីឆ្នាំ២០១៥។ គាត់បានទទួលស្គាល់ថាយ៉ាងហោចណាស់មនុស្ស ៥នាក់ត្រូវបានសម្លាប់ដោយរូបគាត់។

ហ៊ឹម ហ៊ុយ ត្រូវបានសមមិត្ត ឌុច ដែលជាប្រធានមន្ទីរស-២១ សួរថាតើគាត់ «ដាច់ខាត» ឬ «មិនដាច់ខាត» មានន័យថាសម្លាប់ឬមិនសម្លាប់។ ដូចចម្លើយរបស់កងឈ្លបខាងលើ ហ៊ុយ បាននិយាយថា គាត់គ្មានជម្រើសទេ។ បុរសទាំងពីរដឹងថាការធ្វើតាមបញ្ជាគឺជាវិធីតែមួយគត់ដើម្បីរស់ ប៉ុន្តែតើនេះគ្រប់គ្រាន់ដើម្បីបង្ហាញអំពីភាពត្រឹមត្រូវនៃ

សកម្មភាពរបស់អ្នកទាំងពីរដែរឬទេ?

និយាយអំពីអារម្មណ៍ផ្ទាល់ខ្លួន ហ៊ុយ បានរៀបរាប់ថា គាត់ក៏បានស្នើសុំធ្វើជាទាហានជំនួសអ្នកយាមគុកផងដែរ ប៉ុន្តែត្រូវបានបដិសេធដោយ សុន សេន ដែលជារដ្ឋមន្ត្រីក្រសួងការពារជាតិក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម។

នៅពេលដែលសាស្ត្រាចារ្យ Alexander Laban Hinton បានសរសេរសៀវភៅមួយដែលមានចំណងជើងថា" ហេតុអ្វីបានជាគេសម្លាប់? ប្រទេសកម្ពុជានៅក្រោមស្រមោលនៃអំពើប្រល័យពូជសាសន៍" បានគូសបញ្ជាក់ថា អតីតកម្មាភិបាលខ្មែរក្រហមបានអះអាងថា "អ្នកទាំងនោះធ្វើតាមបញ្ជា" ឬការគោរពប្រតិបត្តិចំពោះថ្នាក់លើប៉ុណ្ណោះ។

ក្រៅពីហេតុផល«ធ្វើតាមបញ្ជា» គាត់បានសរសេរថា ការជំរុញផ្សេងទៀតគួរតែត្រូវបានពិចារណាថា តើអ្នកទាំងនោះជឿជាក់លើ «មហាលោតផ្លោះដ៏អស្ចារ្យ» គោលនយោបាយវិស្វកម្មសង្គមនៅពេលនោះ ឬសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួនឬដើម្បីរស់ស្របទៅតាមអ្វីដែលអ្នកទាំងនោះចង់បាន។ តើអ្នកទាំងនោះគិតយ៉ាងណាចំពោះជម្រើសរវាង «សម្លាប់» ឬ «ត្រូវបានសម្លាប់»?

ពាក្យ «ស្ថានភាព» កំណត់ថាជា «សំណុំនៃរឿងដែលកំពុងកើតឡើង និងលក្ខខណ្ឌដែលមាននៅពេលវេលា និងទីកន្លែងជាក់លាក់មួយ» ចំណែកឯពាក្យ «នយោបាយ» កំណត់ថា «ទាក់ទងនឹងនយោបាយ»។ ជាមួយនឹងនិយមន័យនោះ អ្នកទាំងពីរមានន័យថាខ្លួនបានសម្លាប់ដោយសារតែស្ថានការណ៍នយោបាយនៅសម័យនោះ ដែលរបបប្រល័យពូជសាសន៍ខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បានធ្វើការសម្លាប់យ៉ាងរង្គាល ដែលមានអ្នកស្លាប់ជាង ២ លាននាក់ ជាស្ថានភាពដែលពោរពេញដោយឧបសគ្គសម្រាប់អ្នកទាំងពីរក្នុងការធ្វើឬមិនធ្វើតាមបញ្ជា។

តើអ្វីជានិយមន័យនៃស្ថានការណ៍ដែលពោរពេញដោយឧបសគ្គ? «គឺស្ថានភាពដែលមានការដាក់កម្រិតលើវិសាលភាពដែលអាកប្បកិរិយាលក្ខណៈផ្ទាល់ខ្លួន និងការជំរុញឱ្យទៅជាអាកប្បកិរិយា និងការអនុវត្ត»។ ដោយមានការដាក់កំហិតលើអាកប្បកិរិយារបស់អ្នកទាំងពីរ សុខ អៀត និង ហ៊ឹម ហ៊ុយ មិនបានបដិសេធបញ្ជាទេ គឺធ្វើតាម។

បន្ទាប់ពីការសម្លាប់របស់ក្រុមណាស៊ីអាល្លឺម៉ង់លើជនជាតិជ្វីហ្វប្រហែល ៦លាននាក់ក្នុងអំឡុងពេលកាត់ក្តីក្នុងឆ្នាំ១៩៦១ លោក Adolf Eichmann ដែលគេស្គាល់ថាជាស្ថាបត្យករកំពូលនៃ Holocaust ក៏បានផ្តល់ការសារភាពស្រដៀងគ្នាថា គាត់គ្រាន់តែធ្វើតាមបញ្ជាពីថ្នាក់ដឹកនាំកំពូល ឬ គាត់ត្រូវបានបង្ខំឱ្យធ្វើជាអ្នកអនុវត្តអំពើប្រល័យពូជសាសន៍។

នៅក្នុងការពិសោធន៍ដែលធ្វើឡើងដោយអ្នកស្រាវជ្រាវ Stanley Milgram ការសិក្សាអំពីការគោរពប្រតិបត្តិបានផ្តល់នូវចំណុចមួយនៃហេតុផលដែលមនុស្សគោរពតាមបញ្ជា។ អ្នកចូលរួមក្នុងការពិសោធន៍នេះបន្តអនុវត្តការបញ្ជា ហើយបានពន្យល់ថា គ្រាន់តែធ្វើតាមបញ្ជាប៉ុណ្ណោះ ទាំងដឹងថាបង្កគ្រោះថ្នាក់ដល់អ្នកដទៃទៀតផង។

ប្រសិនបើបុគ្គលនោះឆ្លើយសំណួរមិនត្រឹមត្រូវ អ្នកចូលរួមនឹងទទួលបានបញ្ជាឱ្យចុចប៊ូតុងចរន្តអគ្គិសនី ឆក់ឱ្យខ្លាំងដល់អ្នកដែលឆ្លើយសំណួរ។ ទោះជាយ៉ាងណា អ្នកចូលរួមមិនបានដឹងទេថាមានការឆ្លងចរន្តអគ្គិសនីពិតប្រាកដនោះទេ ខណៈជននោះគ្រាន់តែធ្វើពុតជារងគ្រោះ។ សូម្បីតែប្រឆាំងនឹងក្រមសីលធម៌របស់អ្នកចូលរួមក៏ដោយ ក៏អ្នកចូលរួមនៅតែអនុវត្តការបញ្ជា ហើយបានកំណត់ខ្លួនឯងថាមិនទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនទៀតទេ ប៉ុន្តែជាអ្នកអនុវត្តការបញ្ជា។

យោងតាមអ្នកស្រាវជ្រាវ Milgram ការសិក្សាអាចពន្យល់ថា ដោយសារតែអ្នកចូលរួមជឿថាការចូលរួមក្នុងគម្រោងវិទ្យាសាស្ត្រ បានធ្វើរឿងត្រឹមត្រូវ ជាជាងសុខុមាលភាពរបស់អ្នកដែល

ទទួលការឆក់បន្តអគ្គិសនី។

តើឆ្នាំសន្តិសុខ ប្តុកឈ្នួបជឿថា ការសម្លាប់មនុស្សនឹងរួមចំណែកដល់ "មហាលោតផ្លោះដ៏អស្ចារ្យ" ឬធ្វើតាមស្ថានការណ៍នយោបាយ ដូចដែលអ្នកទាំងពីរបានគិតថា គឺជារឿងត្រឹមត្រូវ?

ជាមួយនឹងភាពស្មុគស្មាញនៃអាកប្បកិរិយារបស់មនុស្ស តើយើងជឿថាការសម្លាប់មនុស្សគឺគ្រាន់តែធ្វើតាមបញ្ជា? ឬថាតើដោយសារតែអ្នកទាំងនោះធ្លាប់ទទួលរងផលប៉ះពាល់ទៅនឹងការជំរុញនៃអំពើហិង្សាក្នុងអំឡុងពេលអស្ថិរភាពផ្នែកនយោបាយ សេដ្ឋកិច្ចនិងសង្គ្រាមនៅមុនពេលអំពើប្រល័យពូជសាសន៍បានកើតឡើង ដែលនាំឱ្យគាត់ធ្វើតាមការទទួលបញ្ជាបែបនេះ។ សាស្ត្រាចារ្យ Hinton បានពន្យល់នៅក្នុងសៀវភៅរបស់គាត់អំពីឥទ្ធិពលបឋមឥទ្ធិពលដែលអាចឈានដល់ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍នាំឱ្យមានបន្តិចម្តងៗ។

យោងតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ប្រការ១៖ គោលបំណងបានចែងថា មានតែការកាត់ទោស «មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរនៃច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និង អនុសញ្ញាទំនៀមទម្លាប់ និងអន្តរជាតិដែលកម្ពុជាទទួលស្គាល់ និងបានប្រព្រឹត្តក្នុងអំឡុងពេលពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩»។ បុរសទាំងពីរដែលនិយាយថាធ្វើតាមបទបញ្ជានោះមិនត្រូវបានកាត់ទោសនោះទេ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចាប់ផ្តើមពីឆ្នាំ២០០៦ និង បញ្ចប់នៅឆ្នាំ២០២២។ តុលាការបានចំណាយពេល១៦ឆ្នាំ និងចំណាយថវិកាអស់ជាង៣៣៧ លានដុល្លារអាមេរិក។ តុលាការបានកាត់ទោសបុគ្គលបីនាក់ដែលទទួលខុសត្រូវបំផុតចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម។ នួន ជា និង ខៀវ សំផន គឺជាអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០២ ដែលត្រូវបានកាត់ទោសក្នុងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ និង កាំង ហ្គេកអ៊ាវ អតីតប្រធានមន្ទីរសន្តិសុខស-២១ ដែលត្រូវបានផ្តន្ទាទោសក្នុងសំណុំរឿង ០០១។

សម្រាប់អ្នកជំនាញសិទ្ធិមនុស្ស តុលាការអាចបម្រើជាការអប់រំផ្នែកនយោបាយ និងចងក្រងឯកសារប្រវត្តិសាស្ត្រ ទោះបីជាវាមិនអាចជៀសវាងការរឹតបន្តឹងផ្នែកនយោបាយដែលជាប់ពាក់ព័ន្ធផលប្រយោជន៍ជាជាងយុត្តិធម៌ក៏ដោយ។

តាមទស្សនៈផ្សេងៗរបស់ជនរងគ្រោះមួយចំនួនមិនបានដឹងអំពីដំណើរការរបស់តុលាការទេ នៅពេលអ្នកសម្ភាសន៍សួរគាត់ថាតើតុលាការផ្តល់យុត្តិធម៌ដល់អ្នករងគ្រោះឬអត់។ យ៉ាងណាក៏ដោយ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទាំងនោះសង្ឃឹមថា មនុស្សជំនាន់ក្រោយនឹងបានសិក្សា និងដឹងអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ តាមរយៈឯកសារដែលបានចងក្រង។

ដើម្បីរកយុត្តិធម៌ យោងតាម ប៊ូ ម៉េង អ្នកដែលរស់រានមានជីវិតពីមន្ទីរស-២១ បាននិយាយថា «កាត់ទោសទាំងអស់» [ចំពោះអ្នកដែលទទួលខុសត្រូវលើការសម្លាប់រង្គាលនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យត្រូវតែនាំខ្លួនទៅកាត់ទោស]។ ក្នុងចំណោមអ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម អ្នកទាំងនោះអាចមានទស្សនៈខុសគ្នាលើអត្ថន័យនៃយុត្តិធម៌ និងតុលាការ អ្នកខ្លះមិនទទួលយក និងអ្នកខ្លះមានក្តីសង្ឃឹមផ្សេងទៀតសម្រាប់អនាគតជាវិជ្ជមានរបស់ប្រទេសបន្ទាប់ពីការបញ្ចប់របស់តុលាការ។ សម្រាប់មនុស្សជំនាន់ក្រោយ និង អ្នកប្រវត្តិសាស្ត្រ យុត្តិធម៌នៅតែជាប្រធានបទដែលអាចបន្តការជជែក ពិភាក្សាដេញដោលនាពេលអនាគត។

# តើហេតុអ្វីបានជាគេនិយាយថាជនជាតិដើមភាគតិចមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងធនធានធម្មជាតិ?

រចឹម បុប្ផា



ជនជាតិភាគតិចនៅភូមិតេនង៉ិល ឃុំយ៉ាងទុង ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី។(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នាងខ្ញុំគឺជាអ្នករស់នៅតំបន់ជនជាតិដើមភាគតិចស្ថិតក្នុងខេត្តរតនគិរី។ ខ្ញុំធំធាត់ដឹងក្តីឡើងជាមួយនឹងបែបបទនៃការរស់នៅរបស់បងប្អូនជនជាតិដើមភាគតិចតាំងពីតូចរហូតដល់ អាយុ១៩ឆ្នាំ។ កន្លងមកនេះ នាងខ្ញុំបានសម្គាល់ឃើញថា ស្ថានភាពនៃការរស់នៅរបស់បងប្អូនជនជាតិដើមភាគតិចគឺមានលក្ខណៈផ្សារភ្ជាប់ជាមួយនឹងធម្មជាតិ ព្រៃឈើ អូរ បឹងបួ ជ្រោះភ្នំ ហើយក៏ជាអ្នកថែរក្សាការពារព្រៃឈើថែមទៀតផង។ បងប្អូនជនជាតិដើមភាគតិចប្រកបមុខរបរដាំដំណាំកសិកម្មដើម្បីចិញ្ចឹមជីវិតដូចជា ស្រូវ ចន្ទី កៅស៊ូ ដំឡូងមី និងដំណាំដទៃទៀតដែលកសិកម្មទាំងនោះគឺអាស្រ័យផលដោយពឹងផ្អែកទៅលើព្រៃឈើ ទឹក ដី ខ្យល់ ភ្លៀងក៏ដូចជាការទៀងទាត់នៃបរិយាកាសអាកាសធាតុ។

ប្រសិនបើយើងនិយាយអំពីធនធម្មជាតិ គឺយើងសំដៅទៅលើមជ្ឈដ្ឋានដែលនៅជុំវិញខ្លួនដូចជា ទឹក ដី ភ្លៀង ខ្យល់ ព្រៃឈើ ដំណាំហូបផ្លែ រុក្ខជាតិបៃតង

ឬក៏សត្វព្រៃជាដើម... ពោលគឺអ្វីៗដែលកើតឡើងដោយឯកឯងហើយមានរយៈពេលយូរអង្វែង។

ប្រសិនបើយើងសាកល្បងប្រមើមើលអំពីការអវត្តមាននៃធនធានធម្មជាតិ សំណួរសួរថាតើបងប្អូនជនជាតិដើមភាគតិចនឹងរស់នៅបានយ៉ាងដូចម្តេច?

បងប្អូនជនជាតិដើមភាគតិចរស់នៅបែបធម្មជាតិ បែបបុរាណ ប្រកាន់ខ្ជាប់ទំនៀមទម្លាប់ ក៏ដូចជាថែរក្សាប្រពៃណីវប្បធម៌នៃការរស់នៅដែលមានលក្ខណៈតកូនតចៅតាំងពីជំនាន់ដូនតាដ៏យូរលង់ណាស់មកហើយ។ យ៉ាងណាមិញចំពោះស្ថានភាពនៃការរស់នៅប្រចាំថ្ងៃរបស់ក្រុមគ្រួសារគាត់គឺមានភាពសាមញ្ញជាទីបំផុតទាំងការប្រកបរបរចិញ្ចឹមជីវិត ការហូបចុក ការធ្វើដំណើរ ពោលគឺជីវភាពរស់នៅប្រចាំថ្ងៃសុទ្ធសឹងតែផ្សារភ្ជាប់ជាមួយនឹងធនធានធម្មជាតិ។ រីឯរបស់របរប្រើប្រាស់វិញគឺជាវត្ថុដែលអាចរកបានមកពីធម្មជាតិនិងធ្វើឡើងដោយដៃផ្ទាល់ ឧទាហរណ៍មានដូចជា កាផា (ដែលត្បាញពីដើមឬស្សីនិងវល្លិ៍ផ្សេងៗ) ផ្ទះ តុ ទូ កៅអី (ធ្វើពីឈើព្រៃ) ដែលរបស់របរអស់នេះគឺអាចរកបាននៅក្នុងព្រៃស្រោងក្នុងតំបន់ដែលគាត់រស់នៅ។

ងាកមកមើលការហូបចុករបស់ក្រុមគ្រួសារគាត់វិញ របបអាហារទាំងស្រុងបានអាស្រ័យលើអនុផលព្រៃឈើ បន្លែធម្មជាតិដែលដុះនៅក្នុងព្រៃ។ បន្លែព្រៃរួមមានទំពាំង ជ័រឈើ ស្លឹកកណ្ដោវ ស្លឹកយាវ ផ្សិត និងមានរុក្ខជាតិជាច្រើនទៀតដែលអាចយកមកធ្វើជាអាហារបាន។ បងប្អូនជនជាតិដើមភាគតិចបានដាំដំណាំបន្លែបន្លាជាច្រើនប្រភេទដូចជា បន្លែ ល្ពៅ ល្ហុង បេក ក្រូច ម្នាស់ ឪឡឹក និងដំណាំផ្សេងៗដែលក្រុមគ្រួសារគាត់បានដាំនៅតាមចម្ការឬក៏តាមផ្ទះរបស់ខ្លួនដែលកម្រិតនៃការដាំដុះនិងការរកម្ហូបពីក្នុងព្រៃទាំងនោះគឺវាមានលក្ខណៈវិលជុំ។ ដូច្នេះហើយបានជាធនធានធម្មជាតិគឺពិតជាមានសារសំខាន់ណាស់ចំពោះជនជាតិដើមភាគតិចពីព្រោះវាអាចផ្ដល់ផលវិជ្ជមានក៏ដូចជាជួយទ្រទ្រង់ផ្គត់ផ្គង់ជីវភាពក្នុងការរស់នៅ ព្រមទាំងការហូបចុកពីមួយឆ្នាំទៅមួយឆ្នាំបានយ៉ាងសមប្រកប។


ជនជាតិភាគតិចនៅខេត្តរតនគិរី។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយមកនេះគេឃើញថាធម្មជាតិហាក់បីដូចជាប្រែប្រួលដោយសារកត្តានៃការ «បម្រែបម្រួលអាកាសធាតុ» ធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិ ដែលកត្តាចម្បងនោះគឺមកពីការសឹករិចរិលនៃព្រៃឈើ ការកកើននៃឧស្ម័នផ្ទះកញ្ចក់ និងសកម្មភាពរបស់មនុស្សដែលបាននឹងកំពុងតែជះឥទ្ធិពលអវិជ្ជមានលើធនធានធម្មជាតិដោយមិនដឹងខ្លួន។ បច្ចុប្បន្ននេះមិនថានៅក្នុងប្រទេសឬក៏នៅលើពិភពលោកក្ដីគឺកំពុងប្រឈមទៅនឹងបញ្ហាការប្រែប្រួលអាកាសធាតុយ៉ាងដំណំ។ ការប្រែប្រួលអាកាសធាតុគឺបានផ្ដល់ផលប៉ះពាល់ជាច្រើនសម្រាប់បងប្អូនរស់នៅតាមជនបទដែលប្រកបរបរធ្វើស្រែចម្ការ ជាពិសេសនោះគឺជនជាតិដើមភាគតិចបានរងនូវផលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរបំផុត។ នាងខ្ញុំបានរៀបរាប់នៅខាងលើអត្ថបទអំពីទំនាក់ទំនងរវាងធនធានធម្មជាតិនិងជនជាតិដើមភាគតិចថាតើវាពាក់ព័ន្ធគ្នាបែបណារួចហើយ ដូច្នេះយើងអាចឆ្លុះបញ្ចាំងអំពីផលប៉ះពាល់ថា ប្រសិនបើអវត្តមាននៃធនធានធម្មជាតិតើបងប្អូនជនជាតិដើមភាគតិចនឹងរស់នៅបែបណា? ជនជាតិដើមភាគតិចគឺត្រូវការ

ធនធានធម្មជាតិជាចាំបាច់ ប៉ុន្តែដោយការប្រែប្រួលនៃអាកាសធាតុគឺធ្វើឱ្យដំណើរការនៃធម្មជាតិមានលក្ខណៈខុសប្រក្រតី អាកាសធាតុម្តងក្តៅ ម្តងត្រជាក់ ម្តងរងារ ពេលរដូវក្តៅក៏ក្តៅហួតហែង ពេលដល់រដូវវស្សាគឺបែរជាមិនមានភ្លៀងធ្លាក់ឬភ្លៀងធ្លាក់មិនទៀងទាត់បណ្តាលឱ្យដីឡើងក្តៅគ្មានជាតិសំណើមធ្វើឱ្យដំណាំកសិកម្មរបស់គាត់គឺកប់ងាប់នៅក្នុងដី។

បញ្ហាទាំងអស់នេះគឺកំពុងរីកដុះដាលពីមួយឆ្នាំទៅមួយឆ្នាំក៏បន្តរទៅជាប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ក្រុមគ្រួសារគាត់ៗ តួយ៉ាងខ្ញុំនឹងលើកអំពីបញ្ហាដែលនាងខ្ញុំធ្លាប់បានឆ្លងកាត់កន្លងមកអំពីផលវិបាករបស់គ្រួសារខ្ញុំនិងអ្នកស្រុកភូមិខ្ញុំប៉ុន្មានឆ្នាំចុងក្រោយមកនេះថា បន្ទាប់ពីអាកាសធាតុប្រែប្រួលធនធានធម្មជាតិក៏បាត់ទៅបន្តិចម្តងៗហើយថាតើក្នុងអំឡុងពេលនោះគ្រួសារនិងអ្នកស្រុកភូមិខ្ញុំបានប្រឈមមុខនឹងបញ្ហាអ្វីខ្លះ?

ខ្ញុំចាំបានថាកាលពីខ្ញុំនៅជាកុមារភាព(ប្រហែល ១០ឆ្នាំមុន)អ្នកស្រុកភូមិខ្ញុំរស់នៅប្រកបដោយសេចក្តីសុខនិងសុភមង្គលដោយមិនកង្វល់អំពីលុយកាក់ ទ្រព្យសម្បត្តិអ្វីនោះទេ យើងទាំងអស់គ្នារីករាយជាមួយនឹងការរស់នៅជាមួយធម្មជាតិ មានអាហារហូបចុកគ្រប់គ្រាន់ សម្រាន្តលក់ស្រួល ងើបពីព្រឹកទៅស្រែចម្ការនិងពេលល្ងាចត្រឡប់មកផ្ទះវិញ គឺយើងធ្វើបែបនេះជាប្រចាំថ្ងៃ។ ដំណាំបានផលផ្លែផ្កា បន្លែបង្ការក៏រកបានមកពីចម្ការ និងបានមកពីក្នុងព្រៃដើម្បីយកមកធ្វើជាម្ហូប ពេលខែប្រាំងមានស្រូវហូបបរិបូរណ៍មិនលើសមិនខ្វះ។ នៅជុំវិញខ្លួនគឺមានតែធម្មជាតិបៃតងខៀវស្រងាត់ ខ្យល់បរិសុទ្ធចេញចូលគ្រប់គ្រាន់ ហើយបញ្ហាសុខភាពក៏រឹងមាំ។ ឥឡូវនេះសម័យបច្ចេកវិទ្យាទំនើប កាន់តែទំនើបអ្នកនៅក្នុងទីក្រុងកាន់តែរីកចម្រើន ប៉ុន្តែហេតុអ្វីបានជាអ្នកស្រុកភូមិយើងបែរជារងនូវផលប៉ះពាល់និងភាពលំបាកទៅវិញ? នេះគឺដោយសារតែកត្តានៃការកកើតមនុស្សពីមួយឆ្នាំទៅមួយឆ្នាំដែលសកម្មភាពប្រចាំថ្ងៃរបស់ពួកគេកំពុងធ្វើឱ្យអាកាសធាតុប្រែប្រួលដោយមិនដឹងខ្លួន។ ខស្ម័នផ្ទះកញ្ចក់បានកើនឡើងជាគំហុក អ្វីដែលពិសេសនោះគឺការបាត់បង់ព្រៃឈើដែលជាកត្តាចម្បងធ្វើឱ្យបរិយាកាសប្រែប្រួលនឹងត្រូវបាត់បង់ធនធានធម្មជាតិម្តងបន្តិចៗដែលញុាំងឱ្យប៉ះពាល់ដល់ការរស់នៅរបស់យើងនៅតាមតំបន់ដាច់ស្រយាលពីទីក្រុង។ ១០ឆ្នាំមុនទោះបីជាមិនមានលុយកាក់សម្រាប់ចិញ្ចឹមជីវិតក៏យើងអាចរស់បានដោយសារមានការហូបចុកគ្រប់គ្រាន់ សុខភាពក៏រឹងមាំដែលអំណោយផលមកពីធម្មជាតិ។ ប៉ុន្តែបច្ចុប្បន្ននេះ អ្នកស្រុកអាចនិយាយបានថាគ្មានលុយកាក់គឺពិតជាពិបាកមិនអាចរស់នៅបាន អ្នកនៅក្នុងស្រុកភូមិយើងក៏នាំគ្នាទៅខ្ចីបំណុលឯកជនដើម្បីយកទៅប្រើប្រាស់លើដំណាំកសិកម្ម និងដើម្បីផ្គត់ផ្គង់ការរស់នៅប្រចាំថ្ងៃ។ ការបម្រែបម្រួលអាកាសធាតុនេះពេលខ្លះគឺបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពរបស់លោកអ៊ំពូមីងយាយតា ព្រមទាំងក្មេង(សុខភាពទ្រុឌទ្រោមហើយគ្មានធនធានសម្រាប់យកទៅព្យាបាលជំងឺ)។ បច្ចុប្បន្ននេះអ្នកស្រុកគឺកំពុងតែព្រួយបារម្ភអំពីបន្ទុកនេះ ពោលបើបញ្ហានេះនៅតែបន្តកើតមានឡើងរហូតនោះ យើងពិតជាមានភាពលំបាកនៅក្នុងការរស់នៅ។

ដូចនេះហើយធនធានធម្មជាតិគឺពិតជាសំខាន់សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់មនុស្ស និងភាវៈរស់ដែលមានជីវិតនៅក្នុងព្រៃដោយសារការរស់នៅគឺពឹងផ្អែកទៅលើធម្មជាតិ។ ការធ្វើឱ្យបាត់បង់ធនធានធម្មជាតិ និងព្រៃឈើគឺប្រៀបដូចជាកំពុងបំផ្លាញជម្រកសត្វព្រៃ រុក្ខជាតិមានជីវិតនានា និងជីវិតមនុស្សដែលរស់នៅប្រកបមុខរបរធ្វើស្រែចម្ការជាច្រើននាក់ ជាពិសេសនោះគឺបងប្អូនជនជាតិដើមភាគតិចព្រោះធនធានធម្មជាតិ ឬក៏ព្រៃឈើប្រៀបដូចជាជីវិតដង្ហើមរបស់ក្រុមគ្រួសារគាត់ដោយសារការរស់នៅគឺពឹងផ្អែកលើធនធានធម្មជាតិតាំងពីសម័យដូនតាមកម្ល៉េះ។

# ប្តីឬប្រពន្ធដែលជាប់សែស្រឡាយវៀតណាមក្នុងរបបខ្មែរក្រហម

ជាវ៉ារដ្ឋ មេត្តា

បន្ទាប់ពីមហាសន្និបាតលើកទី៣របស់បក្សកុម្មុយនីស្តកម្ពុជា នៅខែកញ្ញា ឆ្នាំ១៩៧១ មេដឹកនាំខ្មែរក្រហមបានសម្រេចថា វៀតណាមគឺជា «សត្រូវស្រួចស្រាវ» យូរអង្វែងរបស់កម្ពុជា។ ផែនការកម្ចាត់ជនជាតិវៀតណាមបានលេចចេញកាន់តែច្បាស់នៅពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និង ការជម្លៀសប្រជាជនឱ្យទៅរស់នៅតាមទីជនបទនានាដើម្បីធ្វើស្រែចម្ការ។ ខ្មែរក្រហមបានស្វែងរកជនជាតិវៀតណាមដើម្បីដេញអ្នកទាំងនោះឱ្យទៅរស់នៅប្រទេសវៀតណាម។ ជនជាតិវៀតណាមមួយចំនួនបានលាក់បាំងប្រវត្តិរូប និងបន្តរស់នៅប្រទេសកម្ពុជា។ មួយចំនួនទៀត គ្រាន់តែជាប់សែស្រឡាយវៀតណាមពីជីដូនជីតា ខ្មែរក្រហមបញ្ជូនទៅកាន់ព្រំដែនកម្ពុជាវៀតណាម ប៉ុន្តែអ្នកទាំងនោះមិនចេះនិយាយភាសាវៀតណាមទៅកាន់អាជ្ញាធរវៀតណាមទេ។ អ្នកទាំងនោះមិនត្រូវបានអនុញ្ញាតឱ្យឆ្លងព្រំដែន និងរស់នៅប្រទេសវៀតណាមឡើយ។ ខ្មែរក្រហមបានបញ្ជូនអ្នកមានសែស្រឡាយវៀតណាមទាំងនោះឱ្យរស់នៅតាមភូមិស្រុកប្រទេសកម្ពុជាវិញ ប៉ុន្តែជាអកុសលត្រូវបានសម្លាប់ស្ទើរតែទាំងអស់។ ក្នុងអំឡុងប្រាំខែបន្ទាប់ពី «ការរំដោះទីក្រុងភ្នំពេញ ជនជាតិវៀតណាមចំនួនជាង១៥០.០០០នាក់ដែលត្រូវបានដកហូតទ្រព្យសម្បត្តិអស់ពីខ្លួនបានហូរចូលក្នុងខេត្តដុងថាប អានយ៉ាង និង តាយនិញយ៉ាងកុះករ។ អ្នកដែលមានដើមកំណើតជាវៀតណាមត្រូវបានអនុញ្ញាតឱ្យស្ថិតនៅ ប៉ុន្តែអ្នកភៀសខ្លួនដែលមានដើមកំណើតជាចិននិងខ្មែរត្រូវបានរុញច្រានមកកម្ពុជាវិញ។



លឹម ទៀង (រូបខាងស្តាំ) សព្វថ្ងៃរស់នៅភូមិថ្មី សង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្តប៉ៃលិន និងអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

លឹម ទៀង អាយុ៦៩ឆ្នាំ មានស្រុកកំណើតនៅខេត្តបាត់ដំបង បច្ចុប្បន្នរស់នៅភូមិថ្មី សង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្តប៉ៃលិន។ នៅឆ្នាំ១៩៧៥ ឪពុកនិងម្តាយរបស់គាត់ដែលជាប់សែស្រឡាយចិន ប៉ុន្តែខ្មែរក្រហមគិតថាឪពុកម្តាយគាត់ជាយួន

ក៏ហៅឪពុកម្តាយគាត់ចេញទៅក្នុងគោលបំណងយកទៅសម្លាប់ ប៉ុន្តែម្តាយ លឹម ទៀង អង្វរប្រាប់ថាគ្រួសារគាត់មិនមែនយួនទេគឺជាជនជាតិចិន។ ក្រោយមកខ្មែរក្រហមនៅតែយកឪពុកម្តាយគាត់ទៅសម្លាប់ដដែល។ ខ្មែរក្រហមមិនសម្លាប់ លឹម ទៀង ដោយសារម្តាយគាត់អង្វរខ្មែរក្រហមកុំឱ្យយកកូនរបស់គាត់។ ម្យ៉ាងទៀត លឹម ទៀង មានជំងឺប្រកាច់ជាប្រចាំ។ ចំណែកម្តាយក្មេក លឹម ទៀង គឺជាជនជាតិវៀតណាម និងឪពុកក្មេកជាជនជាតិចិន។ ម្តាយក្មេក ប្អូនថ្លៃ និង ប្តីរបស់ លឹម ទៀង ត្រូវខ្មែរក្រហមយកទៅសម្លាប់ទាំងអស់។ នរណាសម្បុរសអត់នៅរស់ទេ បើខ្មៅៗខ្មែរក្រហមទុកឱ្យនៅ សម្បុរស ខ្មែរក្រហមថាយួន។

សាក់រី ហេង ឡៃហ៊ាង បានលើកឡើងថា «ក្រោយព្រឹត្តិការណ៍ឆ្នាំ១៩៧៥» «វាកម្ទេចតែអ្នកដែលកាត់វៀតណាម»។ សាក់រីនិងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានផ្តល់ភស្តុតាងថាបក្សកុម្មុយនីស្តកម្ពុជាបានពិចារណាលើជាតិពន្ធខាងប្រពន្ធ ដូច្នេះក្នុងគ្រួសារចម្រុះគឺមានការកំណត់គោលដៅលើកុមារដែលមានម្តាយវៀតណាម។ ក្នុងករណីឪពុកជាជនជាតិវៀតណាម គេកំណត់គោលដៅលើតែឪពុកប៉ុណ្ណោះ ចំណែកកូនៗគេឱ្យរួចខ្លួន។

អ៊ុច ស៊ុន ឡាយ បានថ្លែងថាគោលនយោបាយខ្មែរក្រហមគឺ«ជីកស្មៅជីកទាំងឫស» ដូច្នេះប្រសិនបើគេយកម្តាយជាវៀតណាមចេញទៅគេត្រូវយកកូននិងចៅទៅដែរ។ ជាលទ្ធផលប្រពន្ធជាជនជាតិវៀតណាមរបស់ អ៊ុច ស៊ុន ឡាយ និង កូន៣នាក់របស់គាត់ត្រូវបានសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ស្រដៀងគ្នានេះដែរ ឡាច គ្រី បានឱ្យដឹងថា «ខ្ញុំបាទក៏ដូចជាប្រជាជនក្នុងភូមិដឹង» ថា «បើសិនជាប្តីហ្នឹងខ្មែរ ហើយប្រពន្ធហ្នឹងវៀតណាមគឺយកទៅទាំងកូនទាំងប្រពន្ធ ហើយបើសិនជាប្តីហ្នឹងវៀតណាម ប្រពន្ធនោះខ្មែរគឺយកតែប្តីទេអត់មានយកកូនទេ»។

ស៊ិន ឆែម បានពន្យល់ថា ចំពោះដោតវ៉ាសនារបស់ក្មេងៗដែលមានម្តាយជាជនជាតិវៀតណាម អង្គការបានប្រកាសនៅក្នុងកិច្ចប្រជុំហើយ «គេនិយាយអញ្ចឹងមែន» របៀបដែលកូនកើតចេញពីអាពាហ៍ពិពាហ៍ចម្រុះដែលត្រូវបានបីបាច់ចិញ្ចឹមដោយម្តាយវៀតណាម «គេមិនទុកកូនទេ យកទៅ ទាំងអស់ ហើយកូនប៉ុន្មាននាក់យកទៅ ទាំងអស់ កូនពីរនាក់យកទាំងពីរ។ អត់ទុកទេទុកតែឪទេ»។ ស៊ិន ឆែម លើកឡើងថា «កូនៗយកទៅអស់រលីងគេមិនទុកផង។ គេថានាំជាប់សាសន៍។ ថេង ផល បានផ្តល់សក្ខីកម្មថា« ការងារហ្នឹងគឺការងាររបស់អង្គការគេហ្នឹង» គេថា «បើម្តាយវៀតណាមកូនក៏វៀតណាមដែរ» ដូច្នេះ «ត្រូវតែយកកូនទៅ ទាំងអស់។ បើឪពុកខ្មែរមិនអាចទុកបានទេកូនហ្នឹង។ បើម្តាយខ្មែរអាចទុកកូនបាន»។

ពៅ ហុង អាយុ៣៦ឆ្នាំ នៅក្នុងឆ្នាំ២០០២ មានស្រុកកំណើតនៅខេត្តព្រៃវែង។ មានឪពុកឈ្មោះ អៀង ពៅ ជាជនជាតិខ្មែរ និង ម្តាយឈ្មោះ ម៉ែង ស៊ីម ជាប់សែស្រឡាយវៀតណាម ដោយមានជីតាទួតជាជនជាតិចិន និងជីដូនទួតជាជនជាតិវៀតណាម។ មូលហេតុនេះហើយបងប្អូនបង្កើតនិងសាច់ញាតិខាងម្តាយ ទាំងអស់របស់ ពៅ ហុង ត្រូវខ្មែរក្រហមយកទៅសម្លាប់ស្ទើរតែផុតពូជក្រោមរូបភាពយកទៅរៀនសូត្រ។ ក្នុងចំណោមសាច់ញាតិរបស់ពៅ ហុង ទាំងអស់គឺមានតែពីរនាក់គត់ដែលមានសំណាងរួចផុតពីសេចក្តីស្លាប់គឺ ពៅ ហុង និង ម្តាយធំរបស់គាត់។

តាំងពីឆ្នាំ១៩៧៥ មកបក្សកុម្មុយនីស្តកម្ពុជាពិចារណាលើជាតិពន្ធវៀតណាមខាងម្តាយ ហើយជាលទ្ធផលការកំណត់គោលដៅលើគ្រួសារចម្រុះគឺកំណត់គោលដៅលើម្តាយជាជនជាតិវៀតណាម និងកូនៗរបស់គេ ដោយ ទុកជីវិតឪពុកជាជនជាតិខ្មែរ ហើយកំណត់គោលដៅលើឪពុកជាជនជាតិវៀតណាម ប៉ុន្តែគេទុកជីវិតឱ្យម្តាយជាជនជាតិខ្មែរនិងកូនៗរបស់គេ។

# និស្សិតមហាវិទ្យាល័យច្បាប់ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ចូលរួមដំណើរទស្សនកិច្ចសិក្សាពីប្រវត្តិសាស្រ្តខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ

ផេង ពង្សរ៉ាស៊ី



លោក ផេង ពង្សរ៉ាស៊ី (រូបខាងស្តាំ) នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ធ្វើបទបង្ហាញផ្ទាំងរូបថតទាក់ទងនឹងរបបខ្មែរក្រហមដែលតាំងបង្ហាញនៅខាងមុខការិយាល័យ ដល់និស្សិតមកពីមហាវិទ្យាល័យច្បាប់ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ម៉ោង៨កន្លះព្រឹក ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានទទួលស្វាគមន៍វត្តមាននិស្សិតមកពីមហាវិទ្យាល័យច្បាប់ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ចំនួន៥០នាក់ និងសាស្ត្រាចារ្យដឹកនាំ ដែលអញ្ជើញមកដល់ការិយាល័យផ្ទាល់ ក្នុងគោលបំណងចុះទស្សនកិច្ចសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមស្ថិតក្នុងខេត្តតាកែវ។ លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងជានាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានធ្វើបទបង្ហាញដល់និស្សិត និងសាស្ត្រាចារ្យ ជាសង្ខេបខ្លីៗពីផ្ទាំងពិព័រណ៍រូបថតទាំង៨ផ្ទាំង ដែលដាក់តាំងនៅខាងមុខការិយាល័យ ព្រមទាំងសៀវភៅ និងឯកសារជាច្រើនទៀត ដើម្បីឈ្វេងយល់ពីទិដ្ឋភាពទូទៅដែលបានកើតមានឡើងក្នុងរបបខ្មែរក្រហម។ ក្នុងពេលធ្វើបទបង្ហាញ និស្សិតខ្លះកត់ត្រា ខ្លះសួរសំណួរ និងខ្លះទៀតអានឯកសារដែលដាក់តម្កល់នៅលើតុសម្រាប់ភ្ញៀវ។ បន្ទាប់ពីទស្សនាបន្ទប់ពិព័រណ៍ និង

អានឯកសាររួចមក និស្សិតទាំងអស់ត្រូវចូលទៅបន្ទប់ថ្នាក់រៀនប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីសិក្សាឈ្វេងយល់ពីមាតិកាប្រវត្តិសាស្ត្រ ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩។

ជាកិច្ចចាប់ផ្ដើម លោក ដេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ និងសាស្ត្រាចារ្យ ជា សៀវម៉ី ដែលដឹកនាំដំណើរទស្សនកិច្ចសិក្សាសម្រាប់និស្សិត បានមានមតិក្រើនរំឭកដល់និស្សិតទាំងអស់ឱ្យយកចិត្តទុកដាក់ ស្ដាប់ កត់ត្រាពីមេរៀន និងរៀនសូត្រពីចំណេះដឹងថ្មីៗ ទាក់ទងនឹងរបបខ្មែរក្រហម។ នេះគឺជាឱកាសរបស់និស្សិតដែលមានសំណួរពីប្រវត្តិសាស្ត្រខ្មែរក្រហម យកមកសួរ និងដោះស្រាយចម្ងល់ផ្សេងៗប្រសិនជាមាន។ បន្ទាប់មកលោក ដេង ពង្សរ៉ាស៊ី បានចាប់ផ្ដើមការធ្វើបទបង្ហាញ ពីដើមកំណើតនៃការកកើតខ្មែរក្រហម, ខ្មែរក្រហមគ្រប់គ្រងប្រទេសក្នុងចន្លោះឆ្នាំ១៩៧៥ដល់១៩៧៩ និងឥទ្ធិពលរបស់ខ្មែរក្រហមក្រោយឆ្នាំ១៩៧៩។

បន្ទាប់ពីសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមរយៈពេលមួយព្រឹកនៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ នៅពេលរសៀលថ្ងៃដដែល និស្សិត សាស្ត្រាចារ្យដឹកនាំ និងបុគ្គលិកនៃមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានធ្វើដំណើរទៅកាន់ភូមិត្រពាំងស្វាយ ឃុំតាភេម ស្រុកត្រាំកក់ ដើម្បីទស្សនាសំណង់ចេតិយដែលបានសាងសង់ឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់ជាសំណងនិម្មិតរូបដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និង ផ្ទាំងពាក្យស្លោកស្ដីពីវិធីសាស្ត្រក្នុងការកសាងសន្តិភាព និងជួយទប់ស្កាត់អំពើប្រល័យពូជសាសន៍តាមរយៈការអប់រំ និងការនិយាយពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ ស្ថិតក្នុងទីតាំងនេះ និស្សិតអាចជួបផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឈ្មោះ លុយ ញ៉ាន (ឈ្មោះបដិវត្តន៍ លុយ ធឹម) អាយុ៦៨ឆ្នាំ រស់នៅភូមិត្រពាំងស្វាយ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ។ លុយ ញ៉ានបានចែករំលែក





និស្សិតមកពីមហាវិទ្យាល័យច្បាប់ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បទពិសោធន៍ជីវិតឆ្លងកាត់របបខ្មែរក្រហម និងការរស់នៅរបស់ខ្លួនក្រោយឆ្នាំ១៩៧៩ ជាមួយតាម៉ុក ដោយការចាកចេញពីស្រុកកំណើតទៅកាន់ភាគខាងលិចប្រទេសកម្ពុជាពីដើមឆ្នាំ១៩៧៩ ប្រាប់ដល់និស្សិតចូលរួម។ លុយ ញ៉ាន ស្គាល់ តាម៉ុក ច្បាស់លាស់ ព្រោះ ញ៉ាន ជាមនុស្សដែលតាម៉ុក ខស្សាហ៍ហៅប្រើជាងអ្នកឯទៀត។ បន្ទាប់ពីស្ដាប់បទពិសោធន៍របស់ លុយ ញ៉ាន រួច នៅម៉ោង២រសៀល ក្រុមនិស្សិតបានធ្វើដំណើរទៅកាន់អតីតមន្ទីរឃុំឃាំងក្រាំងតាចាន់ ជាទីតាំងសម្ងាប់ក្នុងរបបខ្មែរក្រហម ដែលបច្ចុប្បន្នគឺជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ក្រាំងតាចាន់ ដើម្បីជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់ទៀតឈ្មោះ យិន សឿន អាយុ៧៣ឆ្នាំ រស់នៅ

ភូមិព្រៃតាខាប ឃុំគុស ស្រុកត្រាំកក់ គឺជាសាក្សីដែលដឹងឮពីហេតុការណ៍កើតឡើងក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់។ យិន សឿន បាននិយាយរៀបរាប់ និងនាំនិស្សិតទាំងអស់ទៅកាន់ទីតាំងដែលខ្មែរក្រហមនាំអ្នកទោសទៅឃុំឃាំង និងទីតាំងសម្លាប់មួយចំនួន។

ដំណើរទស្សនកិច្ចសិក្សានេះចប់នៅពេលល្ងាច ហើយនិស្សិតមួយចំនួនក៏បានបង្ហាញពីចំណាប់អារម្មណ៍ដូចខាងក្រោម៖

សុខ ណាថារក្សា ភេទស្រី អាយុ២១ឆ្នាំ គឺជានិស្សិតឆ្នាំទី៤ នៃសកលវិទ្យាល័យជាតិគ្រប់គ្រង ។ បន្ទាប់ពីបានចូលរួមទស្សនកិច្ចសិក្សាពីរបបខ្មែរក្រហមរួច ធ្វើឱ្យខ្ញុំយល់ដឹងច្រើនពីរបបប្រល័យពូជសាសន៍ ដែលលោកគ្រូបានបង្ហាញ អំពីអត្ថន័យពាក្យសហករណ៍ ដែលខ្ញុំមិនធ្លាប់បានដឹង ថាជាកន្លែងធ្វើការងារជុំគ្នាជាក្រុមៗ មួយវិញទៀត ខ្ញុំយល់ដឹងថាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ បានបន្សល់ទុកនូវជំងឺបាក់ស្បាត ស្ត្រីមេម៉ាយ ចាស់ជរាក្មេងកំព្រា និងគ្រាប់មីនយ៉ាងច្រើន។ លើសពីនេះ ខ្ញុំបានទៅទស្សនកិច្ចសិក្សាដល់ទីតាំងសម្លាប់របស់ខ្មែរក្រហមផ្ទាល់។ ជាក់ស្តែង ទីតាំងសម្លាប់គឺមិនមែនមានតែនៅគុកទួលស្លែង ឬបឹងជើងឯកទេ គឺមានតាមបណ្តាខេត្តជាច្រើនទៀត។ ខ្ញុំនឹងសិក្សាឈ្វេងយល់បន្ថែមអំពីរបបប្រល័យពូជសាសន៍ឱ្យកាន់តែច្បាស់ជាងនេះទៅទៀត។ ការចូលរួមទស្សនកិច្ចរយៈពេលមួយថ្ងៃនេះ ពិតជាមានសារសំខាន់យ៉ាងខ្លាំង ព្រោះបានផ្តល់ឱកាសឱ្យខ្ញុំបានស្គាល់ និងយល់ដឹងពីរបបខ្មែរក្រហម ដើម្បីទុកជាការចងចាំ និងចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានការរីកចម្រើន។ យើងទាំងអស់គ្នាត្រូវនាំគ្នាជៀសវាង កុំឱ្យមានរបបខ្មែរក្រហមកើតមានទៀត ។ មួយវិញទៀត ខ្ញុំក៏ចង់ចែករំលែកទៅកាន់អ្នកដទៃទៀតឱ្យបានដឹងដូចខ្ញុំដែរ។ ខ្ញុំចង់ឱ្យនិស្សិតគ្រប់រូប គួរតែសិក្សា និងស្គាល់ទីតាំងប្រវត្តិសាស្ត្រឱ្យបានច្រើន ហើយដក់ជាប់ក្នុងចិត្តថា របបខ្មែរក្រហមប្រជាជនត្រូវឆ្លងកាត់ការលំបាកអ្វីខ្លះ។ យើងគ្រប់គ្នាត្រូវនឹកឃើញសោកនាដកម្មក្នុងរបបខ្មែរក្រហមកុំឱ្យភ្លេច។ ដើម្បីទប់ស្កាត់កុំឱ្យរបបខ្មែរក្រហមកើតឡើងវិញម្តងទៀត យុវជនទាំងអស់ត្រូវខិតខំរៀនសូត្រឱ្យច្រើន នាំគ្នាលុបបំបាត់



និស្សិតមកពីមហាវិទ្យាល័យច្បាប់ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ទស្សនកិច្ចសិក្សានៅអតីតមន្ទីរឃុំឃាំងក្រាំងតាចាន់ ដែលបច្ចុប្បន្នគឺជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្រាំងតាចាន់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អំពើហិង្សាក្នុងសង្គម និងចែករំលែកទៅកាន់ក្មេងៗជំនាន់ក្រោយឱ្យបានដឹង។

កាន គាតុង ភេទប្រុស អាយុ២០ឆ្នាំ គឺជានិស្សិតឆ្នាំទី៤ នៃសកលវិទ្យាល័យជាតិគ្រប់គ្រង។ ដំណើរទស្សនកិច្ចសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម ធ្វើឱ្យខ្ញុំបានដឹងពីចំណុចកកើតរហូតដល់ពេលបញ្ចប់ទៅវិញនៃរបបប្រល័យពូជសាសន៍។ មូលហេតុដែលធ្វើឱ្យខ្ញុំមកចូលរួមទស្សនកិច្ច ព្រោះតែខ្ញុំចង់ដឹងអំពីប្រវត្តិសាវតានៃការឆ្លងកាត់សម័យកាលដ៏ជូរចត់ ការហូបចុកមិនបានគ្រប់គ្រាន់ កូនក្មេងត្រូវងើបពីព្រលឹមដើម្បីទៅធ្វើការ។ បើខ្ញុំកើតទាន់របបខ្មែរក្រហម ច្បាស់ជាមិនបានរៀនសូត្រទេ ព្រោះសាលារៀនត្រូវខ្មែរក្រហមបំបិទទាំងអស់ ហើយសម្លាប់អ្នកចេះដឹង។ ខ្ញុំមានអារម្មណ៍សប្បាយរីករាយ នៅពេលបានចូលរួមទស្សនកិច្ចបែបប្រវត្តិសាស្ត្រខ្មែរក្រហម ដែលធ្វើឱ្យខ្ញុំទទួលបានចំណេះយ៉ាងច្រើនទាក់ទងនឹងប្រវត្តិសាស្ត្រ។ ក្រោយពីដំណើរទស្សនកិច្ចសិក្សានេះ ខ្ញុំត្រូវការយល់ដឹងពីប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួនឯងឱ្យច្រើន។



និស្សិតមកពីមហាវិទ្យាល័យច្បាប់ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង កំពុងស្តាប់ចាស់ទុំ រៀបរាប់រឿងរ៉ាវដែលបានកើតឡើងចំពោះគាត់ និងនៅក្នុងភូមិឃុំរបស់គាត់ក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គក់ ស្រីលក្ខ័ណ៍ ភេទស្រី អាយុ២២ឆ្នាំ គឺជានិស្សិតឆ្នាំទី៤ នៃសកលវិទ្យាល័យជាតិគ្រប់គ្រង។ បន្ទាប់ពីខ្ញុំបានចូលរួមដំណើរទស្សនកិច្ចសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមមក ខ្ញុំទទួលបានចំណេះដឹងជាច្រើន ដូចជាសាច់រឿងផ្ទាល់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលគាត់ធ្លាប់ឆ្លងកាត់ការលំបាក និងជម្លៀសជាច្រើនកន្លែង។ ប្រវត្តិសាស្ត្រពិតជាមានសារសំខាន់ណាស់ដល់កូនខ្មែរគ្រប់រូប ត្រូវដឹងពីរបបមួយទៅរបបមួយ។ នៅក្នុងរបបខ្មែរក្រហមមានការសម្លាប់ប្រជាជនជាច្រើន ធ្វើឱ្យខ្ញុំមានការអាណិតអាសូរដល់ជនរងគ្រោះបែកបាក់ឪពុកម្តាយ និងទទួលរងនូវការគំរាមកំហែង។ ប្រសិនជាខ្ញុំកើតទាន់ក្នុងរបបខ្មែរក្រហម ក៏មានអារម្មណ៍អាណិតដល់ខ្លួនឯងដែរ។ ចុងបញ្ចប់ខ្ញុំចង់ឱ្យយុវជនជំនាន់ក្រោយសិក្សាឈ្វេងយល់ឱ្យបានច្រើនអំពីរបបខ្មែរក្រហម ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសជាតិ។ ដើម្បីលុបបំបាត់របបខ្មែរក្រហមកុំឱ្យកើតឡើងវិញម្តងទៀតត្រូវខិតខំប្រឹងប្រែងរៀនសូត្រ ឱ្យក្លាយជាទំពាំងស្នងឫស្សីមួយរូបនៅក្នុងប្រទេសជាតិ។

ទឹម ពណ្ណរាយ ភេទប្រុស អាយុ២០ឆ្នាំ គឺជានិស្សិតឆ្នាំទី៤ នៃសកលវិទ្យាល័យជាតិគ្រប់គ្រង។ ក្នុងដំណើរទស្សនកិច្ចសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម ខ្ញុំមានអារម្មណ៍ក្តុកក្តួលយ៉ាងខ្លាំង ហើយមិននឹកស្មានថាប្រជាជនអាចមានជីវិតមកដល់សព្វថ្ងៃនេះទេ។ ប្រជាជនត្រូវទទួលរងនូវភាពភ័យខ្លាចៗ រយៈពេលមួយថ្ងៃនេះ ខ្ញុំទទួលបានចំណេះដឹងជាច្រើន ខ្ញុំស្គាល់ទីតាំងសម្លាប់ និងបានឃើញរណ្តៅសាកសព។ ចុងបញ្ចប់ខ្ញុំចង់ឱ្យសិស្សនិស្សិតជំនាន់ក្រោយៗទៀតបានចូលរួមទស្សនកិច្ចសិក្សាពីរបបខ្មែរក្រហមឱ្យបានញឹកញាប់ ព្រោះវាផ្តល់ផលប្រយោជន៍សម្រាប់ប្រទេសជាតិ ក៏ដូចជាជួយផ្សព្វផ្សាយ ចងចាំ និងទប់ស្កាត់កុំឱ្យរបបនេះកើតឡើងម្តងទៀត។

# និស្សិតមហាវិទ្យាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រងចុះទស្សនកិច្ចសិក្សាមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

ជុន ស្រីពៅ



និស្សិតមកពីមហាវិទ្យាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ទស្សនកិច្ចសិក្សានៅអតីតមន្ទីរសន្តិសុខជ្រៃ ស្ថិតនៅក្នុងភូមិជ្រៃ ឃុំបាបោង ស្រុកពាមរក៍ ខេត្តព្រៃវែង និងស្តាប់ចាស់ទុំ រៀបរាប់អំពីរឿងរ៉ាវដែលបានកើតឡើងចំពោះគាត់ និងនៅក្នុងភូមិឃុំរបស់គាត់ក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៤ និស្សិតឆ្នាំទី៤ មកពីមហាវិទ្យាល័យ នីតិសាស្ត្រ សាកលវិទ្យាល័យជាតិគ្រប់គ្រង នៅទីក្រុងភ្នំពេញចំនួន ៣៥នាក់ ក្រោមការដឹកនាំដោយសាស្ត្រាចារ្យ ជា សៀវម៉ី បានចុះមកទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ នេះគឺជាដំណើរទស្សនកិច្ចសិក្សាលើកដំបូងសម្រាប់និស្សិតដើម្បីសិក្សាឈ្វេងយល់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) វិធីសាស្ត្រស្រាវជ្រាវ និងទស្សនកិច្ចសិក្សាទៅកាន់ទីតាំងសម្លាប់មនុស្សក្នុងរបបខ្មែរក្រហម។

និស្សិតទាំងអស់បានមកដល់ការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និងទទួលការស្វាគមន៍ពីបុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ លោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានណែនាំនិស្សិតទាំងអស់អំពីតួនាទី និងបេសកកម្មរបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង, បង្ហាញស្លាកសញ្ញាដែលជានិម្មិតសញ្ញារបស់

មជ្ឈមណ្ឌលឯកសារកម្ពុជា, សៀវភៅដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងឯកសារជាច្រើនដែលដាក់តម្កល់សម្រាប់បម្រើដល់សិស្ស និស្សិត គ្រូបង្រៀន អ្នកស្រាវជ្រាវ និងសាធារណជនទូទៅ និងពិព័រណ៍រូបថតស្តីពីរបបខ្មែរក្រហម។ ចំណែកលោកស្រីសាស្ត្រាចារ្យ បានក្រើនរំឭកដល់ក្រុមនិស្សិតឱ្យត្រៀមលក្ខណៈក្នុងការសរសេររបាយការណ៍ខ្លីមួយ ស្តីអំពីទស្សនកិច្ចសិក្សានេះ។

លោក ផេង ពង្សរ៉ាស៊ី ធ្វើបទបង្ហាញពីវិធីសាស្ត្រស្រាវជ្រាវផ្តោតសំខាន់លើវិធីសាស្ត្រក្នុងការសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងចាក់បញ្ចាំងខ្សែវីដេអូចំនួនពីរគឺ គុកទួលស្លែង និងកុំស្មានបងភ្លេច។ លោក ផេង ពង្សរ៉ាស៊ី បង្ហាញគេហទំព័រចំនួនពីរ និងពន្យល់ពីការប្រើប្រាស់គេហទំព័រទាំងពីរនេះដល់និស្សិតក្នុងការស្វែងរកឯកសារទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហមសម្រាប់អាន។ គេហទំព័រទាំងពីរនេះគឺ www.dccam.org និង www.khmerrouge-history.org គឺជាគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ មុននឹងបញ្ចប់កម្មវិធីសម្រាប់ពេលព្រឹក លោកស្រីសាស្ត្រាចារ្យជា សៀវម៉ី បានថ្លែងអំណរគុណចំពោះលោក ផេង ពង្សរ៉ាស៊ី និងបានឱ្យតំណាងនិស្សិតប្រគល់លិខិតថ្លែងអំណរគុណសរសេរដោយដៃ ដើម្បីបញ្ជាក់ពីទឹកចិត្ត និងការសហការល្អជាមួយគ្នា។ លោកស្រីសាស្ត្រាចារ្យមានមតិទៅកាន់និស្សិតថា ៖ «ថ្ងៃនេះ! យើងជោគជ័យហើយ ចំពោះការមកទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ ខ្ញុំតំណាងឱ្យនិស្សិតសាកលវិទ្យាល័យជាតិគ្រប់គ្រងចំនួន៣៥នាក់ ពិតជាមានកិត្តិយសណាស់ ដែលបានទទួលការណែនាំផ្ទាល់ពីលោក ផេង ពង្សរ៉ាស៊ី។ មិនត្រឹមតែប៉ុណ្ណោះ ក៏ទទួលបាននូវបទពិសោធន៍ល្អ ដូចជាការសម្ភាសន៍ និងស្គាល់ពីគេហទំព័រចំនួនពីររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំផ្តាំទៅនិស្សិតទាំងអស់ឱ្យខិតខំប្រឹងប្រែងអានឯកសារបន្តទៀត»។

នៅវេលាម៉ោង១២ និង ៥០នាទី បន្ទាប់ពីសម្រាកនិងហូបបាយថ្ងៃត្រង់រួច និស្សិតទាំងអស់បានធ្វើដំណើរទៅកាន់ទីតាំងសម្លាប់ទួលជ្រៃ ស្ថិតនៅឃុំបាបោង ស្រុកពាមរក៍ ខេត្តព្រៃវែង។ លោក ហម យាង មានអាយុ៧០ឆ្នាំ រស់នៅភូមិសុវាម្រិត(អតីតភូមិទួលជ្រៃ) ឃុំបាបោង ស្រុកពាមរក៍ ខេត្តព្រៃវែង បានចែករំលែករឿងរ៉ាវដែលបានកើតឡើងនៅទីនេះ។ កាលនោះ លោក ហម យាង មានអាយុ២៨ឆ្នាំ ហើយទីតាំងទួលជ្រៃនេះ មិនមានផ្ទះនិងប្រជាជនរស់នៅឡើយ។ ខ្មែរក្រហមបានយកទីតាំងនេះ ធ្វើជាកន្លែងសម្លាប់មនុស្ស។ លោក ហម យាងបានរៀបរាប់ពីប្រភេទប្រជាជនដែលត្រូវបានយកមកសម្លាប់ មានដូចជា ប្រជាជន ១៧ មេសា, មន្ត្រី ឬទាហាននៅក្នុងរដ្ឋការ លន់ នល់ និង កម្មាភិបាលខ្មែរក្រហម




និស្សិតមកពីមហាវិទ្យាល័យច្បាប់ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



និស្សិតមកពីមហាវិទ្យាល័យច្បាប់ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និងទស្សនាទីតាំងសម្លាប់នៅក្នុងឃុំបាបោង ស្រុកពាមរក៍ ខេត្តព្រៃវែង ក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងភូមិភាគបូព៌ា។ លោក ហម យាង បានបន្ថែមថា ក្រៅពីទីតាំងទួលជ្រៃ ក៏មានទីតាំងសម្លាប់ដ៏ធំមួយទៀតដែរ ស្ថិតនៅស្រុកបាភ្នំ ខេត្តព្រៃវែងនេះ គឺទីតាំងសម្លាប់ភ្នំឈើកាច់ ឬភ្នំកំបូក។ បន្ទាប់ពីបានស្តាប់ លោក ហម យាង មានប្រសាសន៍ចប់ លោក ផេង ពង្សរ៉ាស៊ី បានបកស្រាយឡើងវិញនូវចំណុចខ្លះៗ ដែលលោកហម យាង បានរៀបរាប់ខាងលើ និងបន្ថែមនូវចំណុចមួយចំនួន។ ខាងក្រោមគឺជាចំណាប់អារម្មណ៍របស់និស្សិត ដែលបានចុះមកទស្សនកិច្ច៖

ខ្ញុំឈ្មោះ សាត ស៊ីដែត ភេទស្រីអាយុ២២ឆ្នាំ គឺជានិស្សិតឆ្នាំទី៤ ផ្នែកច្បាប់ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង។ នៅក្នុងថ្ងៃនេះ ខ្ញុំទទួលបានបទពិសោធន៍ថ្មី ព្រោះកាលខ្ញុំរៀននៅវិទ្យាល័យ ខ្ញុំក៏ធ្លាប់មានកម្មវិធីទស្សនកិច្ចសិក្សានៅគុកទួលស្លែងដែរ។ កាលនោះខ្ញុំរៀនថ្នាក់ទី១០ ប៉ុន្តែពេលនោះខ្ញុំគ្រាន់តែទៅ ស្តាប់ការនិយាយខ្លះៗ ហើយបានមើលរូបភាពខ្លះៗនៅក្នុងគុកប៉ុណ្ណោះ។ ប៉ុន្តែនៅពេលដែលខ្ញុំបានមកដល់ការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ខ្ញុំបានទស្សនាខ្សែភាពយន្តឯកសារ (មន្ទីរស-២១) ហើយលោក ផេង ពង្សរ៉ាស៊ី បានពន្យល់បន្ថែម ដូច្នេះធ្វើឱ្យខ្ញុំបានដឹងកាន់តែស៊ីជម្រៅថែមទៀត ទាក់ទងនឹងគុកទួលស្លែង ហើយខ្ញុំឃើញថាវាពិតជាកើតឡើងដូច្នេះមែន។ ការមកដល់ទីតាំងសម្លាប់ទួលជ្រៃនេះ









ដំបូង ខ្ញុំគិតថាមានតែប្រជាជនដែលត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញប៉ុណ្ណោះ ដែលត្រូវបានយកមកសម្លាប់នៅទីនេះ។ ប៉ុន្តែតាមរយៈដែលខ្ញុំបានស្តាប់ការចែករំលែករបស់លោកតា ហម ឃាង ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ខ្ញុំទទួលបានចំណេះដឹងថ្មីមួយផ្សេងទៀតគឺ ប្រជាជនជម្លៀសផ្សេងទៀតមកពីតំបន់ភូមិភាគបូព៌ា ក៏ត្រូវបានយកមកសម្លាប់នៅទីនេះដែរ។ ខ្ញុំនឹងយកចំណេះដឹងអំពីដំណើរទស្សនកិច្ចទៅចែករំលែកដល់មិត្តភក្តិរបស់ខ្ញុំ ដើម្បីឱ្យគាត់បានដឹងដូចខ្ញុំដែរ។ ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដែលបានបង្កើតកម្មវិធីទស្សនកិច្ចសិក្សានេះឡើង។ នេះគឺជាឱកាសដ៏ល្អ សម្រាប់និស្សិត ក្នុងការសិក្សាអំពីភាពជាក់ស្តែងទាក់ទងទៅនឹងរបបខ្មែរក្រហម។

ខ្ញុំឈ្មោះ ហុន សុណារី ភេទស្រី គឺជានិស្សិតផ្នែកច្បាប់ មកពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។ ថ្ងៃនេះ ខ្ញុំសប្បាយរីករាយដែលបានមកទស្សនកិច្ចសិក្សានៅក្នុងខេត្តខ្លួនឯង។ មួយវិញទៀត ខ្ញុំទើបតែដឹងថា នៅក្នុងខេត្តព្រៃវែងក៏មានមជ្ឈមណ្ឌលឯកសារទាក់ទងនឹងសម័យខ្មែរក្រហមដែរ។ ដូច្នេះហើយ បានជាអ្នកគ្រូ ជា សៀវម៉ី បាននាំខ្ញុំមកកាន់កន្លែងនេះ ដើម្បីឱ្យខ្ញុំបានដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ ខ្ញុំទទួលបានចំណេះដឹងមួយចំនួននៅក្នុងថ្ងៃនេះ ទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម និងវិធីសាស្ត្រស្រាវជ្រាវខ្លះៗដើម្បីជាជំនួយដល់ការសរសេរសារណា



និស្សិតមកពីមហាវិទ្យាល័យច្បាប់ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ទស្សនកិច្ចសិក្សានៅជម្ល្បមណ្ឌលឯកសារខេត្តព្រៃវែង ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឆ្នាំខាងមុខ ព្រមទាំងគេហទំព័រចំនួន២ដែលយើងអាចធ្វើការសិក្សាស្រាវជ្រាវបាន។ ពេលមកដល់ទីតាំងសម្លាប់ទួលជ្រៃដំបូង ខ្ញុំគិតថាគឺជាវត្តសម្រាប់ប្រជាជនមកគោរពប្រណិប័តន៍ ប៉ុន្តែបន្ទាប់ពីខ្ញុំបានស្តាប់លោក ដេង ពង្សរ៉ាស៊ី និងលោក ហម ឃាង រួចទើបខ្ញុំដឹងថា ទីកន្លែងនេះ គឺជាទីតាំងសម្លាប់មនុស្សនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដែលបានរៀបចំកម្មវិធីនេះឡើង។ ជាចុងក្រោយ ខ្ញុំចង់ឱ្យក្មេងជំនាន់ក្រោយបានឈ្វេងយល់ពីរបប ប៉ុល ពត ថាតើប្រជាជនរស់នៅក្នុងរបបនេះលំបាកយ៉ាងដូចម្តេចខ្លះ។ យើងទាំងអស់គ្នា ត្រូវខិតខំប្រឹងប្រែងរៀនសូត្រ និងជួយទប់ស្កាត់កុំឱ្យរបបនេះវិលមកវិញម្តងទៀត។

# ថ្នាំមួយគ្រាប់ប្តូរនឹងជីវិតម្តាយជួយកូនស្រីមានជំងឺរាក

*រី លក្ខិណា*



សម សុខ (រូបអង្គុយកណ្ដាល) រៀបចំពិធីបុណ្យ១០០ថ្ងៃ ជូនប្តីឈ្មោះ រី សារឿន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រឿងរ៉ាវដែលនៅតែចងចាំមិនភ្លេចទោះបីរំពុកមកលើកណា ទឹកភ្នែកនៅតែហូរ គឺការជួយជីវិតកូនស្រីដែលមានជំងឺរាក ត្រូវប្តូរដោយយកមាន់មួយក្បាលទៅប្តូរជាមួយប្រជាជនថ្មីនូវថ្នាំមួយគ្រាប់។ ទោះបីជាដឹងថាបើឈ្លបចាប់បានច្បាស់ជាស្លាប់ជាមិនខាត។ នៅយប់មួយដែលកូនស្រីអាយុមួយខួបរបស់ខ្ញុំរាកមិនបាត់សោះរយៈពេលកន្លះខែកន្លងមកហើយ។ ឪពុកខ្ញុំបានប្រាប់ខ្ញុំថា កូនចេញទៅក្រៅសិនទៅ បើវាស្លាប់ ចាំគាត់យកទៅកប់។ តែដោយទឹកចិត្តជាម្តាយមិនដាច់ចិត្ត ខ្ញុំបានយកសារុងមួយទៅប្តូរនឹងមាន់មួយជាមួយប្រជាជនមូលដ្ឋាន។ ពេលបានមាន់ខ្ញុំដាក់លាក់ក្នុងអាវ (អាវជំនាន់នោះធំៗ) ដើរឆ្លងស្ទឹងតម្រង់ទៅភូមិដែលមានប្រជាជនថ្មីរស់នៅ និងបានសុំប្តូរថ្នាំពេទ្យមួយគ្រាប់ពណ៌ក្បឿង។ ពេលបានថ្នាំខ្ញុំត្រឡប់មកវិញ។ នៅតាមផ្លូវខ្ញុំជួបនឹងក្រុមឈ្លបដែលដើរមកពីស្ទឹង។ ឈ្លបបានសួរខ្ញុំថា «មិត្តនារីមកពីណា?» ខ្ញុំបានឆ្លើយថាមកពីភូមិស្ទឹង។ ឈ្លបបានឆែកហោប៉ៅរបស់ខ្ញុំ ឃើញមានថ្នាំមួយគ្រាប់។ ឈ្លបមិនបានសួរនាំច្រើនទេ ក៏ចាប់ខ្ញុំចងនឹងដើមកោះ ដោយមានឈ្លបខ្លះទៅវិញ នៅសល់តែម្នាក់



រូបថត សម សុខន បង្រៀនសិស្សថ្នាក់ទី៤ នៅសាលាបឋមសិក្សាទួលស្វាយព្រៃ ឆ្នាំ១៩៩៤ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

យាមខ្ញុំ។ ខណៈពេលនោះខ្ញុំដឹងថា ខ្ញុំពិតជាមិនអាចនៅមានជីវិតរស់ទេ។ ពេលដែលបាត់ខ្ញុំយូរពេក ឪពុកខ្ញុំបានទៅរកមេភូមិ ឈ្មោះ «ឪគ្រុឌ»។ ឪគ្រុឌ គឺជាប្រជាជនចាស់ តែគាត់ស្រឡាញ់និងរាប់អានគ្រួសារខ្ញុំណាស់ ទោះបីគ្រួសារខ្ញុំជាប្រជាជនថ្មីក៏ដោយ។ ដោយសារបានឪគ្រុឌ ទើបខ្ញុំបានរួចជីវិត ព្រោះគាត់ទៅរកខ្ញុំនៅនឹងគល់ឈើកកោះដែលឈ្លបចង។ ឪគ្រុឌបានបញ្ជាឱ្យឈ្លបដោះលែងខ្ញុំ ហើយប្រាប់ឈ្លបថាមានរឿងអ្វី គាត់គឺជាអ្នកទទួលខុសត្រូវ។ ខ្ញុំបានរួចជីវិត និងយកថ្នាំមួយគ្រាប់មកពុះជា៨ចំណែក កិនឱ្យកូនខ្ញុំលេបអស់៣ទៅ៤ចំណែក កូនខ្ញុំក៏បានធូរស្បើយបន្តិចម្ដងៗ និងមានជីវិតរហូតមកដល់សព្វថ្ងៃ។

ខ្ញុំឈ្មោះ សម សុខន សព្វថ្ងៃមានអាយុ៧៤ឆ្នាំ រស់នៅក្រុងភ្នំពេញ។ ខ្ញុំមានស្រុកកំណើតនៅភូមិត្រពាំងទា ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ខ្ញុំគឺជាកូនទី៤ ក្នុងចំណោមបងប្អូនចំនួន៦នាក់ ក្នុងនោះស្រី៥នាក់ និងប្រុសម្នាក់។ សព្វថ្ងៃបងប្អូនរបស់ខ្ញុំស្លាប់អស់ហើយនៅសល់តែខ្ញុំម្នាក់ឯង។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៣ ពីសង្គមចាស់ នៅសាលាព្រៃល្វា។ កាលពីជំនាន់សង្គមគ្មានម៉ូតូជិះទៅរៀនទេ ត្រូវជិះឡានឈ្នួលពីភូមិ ទៅកាន់បន្ទប់ជួលនៅព្រៃល្វា ជួនកាលបងថ្លៃខ្ញុំជិះកង់ដឹកខ្ញុំទៅបន្ទប់ជួល។ ពេលដែលប្រឡងបាក់អង់ជាប់ ខ្ញុំបានមករៀននៅភ្នំពេញ នៅជិតស្តាតចាស់ ដែលសាលាមានឈ្មោះថា «យុវជនស្រោចស្រង់ជាតិ» ខ្ញុំរៀនចប់ថ្នាក់ទី១«ចាស់» នៅឆ្នាំ១៩៧២។ បន្ទាប់ពីរៀនចប់ខ្ញុំប្រឡងចូលសាលាពេទ្យក្បែរមន្ទីរពេទ្យរុស្ស៊ី ផ្នែកពេទ្យបឋម។ ឆ្នាំ១៩៧៤ ខ្ញុំរៀបការជាមួយប្ដីដែលធ្វើជាពេទ្យបឋមដូចគ្នា។ ផ្ទះជួលរបស់ខ្ញុំនៅទួលទំពូង និងដើរមកធ្វើការនៅពេទ្យរុស្ស៊ី។ ពេលខ្លះដើរចាក់ថ្នាំឱ្យប្រពន្ធៗទាហាន ដែលនៅមួយជួរផ្ទះលោកសេនាប្រមុខ លន់ នល់។

នៅឆ្នាំ១៩៧៥ ពេលកងទ័ពខ្មែរក្រហមចូលមក ប្ដីខ្ញុំបានទៅបំពេញបេសកកម្មនៅខេត្តកំពង់ឆ្នាំង ចំណែកខ្ញុំនៅភ្នំពេញ ព្រោះកាលនោះខ្ញុំមានផ្ទៃពោះ៥ខែ។ ខ្មែរក្រហមចូលមកជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញឱ្យទៅស្រុកកំណើតរៀងៗខ្លួន។ ខ្ញុំ និង ម្ដាយរបស់ខ្ញុំក៏ធ្វើដំណើរទៅកាន់ខេត្តដែលជាស្រុកកំណើត។ នៅតាមផ្លូវខ្ញុំបានដាក់ថ្នាំពេទ្យមួយចំនួន អង្ករ ឆ្នាំង ចាន និងដាក់របស់របរលើកង់ រួចបណ្ដើរកង់មកជាមួយនឹង

ប្រជាជនដទៃទៀត។ ខ្ញុំចេញពីផ្សារដើមថ្កូវតម្រង់មកប្រមុះជ្រូកក្បាលថ្នល់ ឆ្លងស្ពានច្បារអំពៅ ហើយយោធាឱ្យខ្ញុំធ្វើដំណើរទៅបូព៌ា ប៉ុន្តែខ្ញុំអត់ទៅ ខាងព្រៃវែង ស្វាយរៀងទេ ខ្ញុំសុំកងទ័ពខ្មែរក្រហមមកតាមព្រែកប្រាវិញ។ ខ្ញុំចេះតែធ្វើដំណើរមករហូតដល់វត្តកោះខែល បានបែកផ្លូវជាមួយនឹងមីងរបស់ខ្ញុំ ដោយគាត់មិនឆ្លងទូកមកត្រើយខាងលិចទេ ឆ្លងមកតែខ្ញុំម្នាក់ឯង។ ពេលដែលចុះទូកខ្ញុំជាន់ខុសក្តារបានអុកគូទធ្វើឱ្យកូនដែលនៅក្នុងផ្ទៃមិនបម្រាសមួយយប់ ខ្ញុំនឹកស្មានថាកូនមានបញ្ហាហើយ តែស្អែកឡើងក៏បំរាស់ធម្មតា។ ខ្ញុំបន្តដំណើរទៅមុខទៀតតាមផ្លូវព្រែកគ្រួស មកដល់វត្តចារ ហើយសម្រាកបន្តិចទើបខ្ញុំបន្តដំណើរមកមុខទៀតដល់វត្តឆ្នាត់ ទើបខ្មែរក្រហមចាប់ផ្តើមឆែករបស់របរខ្ញុំដកយកថ្នាំពេទ្យមួយចំនួន។ ខ្ញុំអង្វរខ្មែរក្រហមព្រោះខ្ញុំពោះធំត្រូវការប្រើថ្នាំពេទ្យ។ ខ្មែរក្រហមយោគយល់ទើបមិនដកយកថ្នាំទាំងអស់។ ខ្ញុំបានមកដល់ផ្ទះកំណើត រួមនឹងបងប្អូនខ្ញុំដែលគាត់ធ្វើដំណើរមកពីខេត្តផ្សេងៗ មកជុំគ្នានៅស្រុកកំណើតទាំងអស់គ្នា។ ពេលមកដល់ផ្ទះពូប៊ុច ដែលជាមេភូមិ បានមកកត់ឈ្មោះ រួមទាំងឆែកយកថ្នាំពេទ្យពីខ្ញុំអស់រលីង។ ដោយសារតែខ្ញុំមានផ្ទៃពោះការងារមិនសូវជាធ្ងន់ទេ ការងារខ្ញុំកាប់ដើមទន្ទ្រានខែត្រ និងស្ទូងស្រូវ។ ក្រោយពេលដែលខ្ញុំសម្រាលកូនរួចនៅខែកញ្ញា ខ្ញុំនៅតែកាប់ទន្ទ្រានខែត្រដដែល ដោយដាក់កូនក្នុងថ្នក់សំពត់។ ពេលរដូវភ្លៀងមកដល់ ខ្មែរក្រហមផ្លាស់ខ្ញុំពីកាប់ទន្ទ្រានខែត្រឱ្យមករើសូត្រវិញ ដោយខ្ញុំយកកូនមកតាម ចងអង្រឹងក្បែរកន្លែងដែលខ្ញុំរើសូត្រ។ ចំណែករបបអាហារគឺខ្មែរក្រហមចែកស្រូវ១ផ្តិលសម្រាប់ខ្ញុំ ចំណែកកូនខ្ញុំវិញបានតែកន្លះផ្តិលទេ បើយកមកបុកគឺបាន២កំប៉ុង សម្រាប់មួយថ្ងៃ។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសខ្ញុំម្តងទៀតតាមរយៈរថភ្លើង ដោយប្រាប់ថាឱ្យទៅរស់នៅកន្លែងថ្មី។ ពេលរសៀលខ្មែរក្រហមឱ្យប្រជាជនថ្មីទាំងអស់ មកជួបជុំគ្នានៅមុខវត្តអង្គអណ្តែត។ ចំណែកក្រុមគ្រួសារខ្ញុំ មានតែបងស្រីធំ ដែលមិនបានជម្លៀសចេញ ព្រោះគាត់ជាអ្នកមូលដ្ឋាន។ ក្រុមគ្រួសារខ្ញុំត្រូវដើរទាំងអស់គ្នា ព្រោះមានរទេះតែមួយសម្រាប់ដាក់របស់របរ។ ខ្ញុំបីកូនតូចដើររហូតដល់ខាងលិចផ្សារសំរោងយ៉ោង តម្រង់មកឡើងរថភ្លើងនៅរ៉ាកុមាររាជា។ ខ្ញុំធ្វើដំណើរតាមរយៈរថភ្លើង ពេលយប់ទើបឈប់សម្រាកនៅខាងលិចខត្តុង្គ និងដាំបាយហូបតាមចំណតដែលរថភ្លើងឈប់។ ខ្ញុំចាំបានថា ខ្ញុំសម្រាករយៈពេល២យប់ទើបទៅដល់រ៉ាសិរីសោភ័ណ។ យប់ទី២ ខ្ញុំសម្រាកនៅរ៉ាពោធិ៍សាត់ ហើយស្អែកឡើងម៉ោងប្រហែល៣ ទើបទៅដល់រ៉ាសិរីសោភ័ណ។ ខ្ញុំឃើញគេដាក់ស្លាកថា សិរីសោភ័ណ សូមស្វាគមន៍។ ខ្មែរក្រហមឱ្យក្រុមគ្រួសារខ្ញុំសម្រាកនៅតាមផ្ទះល្វែងក្បែររ៉ាសិរីសោភ័ណមួយយប់ ទើបព្រឹកឡើងមានត្រាក់ទ័រមកដឹកយកទៅ។ ក្នុងមួយត្រាក់ទ័រដាក់បានប្រហែល៥ទៅ៦គ្រួសារ។ ត្រាក់ទ័រដែលដឹកគ្រួសារខ្ញុំ មានឪពុកខ្ញុំ,បងស្រីខ្ញុំរួមទាំងកូនគាត់ពីរនាក់, ខ្ញុំ, ប្អូនស្រីខ្ញុំ, ប្អូនប្រុសខ្ញុំ, គ្រួសារយាយយ៉ែម, គ្រួសារតាឃិន និងគ្រួសារតាអោក។ ត្រាក់ទ័រចេញដំណើរតម្រង់ទៅកាន់សាលារៀនភ្នំស្រុក។ ពេលទៅដល់សាលារៀនភ្នំស្រុក ត្រាក់ទ័របានឈប់។ ខ្ញុំចុះពីលើត្រាក់ទ័រ ក៏មានរទេះគោ ៥ទៅ៦មកដឹកខ្ញុំបន្តទៅភូមិ។ ប៉ុន្តែក្រុមគ្រួសារខ្ញុំមិនបានជិះរទេះគោទេ គឺដើរទាំងអស់គ្នា ចំណែករទេះគោសម្រាប់តែដឹកសម្ភារដែលយកមកតាមខ្លួនប៉ុណ្ណោះ។ ខ្ញុំនិងបងប្អូនបានមកដល់ភូមិបុស្បូវ សង្កាត់ស្រះជីក ស្រុកភ្នំស្រុក ខេត្តបាត់ដំបង(បច្ចុប្បន្ន ខេត្តបន្ទាយមានជ័យ)។ ពេលដែលទៅដល់ភូមិខ្មែរក្រហមឱ្យយកសម្ភារពីលើរទេះ ហើយខ្មែរក្រហមប្រជុំប្រាប់នឹងចែកដីឱ្យរស់នៅ។ អ្នកភូមិមូលដ្ឋានបានចែកស្បូវ១០កណ្តាប និងជួយកាប់ឈើមកធ្វើជាខ្ទមឱ្យ ប្រជាជនថ្មី។ ដោយស្បូវដែលខ្មែរក្រហមចែកមិនគ្រប់នឹងប្រក់ដំបូល ខ្ញុំបានយកសំពត់ហូលទៅដូរជាមួយនឹងម៉ែៗក្នុងភូមិបានស្បូវ៨០កណ្តាបទៀត ទើបប្រក់ដំបូលនិងបាំងធ្វើជាជញ្ជាំងគ្រប់។ ពេលខ្ញុំទៅដល់គឺមាន



ថ្នាំបុរាណសម្រាប់ព្យាបាលជំងឺក្នុងរបបខ្មែរក្រហម ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រជាជនចិនមួយក្រុមធំបានទៅដល់មុនពួកខ្ញុំ ដោយរស់នៅមួយចំហៀងផ្លូវ មិនរស់នៅលាយ ឡំគ្នាទេ។ ក្រោយមកមិនដឹងប្រជាជនចិនទាំងអស់នោះទៅរស់នៅកន្លែងណាទេ។ ការរស់នៅភូមិបុស្សរមិនលំបាកទេ ព្រោះខ្ញុំមានកូនតូច គឺខ្មែរក្រហមចែកស្រូវក្នុងម្នាក់១ផ្តិល ទាំងកូនក្មេង មនុស្សធំបានស្មើគ្នា។ ខ្ញុំសល់ខោរបស់ប្តីខ្ញុំមួយ គាត់ដេរធ្វើជាសាក់កាដូរដាក់អីវ៉ាន់។ ការងារដែលខ្មែរក្រហមឱ្យខ្ញុំធ្វើគឺដាំបន្លែ និងស្រោចបន្លែ។ ពេលមកដល់ភូមិកូនខ្ញុំចេះតែឈឺមិនជាសោះ។ ក្នុងភូមិមានម៉ែហ៊ុម និងពុក ឡំ ចេះស្តោះផ្លុំ។ គាត់បានជួយផុសថ្នាំបុរាណឱ្យកូនខ្ញុំផឹកក៏មិនជា។ តាមជំនឿគាត់ក៏ដាច់ចិត្តយកកូនរបស់ខ្ញុំទៅដាក់នៅផ្លូវបំបែកជា៤ រួចរើសកូនហ្នឹងមកឱ្យខ្ញុំវិញហើយប្រាប់ខ្ញុំជួយចិញ្ចឹមកូនឱ្យគាត់ព្រម ទាំងដាក់ឈ្មោះឱ្យកូនខ្ញុំថា «សារុំ» រហូតដល់សព្វថ្ងៃ។

នៅឆ្នាំ១៩៧៧ ទើបមានអ្នកគ្រប់គ្រងមកពីខាងភូមិភាគនិរតីចូលមក ពេលនោះការគ្រប់គ្រងក្នុងភូមិតឹងរឹងជាងមុន។ ខាងនិរតី មានតាវ៉ាល់ គឺជាអ្នកគ្រប់គ្រងចុះមកឆែកឆេរក្នុងផ្ទះសឹងតែរាល់ថ្ងៃ។ ពេលដែលកម្មាភិបាលខ្មែរក្រហមចុះមកឆែកឆេរ ខ្ញុំបានចេញទៅស្រោចបន្លែហើយ នៅសល់តែកូនស្រីខ្ញុំនៅចាំផ្ទះ ដោយមានប្អូនប្រុសម្នាក់គាត់ពិការជាអ្នកមើលថែ។ យប់ខ្លះអ្នកស្រុក និងខ្ញុំបានដឹកទឹកឱ្យទៅការដ្ឋានជីកទំនប់អាងត្រពាំងថ្ម។ ដោយសារយប់ងងឹតខ្ញុំមិនដឹងទេថា ទំនប់កាលនោះមានទំហំធំប៉ុណ្ណា ទើបតែរយៈពេល៤៥ឆ្នាំក្រោយ ខ្ញុំបានត្រ ឡប់ទៅកាន់ភូមិបុស្សរវិញ បានជួបជាមួយអ្នកដែលរស់នៅកាលពីជំនាន់ខ្មែរក្រហមជាមួយគ្នា។ ខ្ញុំបានជួបតែមនុស្ស៤នាក់ ដែលនៅរស់ ឈ្មោះយុត យឿន និង២នាក់ទៀតខ្ញុំមិនចាំឈ្មោះគាត់ទេ។ ក្រោយពីសំណេះសំណាលគ្នា រឿងរ៉ាវកាលពីអតីតកាល និងទឹកមុខដែលបានជួបគ្នាម្តងទៀតប្រកបដោយស្នាមញញឹម។ ក្រោយចាកចេញពីភូមិបុស្សរ ខ្ញុំបានបន្តដំណើរទៅមើលអាងត្រពាំងថ្ម ឃើញថា អាងមានទំហំធំណាស់ មិននឹកស្មានថាអាងនេះលើកដោយកម្លាំងមនុស្សទេ។

ខ្ញុំបាត់បង់បងស្រីម្នាក់ ក្លុយ និងប្អូនស្រីម្នាក់ក្នុងរបបខ្មែរក្រហម ព្រោះតែជំងឺពិស ឡើងភ្នែកក្រហម។ ប្អូនស្រីខ្ញុំមិនដឹងថាជាជំងឺពិស ឃ្លានផ្លែត្រប់ និងសម្រាកពេលថ្ងៃ។ ចាស់ៗក្នុងភូមិហាមមិនឱ្យសម្រាកថ្ងៃត្រង់ទេ តែដោយយើងជាអ្នកចំណូលថ្មីមិនដឹងពីការហាមនេះ ទើបធ្វើឱ្យប្អូនស្រីខ្ញុំស្លាប់។

នៅពេលរបបខ្មែរក្រហមដួលរលំ ខ្ញុំបានចេញមកតាមមាត់ស្ទឹងក្រ ឡាញ់ និងធ្វើដំណើរមកតាមសៀមរាប។ មកដល់ខាងលិចបារាយណ៍ទឹកថ្លា ក្រុមគ្រួសារខ្ញុំសម្រាកនៅតាមផ្លូវ និងចូលទៅក្នុងភូមិសុំអង្ករពីប្រជាជនចាស់។ ខ្ញុំសម្រាកនៅសៀមរាបមួយខែ ទើបបន្តធ្វើដំណើរមកដល់ស្គន់។ ពេលដល់ស្គន់ស្រាប់តែមានរថយន្តឈ្នួលជនជាតិវៀតណាមដឹកម្នាក់យកតម្លៃជាមាស១ជី ទើប ឡានដឹកមកដល់ភ្នំពេញ។ ខ្ញុំ និងសមាជិកគ្រួសារ បានបន្តដំណើរមកដល់ស្រុកកំណើតវិញ។ ប៉ុន្តែពេលមកដល់ស្រុកកំណើត បែរជាប្រជាជននៅក្នុងភូមិចោទសមាជិកគ្រួសារខ្ញុំថាជាខ្មែរក្រហម រួចរកចាប់ខ្ញុំទៀត។ ហេតុនេះទើបខ្ញុំ និងកូនស្រីសម្រេចចិត្តមកភ្នំពេញវិញ និងរស់នៅទីក្រុងភ្នំពេញរហូតមកដល់សព្វថ្ងៃ។













# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់បតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!














រូបក្របមុខ ៖
សម្តេចព្រះ នរោត្តម សីហនុ «ព្រះបរមរតនកោដ្ឋ»
ចុះជួបសំណេះសំណាលជាមួយប្រជានុរាស្ត្ររបស់ព្រះអង្គ និងដាំកូនឈើ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ ៖
ទីតាំងស្តូបដែលបានសាងសង់ឡើងដោយ សម្តេចព្រះ នរោត្តម សីហនុ
«ព្រះបរមរតនកោដ្ឋ» នៅឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ-សែនជ័យ ខេត្តស្ទឹងត្រែង
ថតពីលើអាកាស។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org



A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 300, December 2024 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.